ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jul-2013, 13:15
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០១នាទី**

**សវនាការលើកទី២០៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន *(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡៃ ជុនធី

លោកស្រី បេនី យេ *(Ms Ms. Beini YE)*

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី បេនី យេ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ម៉ម រិទ្ធា | ខ្មែរ |
| លោក ឡេវ ឡាំ (TCW-386) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឡេង ឡាំ** (TCW-386)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ២
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................ទំព័រ ៦
សួរដោយលោក សេង ប៊ុនឃាង ផ្តើមពី ....................ទំព័រ ៣៤
សួរដោយលោកស្រី បេនី យេ ផ្តើមពី ....................ទំព័រ ៣៧
សួរដោយលោក សុន អរុណ ផ្តើមពី ....................ទំព័រ ៤២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៤៤
សួរដោយលោក អាកទួរ វែកគែន ផ្តើមពី ....................ទំព័រ ៧២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះតាមកាលវិភាគដែលបានកំណត់ គឺអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-386។ លោកក្រឡាបញ្ជីសវនាការ លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ថា ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

សូមកត់សម្គាល់ផងដែរថា សហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដូចលោកប្រធានបានជម្រាបជូន សាក្សីដែលត្រូវផ្តល់សក្ខីកម្មថ្ងៃនេះគឺសាក្សីដែលមានរហស្សនាម TCW-386។ សាក្សីរូបនេះមានមេធាវីប្រឹក្សាឈ្មោះ ម៉ម រិទ្ធា។

សម្រាប់សវនាការថ្ងៃនេះមានសាក្សីបម្រុងមួយរូប គឺសាក្សីដែលមានរហស្សនាម TCW-689។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខរូបលោកតាដំបងដែកកាលពីព្រឹកមិញរួចហើយ។ សាក្សីរូបនេះបញ្ជាក់ថា គាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន នោះទេ។ ហើយតាមសមត្ថភាពដែលគាត់អាចដឹង គាត់ក៏មិនជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះផងដែរ។ សូមអរគុណលោកប្រធាន។

[០៩:០៤:១០]

**ប្រធានអង្គជំនុំ៖**

អរគុណលោក ផារី។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី ព្រមទាំងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[០៩:០៥:២៧]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៧:០០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក ឡេវ ឡាំ៖**

**ឆ៖** ខ្ញុំបាទ ឈ្មោះ ឡេវ ឡាំ នៅកំពង់ឆ្នាំង។

**ស៖** អរគុណលោក ឡេវ ឡាំ តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ខ្ញុំបាទអាយុ ៥៨ ឆ្នាំ។

**ស៖** អរគុណហើយទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទ រស់នៅភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

**ស៖** អរគុណហើយសព្វថ្ងៃនេះតើលោកប្រកបមុខរបរអ្វីលោក ឡេវ ឡាំ?

**ឆ៖** ខ្ញុំបាទ ធ្វើស្រែចម្ការ។

**ស៖** ឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ព្រីង ឡេវ។

**ស៖** ចុះម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ម្តាយបង្កើតរបស់ខ្ញុំឈ្មោះ នួន សែម។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ នូ រ៉េម មានកូន១០នាក់។

**ស៖** បាទ អរគុណ។ ហើយលោក ឡេវ ឡាំ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានចំណងញាតិលោហិតញាតិពន្ធជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ ហើយក៏មិនជាប់ញាតិលោហិតឬញាតិពន្ធជាមួយនឹងជនជាប់ចោទ

ទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែរ ហើយថាលោកបានស្បថរួចហើយនៅចំពោះមុខអ្នកតាដំបងដែកនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ តើពិតមែនដែរទេ?

**ឆ៖** បាទ ខ្ញុំបានស្បថនៅមុខលោកតាដំបងដែករួចហើយ។

**ស៖** តើលោកមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធនៃភាគីនៃរឿងក្តីនេះទេ? ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ឬហ្នឹងជាមួយនឹងជនជាប់ចោទ លោក នួន ជា និងលោក ខៀវ សំផន?

[០៩:១០:០០]

**ឆ៖** បាទ ខ្ញុំបាទអត់មានជាប់សាច់ឈាមជាមួយពួកហ្នឹង ហើយមិនដែរស្គាល់ផង។

**ស៖** អរគុណលោក ឡេវ ឡាំ។ ឥឡូវនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ លោក ឡេវ ឡាំ ក្នុងនាមលោកជាសាក្សីក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអត្ថាធិប្បាយ ឬអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយដើម្បីសម្រួលដល់ការអនុវត្តសិទ្ធិនេះ អង្គជំនុំជម្រះបានផ្តល់នូវមេធាវីប្រឹក្សាតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញដល់លោកដើម្បីជួយពិភាក្សាជាមួយលោកក្នុងការស្តាប់នូវសំណួរ ហើយនិងពិភាក្សាថា បើសិនជាប្រភេទសំណួរណាដែលទំនងជាដាក់បន្ទុកលើចម្លើយ ដែលលទ្ធផលនៃចម្លើយរបស់លោកអាចដាក់បន្ទុកលើខ្លួនឯង លោកអាចពិភាក្សាជាមួយមេធាវីប្រឹក្សារបស់លោកជាមុនសិន។ ហើយក្នុងការការសម្រេច គឺនៅតែលោក។ លោកអាចឆ្លើយបាន លោកសម្រេចមិនឆ្លើយមិនបាន បើសិនជាលោកយល់ថា សំណួរនេះជាសំណួរដែលនាំឲ្យលោកផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

[០៩:១១:២៧]

អំពីករណីក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ លោកត្រូវឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ ហើយលោកក៏ត្រូវតែឆ្លើយតែការណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះដែរឬទេ?

[០៩:១២:១០]

**ឆ៖** ម៉េច-- បាទខ្ញុំបាទ អត់យល់លោកប្រធាន។

**ស៖** ម្តងទៀត គឺលោកអាចមានសិទ្ធិថាមិនឆ្លើយតបនឹងសំណួរណាដែលនាំឲ្យចម្លើយរបស់លោកហ្នឹងដាក់បន្ទុកលើខ្លួនឯង ទម្លាក់កំហុសលើខ្លួនឯង។ នេះជាសិទ្ធិ ប៉ុន្តែសំណួរប្រភេទនេះ លោកអាចពិភាក្សាជាមួយនឹងមេធាវីប្រឹក្សាថាលោកសម្រេចឆ្លើយ ឬក៏មិនឆ្លើយ។ ឆ្លើយក៏បាន មិនឆ្លើយក៏បាន នេះជាសិទ្ធិរបស់លោក។ ក្នុងករណីផ្សេងទៀត គឺករណីយកិច្ចគឺលោកត្រូវតែឆ្លើយនូវរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមសួរលោក។ លើកលែងតែក្នុងករណី ដូចករណីសិទ្ធិដែលសំណួរ ឬអំណះអំណាងដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយក្រៅពីនេះ គឺលោកមានកាតព្វកិច្ចត្រូវតែឆ្លើយតែការណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬមានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬក៏ចៅក្រមសួរលោក។ បាទនេះជាករណីយកិច្ចក្នុងនាមជាសាក្សី។ លោកយល់ទេ?

**ឆ៖** បាទ ខ្ញុំយល់ហើយ អំពីចម្លើយណាដែលខ្ញុំបានឃើញ បានយល់ បានដឹង បានខ្ញុំឆ្លើយ។ បើខុសពីហ្នឹង ខ្ញុំអត់ដឹងឆ្លើយយ៉ាងម៉េចទេ ជូនអង្គប្រជុំ។

[០៩:១៣:៤៧]

**ស៖** បាទអរគុណ។ ហើយលោក ឡេវ ឡាំ តើរយៈពេលកន្លងមកនេះ ប៉ុន្មានឆ្នាំមុននេះ តើលោកធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយប្រសិនបើបានផ្តល់ លោកផ្តល់ប៉ុន្មានដង ហើយនៅពេលណា? នៅទីកន្លែងណា?

**ឆ៖** បាទ ខ្ញុំបានផ្តល់សម្ភាសនៅផ្ទះខ្ញុំ នៅខែកក្កដា។ ភ្លេចបាត់ហើយ ខ្ញុំភ្លេចបាត់ហើយលោកប្រធាន។ បានសម្ភាសមែន បានសម្ភាសម្តង។

**ស៖** នៅហ្នឹងផ្ទះរបស់លោក នៅភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ អ៊ីចឹងពិតមែនទេ?

**ឆ៖** បាទពិតមែនហើយ។

**ស៖** តើលោកចាំឆ្នាំទេ ឆ្នាំណា ក្នុងឆ្នាំណាប្រហែល?

**ឆ៖** នៅឆ្នាំ២០០៨។

**ស៖** អរគុណលោក ឡេវ ឡាំ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ

តើលោកបានពិនិត្យមើល ឬក៏បានអាន ឬក៏ស្តាប់ការអានរបស់បុគ្គលណាម្នាក់នូវកំណត់ហេតុដែលលោកផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៅនឹងផ្ទះរបស់លោកកាលពីឆ្នាំ២០០៨នោះ ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ បានគាត់សម្ភាសខ្ញុំនោះ ខ្ញុំបាន -- លោកខាងមេធាវីជួយពន្យល់ដែរ ប៉ុន្តែខ្ញុំបានមើលបានដាច់ខ្លះ មិនដាច់ខ្លះ ដោយសារអក្សរវាជាប់គ្នាពេក។

**ស៖** បាទ អរគុណ។ តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំតើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលលោកផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតដែលលោកបានអាន ឬក៏បានស្តាប់ការអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ ឬក៏ស៊ីសង្វាក់គ្នា ស្របទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៨ នោះដែរឬទេ?

[០៩:១៦:២១]

**ឆ៖** បាទ ខ្ញុំបានមើលទៅតាម ខ្ញុំសម្ភាសនោះ ដល់តែមើលទៅវាដូចស្រដៀងគ្នាខ្លះ ប៉ុន្តែមានចំណុចមួយដែល ជួនកាលគាត់ដាក់ពាក្យលើស បានខ្ញុំមានបញ្ហាខ្លះ ព្រោះខ្ញុំមានត្រូវការតវ៉ាដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយក្នុងស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមជម្រាបផងដែរថា តំណាងសហព្រះរាជអាជ្ញារួម និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលសរុបកន្លះថ្ងៃក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរមេធាវី និងភាគីទាំងអស់។ លោកប្រធានខ្ញុំសូមចាប់ផ្តើមដោយបង្ហាញឯកសារគឺកិច្ចសម្ភាសន៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឺឯកសារដែលមានលេខ D125/68។ ដូច្នេះសូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំសូមលោកប្រធានអនុញ្ញាត ដើម្បីឲ្យខ្ញុំអាចបង្ហាញឯកសារនេះជូនដល់សាក្សី។ សូមលោកប្រធានអនុញ្ញាត។

[០៩:១៧:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:១៨:២២]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌែល លីសាក់៖**

**ស៖** សូមជម្រាបសួរលោក ឡេវ ឡាំ ខ្ញុំឈ្មោះ ឌែល លីសាក់ ខ្ញុំជាតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ហើយខ្ញុំនឹងមានសំណួរមួយចំនួនដើម្បីសាកសួរលោក។ ហើយខ្ញុំនឹងសួរបន្តពីអ្វីដែលលោកទើបតែបានជម្រាបទៅអង្គជំនុំជម្រះ គឺលោកជម្រាបទៅដល់លោកប្រធាន។ លោកបានជម្រាបថា មានផ្នែកមួយនៅក្នុងកិច្ចសម្ភាសន៍របស់លោកដែលលោកថាចង់ធ្វើការកែតម្រូវ តើលោកចង់កែតម្រូវទៅលើផ្នែកណាដែរ? តើលោកអាចប្រាប់បានទេថាផ្នែកណាមួយនៃកិច្ចសម្ភាសន៍នោះដែលលោកចង់ធ្វើការកែតម្រូវ?

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ ខ្ញុំចង់កែតម្រូវដែលខ្ញុំដើរទៅគុកដំរីស្រុតនោះ ឃើញគេយកសពមកនៅកប់។ ប៉ុន្តែគាត់ដាក់ត្រង់ថា "ខ្ញុំឃើញដល់ទៅពីរដង"។ ខ្ញុំឃើញតែម្តងនៅពេលដែលខ្ញុំដើរទៅនុ៎ងទេ។ សូមកែត្រង់ហ្នឹង។ សូមអរគុណ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ យើងនិយាយអំពីហេតុការណ៍ដែលបានកើតឡើងនៅពេលនោះ។ ជាដំបូងខ្ញុំសូមសួរលោកពីរបីសំណួរពាក់ព័ន្ធទៅនឹងរយៈពេលមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ នៅក្នុងចម្លើយដំបូងរបស់លោក នៅក្នុងកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត គឺឯកសារ D125/68 នោះ លោកបានបញ្ជាក់ដូចតទៅនេះ៖ "នៅក្នុងឆ្នាំ១៩៧២ ខ្ញុំបានធ្វើជាឈ្លបឃុំស្វាយជុក ស្រុកកំពង់ត្រឡាចលើ ហៅស្រុក១២។ ខ្ញុំធ្វើកងឈ្លបពីឆ្នាំ១៩៧២ រហូតដល់ឆ្នាំ១៩៧៥។ ខ្ញុំបានចេញពីកងឈ្លបនៅវាងពាក់កណ្តាលឆ្នាំ១៩៧៥ ហើយបានទៅនៅក្នុងកងចល័តឃុំវិញ"។ តើស្រុកដែលលោកនិយាយថា លោកបញ្ជាក់ថា លោកធ្វើជាកងឈ្លបរបស់ឃុំនុ៎ង តើនៅស្រុកហ្នឹង គេហៅថាស្រុកកំពង់ត្រឡាចលើ ឬក៏ហៅស្រុក១២ នៅក្នុងឆ្នាំ៧៥? តើស្រុកហ្នឹងវាដូចគ្នាហ្នឹងស្រុកដែល

មានឈ្មោះថា សាមគ្គីមានជ័យ។ តើស្រុកកំពង់ត្រឡាចលើ និងស្រុកសាមគ្គីមានជ័យហ្នឹងដូចគ្នាតែមួយ ឬក៏ខុសគ្នា?

[០៩:២១:១៦]

**ឆ៖** បាទ ស្រុកកំពង់ត្រឡាចលើ ហើយនិងស្រុកសាមគ្គីមានជ័យហ្នឹង ដូចតែគ្នាទេ។ គ្រាន់តែមុនស្រុកកំពង់ត្រឡាចលើហ្នឹងចាស់ ស្រុកសាមគ្គីហ្នឹងគេដាក់ថ្មី ទើបហ្នឹងដាក់ថ្មីប៉ុន្មានឆ្នាំហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកអាចពណ៌នាដោយសង្ខេបបានទេ អំពីការងារដែលលោកទទួលធ្វើក្នុងពេលដែលលោកធ្វើជាឈ្លបឃុំ គឺឈ្លបឃុំស្វាយជុក ពីឆ្នាំ៧២ រហូតដល់ខែមេសា ឆ្នាំ៧៥ ហ្នឹង តើលោកបំពេញការងារអ្វីខ្លះ?

**ឆ៖** បាទ ខ្ញុំនៅចាប់ពីឆ្នាំ១៩៧២ មកខ្ញុំចូលធ្វើកងឈ្លបនេះ គឺមិនបានធ្វើអីទេ គ្រាន់តែជាបង្កបង្កើនផល ដាំដំណាំ ដាំជាដំឡូង ដាំ -- ឡើងត្នោត រហូតមកដល់ឆ្នាំ១៩៧៥ ហ្នឹង។

**ស៖** តើលោកធ្លាប់ចូលរួមក្នុងការវាយប្រយុទ្ធជាមួយកងទ័ព លន់ នល់ ដែរឬទេ គឺថាក្នុងចន្លោះឆ្នាំ៧២ ដល់៧៥ ហ្នឹង? តើលោកធ្លាប់ប្រយុទ្ធជាមួយពួក លន់ នល់ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនបាន ដែលបានទៅទេ គ្រាន់តែគេឲ្យនៅបង្កបង្កើនផលនៅខាងក្រោយ។

**ស៖** តើលោកធ្លាប់ទៅបោះទីតាំងនៅកន្លែងណាដែរ? តើនៅក្នុងភូមិណាដែលលោកឈរជើងពេលដែលជាកងឈ្លបនុ៎ង?

**ឆ៖** ខ្ញុំបានបោះទីតាំងនៅកន្លែងខាងត្បូងភូមិច្រកសង្កែ ប្រហែលជា៣០០ម៉ែត្រពីភូមិ។

**ស៖** តើអ្នកណាជាមេកើយរបស់លោកនៅពេលដែលលោកធ្វើជាឈ្លបនៅក្នុងឃុំស្វាយជុកនោះ?

**ឆ៖** អង្កាល់នុ៎ងមេធំឈ្មោះ ស្រ៊ន និង ណាន។

**ស៖** តើ ស្រ៊ន គាត់មានតួនាទីជា -- គាត់កាន់តួនាទីអ្វីដែរ? ហើយចុះ ណាន ហ្នឹងគាត់កាន់តួនាទីអ្វីដែរ?

**ឆ៖** ណាន តួនាទីជាមេឃុំស្វាយជុកខាងជើង។ ស្រ៊ន ហ្នឹងគាត់ជាគណៈស្រុក។

**ស៖** មុនពេលដែលយើងចូលទៅដល់ហេតុការណ៍ក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំមានសំណួរមួយចំនួនទៀតទាក់ទងទៅនឹងស្រុកកំពង់ត្រឡាចលើ។ ខ្ញុំចង់សួរលោកជាគឺថា តើលោកដឹងអំពីការវាយដណ្ដើមយកទីក្រុងឧដុង្គដោយពួកខ្មែរក្រហមនៅក្នុងឆ្នាំ៧៤ដែរឬទេ? តើលោកដឹងអំពីព្រឹត្តិការណ៍នេះទេ?

[០៩:២៥:៣៨]

**ឆ៖** ខ្ញុំបានដឹងថាគេជម្លៀសមកហ្នឹង ឃើញថាគេជម្លៀសមកហ្នឹងបានដឹងថាគេវ៉ៃភ្នំពេញបែកដែលខ្ញុំនៅខាងក្រោយឯណោះ ខ្ញុំនៅឡើងត្នោតណោះ។

**សៈ** ខ្ញុំចង់សាកសួរលោកអំពីឧដុង្គ គឺទីរួមស្រុកឧដុង្គ តើលោកចាំ ឬក៏លោកដឹងអំពីការរំដោះក្រុងឧដុង្គដែរឬទេ គឺនៅពេលដែលមានការរំដោះក្រុងឧដុង្គដោយពួកខ្មែរក្រហមដែរទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងថា -- ដឹងប៉ុន្តែគ្រាន់តែថាវាខេត្តខុសគ្នា ខាងឧដុង្គគឺខេត្តកំពង់ស្ពឺ ខាងលង្វែកគឺខេត្តកំពង់ឆ្នាំង ដឹងថាខាងកំពង់ឆ្នាំងទេ ឃើញជម្លៀសខាងកំពង់ឆ្នាំង។

**សៈ** ខ្ញុំមានសំណួរពីរបីទៀតទាក់ទងទៅនឹងស្រុករបស់លោក។ តើមានឃុំមួយទៀតនៅក្នុងស្រុកកំពង់ត្រឡាចលើ ដែលគេហៅថាឃុំភីម តើលោកស្គាល់ឃុំភីមនៅក្នុងស្រុកកំពង់ត្រឡាចលើហ្នឹងទេ?

**ឆ៖** ឃុំភីម អត់ដែលស្គាល់ឃុំភីមហ្នឹងផង អត់ទេ។

**លោក សេង ប៊ុនឃាង៖**

អ៊ីចេះលោកប្រធានដើម្បីឲ្យច្បាស់ ព្រោះឈ្មោះនេះពិបាកអានបន្តិច។ លោកសាក្សីគឺឈ្មោះ ឃុំពាម១ បាទ១។

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ ឃុំពាមហ្នឹងជាប់នឹងស្វាយជុក នៅខាងលិចឃុំស្វាយជុកគេហៅថាឃុំពាម បាទស្គាល់។

[០៩:២៧:៥០]

**សួរដោយលោក ខេល លីសាក់៖**

**សៈ** នៅពេលដែលលោកនិយាយថានៅក្បែរ គឺវានៅខាងលិចនៃស្រុកស្វាយជុកហ្នឹងតែមែនទេ។

**ឆ៖** បាទ១ នៅខាងលិចឃុំស្វាយជុកគេហៅពាម ព្រោះឃុំជាប់គ្នា។

**សៈ** លោកសាក្សី គឺមានភស្តុតាងនៅក្នុងការជំនុំជម្រះនេះ ដែលថាមានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនមានមន្ទីរនៅក្នុងឃុំពាម ក្នុងឆ្នាំ៧២ ចន្លោះពីឆ្នាំ៧២ ដល់ឆ្នាំ៧៥នោះ។ ហេតុដូច្នេះហើយទើបខ្ញុំចង់សួរមួយចំនួនទាក់ទងទៅនឹងឃុំពាមនេះ។ នៅក្នុងសវនាការនេះ នៅថ្ងៃទី២២ ខែវិច្ឆិកាឆ្នាំ២០១១ គឺខ្ញុំនិយាយយោងទៅលើឯកសារ E1/14.1 គឺនៅម៉ោង ១៤:៥៤:៣៥វិនាទី គឺនៅត្រង់

ចំណុចនេះលោក នួន ជា បានបញ្ជាក់ថា ខ្ញុំសូមដកស្រង់ “ដើម្បីធានា -- ដើម្បីដឹកនាំការប្រយុទ្ធវាយផ្តាច់ព្រ័ត្ររំដោះភ្នំពេញឲ្យមានប្រសិទ្ធភាព ប៉ុល ពត លេខាបក្សទៅនៅប្រចាំការជិតសមរភូមិឯភ្នំពេញ គឺនៅភូមិបឹងតាលង ខាងត្បូងភូមិច្រកស្តេច ឃុំពាម ស្រុកកំពង់ត្រឡាច”។

[០៩:២៩:៤៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន ដើម្បីជួយដល់សាក្សីឲ្យយល់អំពីឈ្មោះនៃទីតាំងទាំងអស់នេះ ខ្ញុំសូមអនុញ្ញាតលោក ដើម្បីផ្តល់នូវសម្រង់ដែលខ្ញុំទើបតែអានអម្បាញ់មិញនេះ ដើម្បីឲ្យសាក្សីគាត់អាចមើលជាភាសាខ្មែរគឺមើលឈ្មោះជាភាសាខ្មែរដើម្បីឲ្យគាត់អាចយល់ច្បាស់សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីសូមលោកមើលទៅលើផ្នែកដែលខ្ញុំដាក់ក្រដាសពណ៌ខៀវ ពណ៌បៃតងនៅក្បែរនុ៎ង គឺលោកមើលឃើញថាវាជាចម្លើយរបស់លោក នួន ជា ហើយគាត់បានបញ្ជាក់អំពីមូលដ្ឋានដែលប៉ុលពត បានបោះទីតាំងគឺបោះទីតាំងនៅភូមិច្រកស្តេច នៅក្នុងឃុំពាម។ អ្វីដែលខ្ញុំចង់សួរលោកគឺថា តើលោក ស្គាល់ទីតាំងនេះដែរឬទេ?

[០៩:៣១:០៥]

**ឆ៖** បាទ ខ្ញុំមិនដែលបានស្គាល់ទីតាំងគេទេ ព្រោះគេអ្នកធំ ខ្ញុំតូចតាចខ្ញុំមិនដែលបានទៅគេហៅជិត ទៅជួបទេ។ បាទមានតែប៉ុណ្ណឹង។

**ស៖** ក្រៅពីមន្ទីររបស់ ប៉ុល ពត តើលោកស្គាល់ភូមិនេះដែរឬទេ គឺខ្ញុំចង់សួរលោកអំពីភូមិច្រកស្តេច។ តើលោកស្គាល់ភូមិហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំស្គាល់ភូមិច្រកស្តេច ស្គាល់។

**ស៖** នៅក្នុងចម្លើយរបស់ នួន ជា ដដែលនេះគាត់បានបន្តទៅទៀតថា ពេលកងទ័ពបដិវត្តន៍ចូលទៅជិតភ្នំពេញប៉ុលពតទៅនៅឃុំក្រាំងដូងហៅ ប-៥ ជាប់ឃុំពាម ស្រុកកំពង់ត្រឡាច គឺនៅភូមិចន្ទី។ អ្វីដែលខ្ញុំចង់សួរលោកគឺថា ខ្ញុំមិនមែនចង់សួរថាលោកស្គាល់ ប-៥ ឬក៏អត់នោះទេ ប៉ុន្តែខ្ញុំចង់សួរថា

លោកស្គាល់ទីតាំងឃុំដែល នួន ជា បានរៀបរាប់គឺឃុំក្រាំងដូង និងភូមិចន្ទីហ្គឹង។ តើលោកស្គាល់ឃុំក្រាំងដូង និងភូមិចន្ទីហ្គឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតបសូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក នួនជា?

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ។ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាឲ្យលេខឯកសារ ថា នួន ជា នឹងមកឲ្យដឹងទាំងអស់គ្នាផង។ និយាយតែពីអ្នកសាក្សីអ៊ីចឹងវាមិនមានហេតុផលត្រឹមត្រូវ។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំបានបញ្ជាក់រួចហើយថាជាប្រតិចារឹកនៃសវនាការគឺថាជាប្រតិចារឹកដដែលដែលខ្ញុំបានដកស្រង់ពីមុនរួចទៅហើយគឺឯកសារ E1/14.1 គឺជាប្រិចារឹកនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ នៅម៉ោង ១៤:៥៤:៣៥ វិនាទី។ តើខ្ញុំអាចបន្តទៅមុខបានទៀតទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសួរលោកតទៅទៀត លោក ឡេវ ឡាំ គឺខ្ញុំមិនដឹងថាលោកស្គាល់ឬមិនស្គាល់ ប-៥ ទេ ប៉ុន្តែតើលោកអាចប្រាប់ខ្ញុំទេ អំពីទីតាំងដែលរៀបរាប់នៅទីនេះទេ អំពីភូមិចន្ទី ហើយនិងឃុំដែលថាអាចជាឃុំក្រាំងដូង?

**ឆ៖** បាទ ខ្ញុំស្គាល់ភូមិក្រាំងដូងក៏ធ្លាប់ស្គាល់ដែរព្រោះធ្លាប់បានទៅ រាល់ដងខ្ញុំធ្លាប់ទៅលេងនៅភូមិហ្នឹង ភូមិពាម ភូមិខ្ញុំដែរ។ ស្គាល់ ស្គាល់ក្រាំដូង ស្គាល់ច្រកស្ដេច ស្គាល់។

[០៩:៣៥:២០]

**ស៖** លោក ខៀវ សំផន នៅក្នុងសវនាការនេះ គាត់បាននិយាយថា នេះគឺឯកសារ E3/27 បាទ E3/27 នៅខ្មែរ 00156614, អង់គ្លេស 00156743, ហើយបារាំង 00156666។ លោក ខៀវ សំផន បាននិយាយថាគាត់ ហើយនិងមេដឹកនាំមួយចំនួនដូចជា នួន ជា។ គឺទីតាំងនៅមន្ទីររបស់ប៉ុល ពត នៅពេលមុនដែលចូលដល់ឆ្នាំ ខែមេសា ឆ្នាំ១៩៧៥។ ខ្ញុំសួរលោកថា តើលោកធ្លាប់ឮទេនៅពេលនោះ

ដែលថា មានមេដឹកនាំកំពូលរបស់កម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហម ដូចជា ប៉ុល ពត, នួន ជា និងខៀវ សំផន បាននៅឃុំពាមនោះដែរឬទេ?

**ឆ៖** ខ្ញុំបានឮតែឈ្មោះទេ ប៉ុន្តែគ្រាន់តែថាមិនដែលឃើញ មិនដឹងគាត់មុខអាម៉េចផង។ បាទ មានតែប៉ុណ្ណឹង។

[០៩:៣៦:៥៥]

**លោក ខេល លីសាក់៖**

បាទ ហើយសំណួរមួយទៀតទាក់ទងទៅនឹងខ្លឹមសារយោង មុននឹងចូលដល់ខែមេសា ឆ្នាំ១៩៧៥ ហើយសក្ខីកម្មដែលផ្តល់ឡើងដោយឈ្មោះ ឌុច នៅក្នុងរឿងក្តីនេះ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២។ ឯកសារ E1/51.1 ៗ ប្រតិចារឹកថ្ងៃទី២០ មីនា ឆ្នាំ២០១២ ម៉ោង ០៩:២០នាទី និង២វិនាទី។

សូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញជូនសេចក្តីដកស្រង់ជូនសាក្សីពិនិត្យមើល ដើម្បីឲ្យគាត់បានឃើញទីតាំង ទីកន្លែងដែលខ្ញុំនឹងសួរបន្ត។ សូមអនុញ្ញាតបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សីនៅក្នុងឯកសារដែលបានជូនទៅលោកនេះ បាទ នៅផ្នែកមួយដែលយើងគូសសម្គាល់ដោយពណ៌បៃតងនោះ ឌុច នោះបាននិយាយថា ដំបូងទីតាំងរបស់ទីបញ្ជាការនៃភូមិភាគពិសេស មន្ទីររបស់ វន វ៉េត នៅក្នុងឆ្នាំ១៩៧៣ គឺនៅភូមិក្រាំងបេង ឃុំពាមខាងត្បូង នៅស្រុកកំពង់ត្រឡាចលើ។ តើលោកស្គាល់ភូមិមួយនៅឃុំពាម ទេដែលភូមិនោះឈ្មោះថា “ភូមិក្រាំងបេង”?

[០៩:៣៩:០៤]

**ឆ៖** បាទខ្ញុំស្គាល់។ ភូមិក្រាំងបេង ស្គាល់។

**ស៖** តើលោកដឹងដែរឬទេថា មានភូមិភាគពិសេស មានទីបញ្ជាការភូមិភាគពិសេសនៅជិតភូមិនេះនៅក្នុងឆ្នាំ១៩៧៣នោះ?

**ឆ៖** ខ្ញុំបាទ ខ្ញុំអត់ដែលដឹងថាជំរំគាត់បោះនៅកន្លែងហ្នឹងទេ គ្រាន់តែខ្ញុំបាទស្គាល់តែភូមិ។ ប៉ុន្តែជំរំទ័ពហ្នឹង វាអត់ទេ អត់ដែរឃើញ។

**សៈ** តើលោកស្គាល់ថា វន វ៉េត ជានរណាដែរឬទេនៅក្នុងឆ្នាំ១៩៧២ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ នោះ?

**ឆៈ** បាទ វន វ៉េត នេះក៏ខ្ញុំមិនដែលស្គាល់ដែរ ព្រោះអីខ្ញុំនៅតែក្នុងភូមិណេះមិនដែលបានដើរទៅត្រង់ហ្នឹងទេ។

**សៈ** សហព្រះរាជអាជ្ញា ឥឡូវនេះខ្ញុំសូមចូលទៅដល់ព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បាទហើយនិងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីនោះ។ ដំបូងខ្ញុំចង់សួរលោកថា តើលោកនៅកន្លែងណានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះ?

[០៩:៤១:00]

**ឆៈ** បាទ ឆ្នាំ៧៥ហ្នឹង ខ្ញុំនៅឡើងត្នោតនៅឡើយទេ នៅកន្លែងមន្ទីរឡើងត្នោតៗគ្នាតែ៣នាក់ទេ គេឲ្យឡើងត្នោត ថ្ងៃឆ្នាំ៧៥ហ្នឹង។

**សៈ** លោកនៅទីកន្លែងដែលលោកបានបញ្ជាក់ប្រាប់តុលាការខាងដើមហ្នឹងបាទ ដែលថា ៣០០ ម៉ែត្រពីភូមិច្រកសង្កែ តើនៅកន្លែងហ្នឹងឬ?

**ឆៈ** បាទ ខ្ញុំនៅកន្លែងហ្នឹងហើយនៅឡើងត្នោតកន្លែង។

**សៈ** តើលោកបានឃើញអ្នកជម្លៀសចេញ -- ប្រជាជនដែលជម្លៀសពីភ្នំពេញទៅបានទៅដល់ឃុំរបស់លោកទេ ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះ?

**ឆៈ** បាទ ខ្ញុំបានឃើញអ្នកជម្លៀសពីកំពង់ឆ្នាំង ច្រើនពីកំពង់ឆ្នាំងមកវិញទេ។ រឿងខាងភ្នំពេញផ្សេង ច្រើនខាងកំពង់ឆ្នាំង។

**សៈ** តើអ្នកដែលទាំងនោះបានទៅដល់ភូមិរបស់លោកហ្នឹងរយៈពេលប៉ុន្មាន គឺរយៈពេលប៉ុន្មានក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ នោះ?

**ឆៈ** ទៅបានអស់រយៈពេលប្រហែលជាមួយអាទិត្យ។

**សៈ** តើលោកអាចប៉ាន់ប្រមាណបានទេ ថាតើឃើញមានមនុស្សប៉ុន្មាននាក់? ប៉ុន្មានគ្រួសារ? ដែលលោកបានសង្កេតឃើញថា គេបញ្ជូនទៅឃុំស្វាយជុកនោះ?

**ឆៈ** បាទ ខ្ញុំបានឃើញប្រហែលជាងពីរបីរយ-- ២០០គ្រួសារឯណោះ ប៉ុន្តែសព្វថ្ងៃវានៅរស់ខ្លះព្រោះបាត់ខ្លួនអស់ខ្លះហ្នឹង។

[០៩:៤៣:៤៣]

**ស៖** បាទ នេះខ្ញុំ -- យើងនឹងសួរលោកអំពីការបាត់ខ្លួននេះនៅពេលបន្តិចទៀតនេះ ប៉ុន្តែចង់សួរថានៅពេលដែលប្រជាជនជម្លៀសទៅដល់ឃុំរបស់លោកនោះ គេឲ្យអ្នកទាំងអស់នោះនៅកន្លែងណា?

**ឆ៖** បាទ គេជម្លៀសមកហ្នឹង គឺវានៅក្នុងភូមិច្រកសង្កែហ្នឹង ឃើញនៅភូមិហ្នឹង ច្រកសង្កែហ្នឹង។

**ស៖** តើនៅកន្លែងនោះគេប្រើអគារ ឬក៏រោងដើម្បីឲ្យអ្នកប្រជាជនជម្លៀសរស់នៅ ឬក៏ឲ្យនៅក្នុងវត្ត ឬក៏នៅកន្លែងណានៅពេលដែលប្រជាជនជម្លៀសទៅដល់នោះ?

**ឆ៖** បាទ ពេលដែលប្រជាជនជម្លៀសទៅហ្នឹងគឺអត់មានជម្រកទេ គឺនៅតាមក្រោមផ្ទះ ក្រោមម្លប់ឈើ នៅក្នុងភូមិហ្នឹង។ បាទ ក្រោមផ្ទះចាស់ដែលប្រជាជនដែលនៅមុន ដូចជាផ្ទះខ្ញុំអីហ្នឹង គាត់មករស់នៅៗក្រោមផ្ទះខ្ញុំអីចឹងទៅ ក្រោមម្លប់ឈើ ដើមឈើ។

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលដែលប្រជាជន ១៧ មេសា ជាប្រជាជនជម្លៀសទៅដល់ឃុំរបស់លោក ថាតើគេតម្រូវឲ្យប្រជាជនទាំងនោះផ្តល់នូវប្រវត្តិរូបអ្វីទេ?

[០៩:៤៥:៣៧]

**ឆ៖** បាទ ខ្ញុំបានដឹងថា គេឲ្យរើសប្រវត្តិរូបនោះ ដោយបញ្ជាពីឈ្មោះ ស្រ៊ន ថាឲ្យឈ្មោះ ណាន នោះបានធ្វើប្រវត្តិរូបប្រជាជន១៧មេសានេះ ដើម្បីទុកអ្នកខាងកសិករ ពួកស្ម័យត្រាណគេទុកមួយកន្លែងអីចឹង។ សូមអរគុណ។

**ស៖** ចំពោះដែលលោកបានកំណត់ឈ្មោះអំមិញនេះ ដែលថាជាអ្នកណែនាំថា ឲ្យគេប្រមូលប្រវត្តិរូប ស្រ៊ន ហ្នឹងដែលជាអ្នកបង្គាប់ហ្នឹង តើគាត់ហ្នឹងជាគណៈស្រុកដូចដែលលោកបានបញ្ជាក់ពីខាងដើមហ្នឹង ឈ្មោះហ្នឹង?

**ឆ៖** បាទ ឈ្មោះហ្នឹងពិតហើយ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងអានជូនលោកស្តាប់ផ្នែកមួយនៃបទសម្ភាសន៍របស់លោកជូនទៅការិយាល័យចៅក្រមស៊ើបអង្កេត គឺឯកសារ D125/68, ខ្មែរ ERN 00201484 ដល់ 85, អង់គ្លេស 0027 4647, បារាំង 00338364។ លោកបានឆ្លើយដូចខាងក្រោមនេះ នៅផ្នែកនេះ សូមដកស្រង់ “ពេលនោះគឺភ្លាមៗបន្ទាប់ពីថ្ងៃ១៧ មេសា ខ្ញុំនៅជាឈ្លបនៅឡើយ ហើយធ្វើការជាមួយ ណាន បន្ទាប់ពីទទួលសេចក្តីណែនាំពី ស្រ៊ន--

[០៩:៤៨:០៤]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចលោកតំណាងសហព្រះរាជអាជ្ញា មានការជំទាស់តវ៉ាពីខាងមេធាវីការពារក្តី។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរ។ ខ្ញុំសូមជំទាស់ចំពោះការអានដោយសហព្រះរាជអាជ្ញានូវខ្លឹមសារនេះ។ តាមពិតនោះ ខ្ញុំដឹងអំពីសេចក្តីសម្រេចលើបញ្ហាដែលទាក់ទងទៅនឹងអានខ្លឹមសារមួយចំនួនពីចម្លើយ -- ពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំក៏ជំទាស់ផងដែរអំពីមូលហេតុមួយចំនួន ជាពិសេស ខ្ញុំជំទាស់ដោយថាផ្នែកនេះជាផ្នែកដ៏សំខាន់មួយកាលណាយើងនិយាយអំពីគោលនយោបាយដែលសហព្រះរាជអាជ្ញាព្យាយាមបង្ហាញភស្តុតាង។ ហើយម្យ៉ាងវិញទៀត លោកប្រធាន លោក លោកស្រីចៅក្រម យើងៗជាជំហានដំបូងនៃការសួរសំណួរសាក្សីនេះ គាត់បានឆ្លើយថា នេះគឺជាកំណត់ហេតុពីមុន គឺមិនចាំបាច់ឲ្យរំឭកការចងចាំ។ ហេតុអ្វីក៏យកមកសួរសំណួរបែបនេះដូចដែលសហព្រះរាជអាជ្ញា យកមករំឭកនេះ ពីព្រោះគាត់បានរំឭករួចហើយ។

[០៩:៤៩:៣៣]

**លោក ឌេល លីសាក់៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបទៅនឹងការជំទាស់នេះ។ ចំណុចទី១ នេះគឺជានីតិវិធីដែលតុលាការបានសម្រេចរួចហើយ។ ទី២ មេធាវីមានការយល់ច្រឡំអំពីផ្នែកខ្លឹមសារមួយដែលខ្ញុំលើកនេះ មិនមែនជាបញ្ហាស្រួចស្រាល់នោះទេ។ ប្រហែលថាលោកយល់ច្រឡំអំពីខ្លឹមសារដែលខ្ញុំបម្រុងនឹងអាន ហើយខ្ញុំនឹងបន្តសួរនៅសំណួរបើកចំហ ដើម្បីឲ្យសាក្សីនេះ។ ប៉ុន្តែសាក្សីបានបញ្ជាក់ហើយថា មានការណែនាំឲ្យគេធ្វើប្រវត្តិរូប។ ឥឡូវនេះខ្ញុំនឹងដកស្រង់អំពីខ្លឹមសារដែលនិយាយអំពីប្រវត្តិ ហើយនិងខ្លឹមសារលម្អិត។ ដូច្នេះ ខ្ញុំនឹងអនុវត្តដូចអ្វីដែលតុលាការបានអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើនោះឯង។ ហើយខ្ញុំយល់ថា ការជំទាស់របស់មេធាវីការពារក្តីនេះមិនសមស្របទេ សូមជ្រាបបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥១:០២]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់មេធាវីការពារក្តីលោក នួន ជា ចំពោះសំណួរ

និងវិធីនៃការរៀបចំតាំងសំណួររបស់សហព្រះរាជអាជ្ញា គឺមានលក្ខណៈមិនសមស្របទេ។ តំណាងសហព្រះរាជអាជ្ញាបានប្រព្រឹត្តទៅក្នុងការតាំងសំណួរដេញដោលតាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះ ដែលអនុវត្តជិត២ឆ្នាំកន្លងមកហើយ។

លោកតំណាងសហព្រះរាជអាជ្ញាអាចបន្តវិធីសាស្ត្រក្នុងការសួរដេញដោលតទៅទៀត!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តឡើងវិញ ពីចំណុចពីដំបូងដែលខ្ញុំចង់បញ្ជាក់ជូនសាក្សី។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកបាននិយាយថា៖ "ភ្លាមៗបន្ទាប់ពីថ្ងៃ១៧ មេសា ខ្ញុំនៅជាឈ្លបនៅឡើយ ហើយធ្វើការជាមួយ ណាន។ បន្ទាប់ពីទទួលសេចក្ដីណែនាំពី ស្រ៊ន ឈ្មោះ ណាន បានធ្វើការកត់ត្រាប្រវត្តិរូបរបស់ប្រជាជន ១៧មេសា។ បន្ទាប់មក ណាន បានហៅប្រធានភូមិនៅក្នុងឃុំទាំងអស់មកប្រាប់ឲ្យប្រវត្តិរូបប្រជាជន១៧មេសា ដែលនៅក្នុងឃុំទាំងអស់នេះ"។ សូមបញ្ចប់សេចក្ដីដកស្រង់។

នៅក្នុងចម្លើយនេះលោកបានយោងទៅរកការប្រជុំមួយ ដែល ណាន ដែលលោកបញ្ជាក់ថា គាត់នោះជាប្រធានឃុំ ដែលការប្រជុំនោះ ណាន បានណែនាំប្រធាភូមិឲ្យកត់ត្រាប្រវត្តិរូប។ តើការប្រជុំនោះនៅកន្លែងណា? លោកចាំទេបាទ?

[០៩:៥២:៥១]

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ កន្លែងប្រជុំនោះគឺនៅមន្ទីរនោះទេ កន្លែងខ្ញុំនេះនុំង អាមន្ទីរនៅពីរបីរយម៉ែត្រពីភូមិនោះ មិនប្រជុំនៅក្នុងភូមិទេ។ ពេលនោះខ្ញុំបាននៅក្បែរៗនោះ។

**ស៖** តើលោកបានវត្តមាននៅកន្លែងប្រជុំដែរឬទេ នៅពេលដែល ណាន គាត់បានណែនាំឲ្យប្រធានភូមិទាំងអស់ធ្វើប្រវត្តិរូបចំពោះប្រជាជនជម្លៀសនោះ?

**ឆ៖** បាទ គេមិនឲ្យយើងខ្ញុំឃើញទេ គ្រាន់តែឮថា ពេលគេប្រជុំនោះឲ្យ មិត្តណាន ឲ្យប្រធានភូមិធ្វើប្រវត្តិរូប។ គ្រាន់តែប៉ុណ្ណឹង គេមិនឲ្យយើងឃើញទេរឿងប្រវត្តិរូបនោះ មិនឲ្យខ្ញុំបានដឹងទេរឿងប្រវត្តិរូបនោះ មិនបានឃើញទេ។

**ស៖** សូមឲ្យលោកជម្រាបតុលាការពីអ្វីដែលលោកចងចាំច្បាស់បំផុត។ តើលោកបានឮពាក្យ

ពេចន៍អ្វីខ្លះដែល ណាន បានណែនាំ ឬក៏ប្រាប់ឲ្យទៅប្រធានភូមិប្រមូល ឬក៏កត់ត្រាប្រវត្តិរូបនោះ តាមដែលលោកចាំ លោកចាំពាក្យអ្វីពី ណាន និយាយនោះ?

**ឆ៖** ខ្ញុំបាទខ្ញុំបានចាំដែលខ្ញុំបាទនៅជិតក្នុងរោងដែរ ថា ណាន ប្រាប់ប្រធានភូមិឲ្យប្រធានមកប្រមូលប្រវត្តិរូប ដើម្បីយកមកប្រគល់ឲ្យទៅ ស្រ៊ន។ បាទ ខ្ញុំស្តាប់បានប៉ុណ្ណឹង។

[០៩:៥៥:00]

**ស៖** តើលោកអាចប្រាប់តុលាការបានទេ ថាតើមន្ទីររបស់ ណាន នោះនៅកន្លែងណា?

**ឆ៖** បាទ មន្ទីររបស់ ណាន ហ្នឹងគឺគាត់អត់មាននេះទេ នៅកន្លែងហ្នឹងដែលហ្នឹង។ កាលហ្នឹងគាត់មិនបានធ្វើជាមន្ទីរទេ មានតែពួកឈ្លបប៉ុន្មាននាក់ទេដែលគេធ្វើរោងឲ្យនៅ ខាងកម្មាភិបាលគេ គេនៅតាមផ្ទះប្រជាជនទេ។ ផ្ទះហ្នឹងវាថាផ្ទះប្រជាជនទេ ប៉ុន្តែគេសុំនៅ កម្មាភិបាលគេនៅ។

**ស៖** នៅក្នុងចម្លើយដែលខ្ញុំទើបតែបានអានហើយលោកក៏បានចង្អុលបង្ហាញថា នៅក្នុងភ្លាមៗបន្ទាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥លោកនៅជាឈ្លបនៅឡើយ ហើយលោកធ្វើការជាមួយ ណាន។ នៅពេលដែលលោកថាលោកធ្វើការជាមួយ ណាន នោះ តើឈ្លបឃុំត្រូវរាយការណ៍ទៅឲ្យ ណាន នោះទេ?

**ឆ៖** បាទ អារឿងកងឈ្លបនឹងវាការងារពី -- មានតែ ណាន ទេដែលអ្នកបញ្ជាដែរ ឲ្យសម្រាកទៅធ្វើការអី ទៅដូចជារត់សំបុត្រ ដូចជាធ្វើការនេះនុំង ណាន បញ្ជាឲ្យឈ្លបហ្នឹងទៅធ្វើការហ្នឹងដែរ។

**ស៖** តើលោកមានមុខតំណែង ឬក៏មុខងារតំណែងអ្វីទេនៅក្នុងជាឈ្លបឃុំនៅកាលនោះ?

**ឆ៖** បាទ ខ្ញុំអត់មាន គ្រាន់តែជាឈ្លបមែន តែអត់មានតំណែងអីទេ ព្រោះអីខ្ញុំជាប់នូវនិន្នាការ។

[០៩:៥៧:៤៨]

**ស៖** ខ្ញុំមិនប្រាកដថាខ្ញុំ -- ប្រហែលជាលោកបានបញ្ជាក់ហើយឬនៅ? ប៉ុន្តែសូមលោកបញ្ជាក់តើត្រូវដែរឬទេ ណាន ហ្នឹងគាត់ជាស្ត្រីទេ។ តើអីចឹងដែរឬទេបាទ?

**ឆ៖** បាទ ពិតមែន ស្ត្រីទេ គ្នាស្រីទេ កម្មាភិបាលស្រី*(ឮមិនច្បាស់)*។

**ស៖** បន្ទាប់ពីគេធ្វើប្រវត្តិរូបរួចហើយគេប្រមូលពីប្រជាជន១៧ មេសា ជាប្រជាជនជម្លៀសនៅក្នុងឃុំរបស់លោកនោះ តើលោកបានដឹងទៀតទេថាតើគេបញ្ជូនប្រវត្តិរូបនោះទៅណា? ហើយគេយកប្រវត្តិរូបនោះទៅប្រើដូចម្តេច? គេចាត់វិធានការដូចម្តេច?

**ឆ៖** បាទ ខ្ញុំបានដឹងថាឲ្យ មិត្តណាន ហ្នឹងប្រមូលពីប្រធានភូមិ យកទៅប្រគល់ឲ្យ ស្រ៊ន រួច

ដល់ប្រគល់ឲ្យទៅ មិនដឹងគាត់ចាត់ចែងយ៉ាងម៉េចទេ ខ្ញុំបាទមិនបានតាមដានគេដែរ។

**ស៖** ខ្ញុំនឹងអានចម្លើយមួយទៀតជាខ្លឹមសារ ជាបទសម្ភាសន៍របស់លោក គឺនៅក្នុង D125/68 ខ្មែរ 00201484, អង់គ្លេស 00274646, បារាំង 00338364 លោកបាននិយាយនៅទីនេះថា នៅពេលដែលប្រជាជន១៧មេសា មកពីភ្នំពេញមកដល់ស្រុកទី១២ហើយ គេឲ្យអ្នកទាំងអស់នោះបំពេញប្រវត្តិរូប។ ផ្អែកតាមចម្លើយរបស់អ្នកទាំងនោះ គេបានបែងចែកទៅជាពីរប្រភេទ ប្រជាជនធម្មតា ដូចជាកសិករ ហើយប្រជាជនមិនធម្មតាដូចជាទាហាន ដូចជារដ្ឋការលន់នល់ នោះហើយនិងទាយទុន ជាដើមនោះផងដែរ។ តើលោកអាចប្រាប់ខ្ញុំបានទេថា តើលោកដឹងថាប្រជាជន១៧មេសា ជាប្រជាជនជម្លៀសនោះត្រូវបានគេបែងចែកទៅតាមប្រវត្តិរូបរបស់គេហ្នឹងទៅជាពីរក្រុម គឺប្រជាជនធម្មតា ហើយនិងប្រជាជនមិនធម្មតា ដូចជាទាហាន រាជការ អ្នករាជការរបប លន់ នល់ នោះ។ តើលោកដឹងដោយរបៀបណាថាគេបែងចែកបែបនេះ?

[១០:០១:០០]

**ឆ៖** បាទដែលខ្ញុំដឹង កាលណោះ ខ្ញុំនៅឈ្លបនៅឡើយ ហើយឮសួរគេថា ឲ្យបែងចែកជាពីរអង្គាល់ធ្វើប្រវត្តិរូបហ្នឹង ថាកសិករដាក់ឲ្យនៅដោយកសិករ។ ខាងស្វ័យត្រាណឲ្យនៅតែដោយស្វ័យត្រាណទៅ ហើយទាហានគេអត់មានម៉េចសួរទេទាហាន ដឹងតែទាហានគេប្រឆាំងហើយ គេអត់សួរទេ។

**ស៖** តើលោកនៅចាំទេ តើលោកដឹងដោយរបៀបណាថា ប្រជាជន១៧មេសានោះ ត្រូវបានគេបែងចែកទៅជាពីរក្រុម តើលោកឮពីអង្គប្រជុំ ដែលលោកបានចូលរួម ឬក៏ ណាន ជាអ្នកប្រាប់លោក ឬក៏អ្នកណាផ្សេងទៀតនៅក្នុងឃុំជាអ្នកប្រាប់លោកពីរឿងនេះបាទ?

**ឆ៖** បាទពេលដែលគាត់នៅកន្លែងប្រជុំហ្នឹង ខ្ញុំក៏នៅជិតហ្នឹងដែរ ឮសួរតែអ៊ីចឹង ឮសួរថា ណាន ថាយើងត្រូវបែងចែកទុកប្រជាជនជាកសិករហ្នឹងទុកឲ្យធ្វើការ។

**ស៖** នៅពេលដែលលោកនិយាយថា លោកនៅក្បែរការប្រជុំ ហើយឮសួរ ណាន និយាយហ្នឹង តើវាជាការប្រជុំដូចដែលលោកបានបញ្ជាក់ពីមុនមកហើយ ឬមួយក៏ជាការប្រជុំផ្សេងមួយទៀត នៅពេលដែលលោកបានឮ ណាន និយាយនោះ?

**ឆ៖** បាទ ខ្ញុំឮតែម្តងហ្នឹងទេថាប្រជុំកាលនៅ ដែលខ្ញុំនៅក្បែរនោះតែម្តងហ្នឹង។

[១០:០២:៣៤]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកថាតើអ្នកជម្លៀសអ្នក១៧មេសា ដែលមកឃុំស្វាយជុកហ្នឹង តើអ្នកជម្លៀសហ្នឹងមានទាំងមន្ត្រីលន់ នល់ មានទាំងទាហាន លន់ នល់ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំតាមដឹងវា ព្រោះតាំងពីប្រជាជន ទាហាន វាលាយគ្នាហ្នឹង មកច្របូកច្របល់គ្នា ដែលពេលដែលគាត់ចេញជម្លៀសមកហ្នឹង។ ណាដាច់បាយ ដាច់អង្ករគាត់ផងហ្នឹង ចេញតែមកនៅក្នុងភូមិហ្នឹងទៅ វាច្របូកច្របល់គ្នា។ អ៊ីចឹងបានគេថា លើកប្រវត្តិរូបអ៊ីចឹងហ្នឹង។ ខ្ញុំដឹងអ៊ីចឹង។

**ស៖** នៅពេលដែលអ្នកជម្លៀសមកដល់ឃុំរបស់លោក តើលោកមានឃើញថាអ្នកជម្លៀសណាមួយ ឬក៏អ្នកណាម្នាក់ គាត់ពាក់ខោអាវទាហានដែរឬទេ?

**ឆ៖** បាទខ្ញុំ តាមខ្ញុំដឹងវាឃើញមានទាហានដែរថា ដូចឧទាហរណ៍ថាទាហានហ្នឹងវាបីបួន-ម្ភៃសាមសិបនាក់អ៊ីចឹងទៅ។ ប៉ុន្តែឃើញតែនៅបាន១ថ្ងៃ ក៏ចេញទៅទៀតទៅ មិនដឹងចេញទៅតាមច្រកណាទេ ឃើញទាហាន ព្រោះថាបើប្រជាជនមានគោ មានផ្ទះ អាចនៅហ្នឹងបានរហូតដល់១អាទិត្យឬនៅដល់សព្វថ្ងៃ។

[១០:០៤:៥៨]

**ស៖** តើមេឃុំ ឬក៏មេស្រុកហ្នឹងគាត់មានផ្តល់ការណែនាំ ឬក៏ការបញ្ជាថា តើត្រូវធ្វើយ៉ាងម៉េចជាមួយពួកជម្លៀស១៧មេសាហ្នឹង? តើគេមានប្រាប់ថាត្រូវធ្វើយ៉ាងម៉េចជាមួយអ្នកជម្លៀសដែលត្រូវគេរកឃើញថាជាពួកសក្តិភូមិ ឬក៏ពួកមន្ត្រីរដ្ឋការ ឬក៏ទាហាន លន់ នល់ ដែរទេ? ថាតើត្រូវធ្វើយ៉ាងម៉េចអីដែរទេ?

**ឆ៖** បាទ ពេលដែលគេរើសហ្នឹង ខ្ញុំ -- ពេលដែលរើសហ្នឹងខ្ញុំមិនបានដឹងទេ ដល់ក្រោយមកឮសួរគេនិយាយថា រើសអ្នក១៧ ជាកសិករហ្នឹងឲ្យនៅមួយកន្លែង ហើយនិងអ្នកស្ម័យគ្រាណហ្នឹងឲ្យនៅមួយកន្លែងទៅ។ ក្រោយមកវាបាត់អ្នក អាពួកធ្វើស្ម័យគ្រាណក៏បាត់ខ្លួនអស់អ៊ីចឹងទៅ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងអានន្ទរចម្លើយរបស់លោកបន្តទៅទៀត ដើម្បីសួរបន្ថែមទៅលើចំណុចនេះគឺឯកសារ D125/68 នៅត្រង់ភាសាខ្មែរមានលេខ 00201484, ភាសាអង់គ្លេសមានលេខ 0027 4646, ភាសាបារាំងមានលេខ 00338364។ ដែលនៅត្រង់នេះលោកបានឆ្លើយថា៖ “បញ្ជាត្រូវបានចេញពីមេភូមិ និងមេឃុំ និងមេស្រុក ខ្ញុំបានឮដោយផ្ទាល់ ដែលថាមេស្រុក ស្រុក១២ ឈ្មោះ ស្រ៊ន បានប្រាប់ ណាន (ស្រី) គណៈឃុំស្វាយជុកថា ត្រូវបែងចែកពួកគេ។ ទុកពួកកសិករឲ្យនៅធ្វើការ ហើយយកពួកខ្មាំងចេញ ត្រូវកម្ទេចពួកនាយទុន។ សំណួរ៖ តើ កម្ទេច មានន័យដូចម្តេច? ឆ្លើយ៖ នៅពេល

នោះទាំងអស់គ្នាដឹងថា កម្មេចគឺសម្លាប់"។ ហើយបន្ទាប់មកចុះមកក្រោមបន្តិច គឺនៅទំព័របន្ទាប់លោកបានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖

[១០:០៧:៤៤]

"ស្រ៊ន ជាអ្នកធ្វើការសម្រេចចុងក្រោយដើម្បីឲ្យ ណាន យកទៅអនុវត្ត។ ខ្ញុំបានឮដោយផ្ទាល់ត្រចៀករបស់ខ្ញុំអំពីសេចក្តីសម្រេចនោះ ក្នុងនោះមានឪពុកមារបស់ខ្ញុំម្នាក់ត្រូវបានគេសម្រេចយកទៅសម្លាប់ដែរ។ ពេលនោះ ខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង តែមិនហ៊ាននិយាយអ្វីទាំងអស់ មានតែបង្ហូរទឹកភ្នែកតែប៉ុណ្ណោះ។ នៅពេលនោះមានមនុស្សប៉ុន្មាន ១០០គ្រួសារត្រូវបាននាំយកទៅសម្លាប់ នាដើមរដូវវស្សាឆ្នាំ១៩៧៥។ បទបញ្ជាសម្លាប់នេះត្រូវបានអនុវត្តភ្លាម"។ ខ្ញុំសូមបញ្ចប់ការដកស្រង់ចម្លើយរបស់លោក។ សំណួរទី១ របស់ខ្ញុំគឺថា--

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាផ្អាកបន្តិចសិន!

សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន! ដើម្បីជាកំណត់ត្រាប្រតិចារឹក គឺថាយើងមិនគួរអាននូវប្រយោគនេះទេ ព្រោះប្រយោគនេះជាប្រយោគសំខាន់ ដូច្នេះគួរតែមានការសួរជាសំណួរបើកតែម្តងទៅ។ ដូច្នេះចំពោះខាងព្រះរាជអាជ្ញា គឺយើងមិនអាចទទួលយកបានទាល់តែសោះក្នុងការដែលយើងធ្វើបែបនេះ ហើយទទួលយកចម្លើយពីសាក្សី។ ដូច្នេះដើម្បីជាកំណត់ត្រាប្រតិចារឹក យើងខ្ញុំសូមធ្វើការប្រឆាំងជំទាស់យ៉ាងខ្លាំង។

[១០:០៩:០២]

**លោក ឌេល លីសាក់៖**

លោកប្រធាន! ខ្ញុំគិតថាតុលាការបានសម្រេចរួចទៅហើយ។ ខ្ញុំបានសួរនូវសំណួរបើក ហើយឥឡូវនេះខ្ញុំធ្វើការសួរដេញតាមពីក្រោយដែលផ្តល់នូវព័ត៌មានលម្អិត។ ដូច្នេះ តើខ្ញុំអាចបន្តទៅមុខទៀតបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ពុំមានប្រសិទ្ធភាពទេ មិនមានមូលដ្ឋានសមស្របទេ ពីព្រោះអង្គជំនុំជម្រះបានសម្រេចរួចហើយនូវទម្រង់ការណ៍នៃវិធីសាស្ត្រក្នុងការតាំងសំណួរដេញដោលនៅក្នុងតុលាការនេះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោលបន្តទៅទៀត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងចំណុចនេះលោកបានបញ្ជាក់ថា លោកបានឮសេចក្ដីសម្រេច ឬក៏ការបង្គាប់ពីមេដឹកនាំថ្នាក់ស្រុក គឺឈ្មោះ ស្រ៊ន រួមបញ្ចូលទាំងសេចក្ដីសម្រេចសម្លាប់អ៊ំរបស់លោកផង។ តើលោកបញ្ជាក់បានដែរឬទេ ថាតើលោកស្ដាប់ឮសេចក្ដីសម្រេចរវាង ស្រ៊ន ហើយនិង ណាន ហ្នឹងនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំបានស្ដាប់បាននៅពេលដែលគាត់ប្រជុំនៅកន្លែងមន្ទីរកងឈ្លបនុ៎ង។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេថា ក្នុងនោះលោកនិយាយថា ឪពុកមារបស់លោកត្រូវបានគេយកទៅសម្លាប់ផងដែរ? តើឪពុកមារបស់លោកគាត់មានតួនាទីអ្វីដែរមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ តើគាត់មាន -- តើគាត់បំពេញការងារអ្វីដែរ?

[១០:១០:៥៧]

**ឆ៖** បាទ ឪពុកមាខ្ញុំហ្នឹងគាត់ធ្វើទាហាននៅខាង លន់ នល់ នៅលង្វែក។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ គឺលោកបាននិយាយថា កិច្ចប្រជុំដែលលោកបានស្ដាប់ឮ គឺកិច្ចប្រជុំដែលធ្វើឡើងនៅមន្ទីរកងឈ្លប។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ដែរឬទេថា កិច្ចប្រជុំហ្នឹងធ្វើឡើងនៅកន្លែងណាដែរ? តើនៅក្នុងភូមិច្រកសង្កែ ឬមួយក៏នៅក្រៅភូមិច្រកសង្កែ?

**ឆ៖** បាទ ដែលខ្ញុំដឹងនេះ គឺនៅក្រៅភូមិទេ គឺនៅកន្លែងកងឈ្លបហ្នឹង គឺរោងកន្លែងកងឈ្លបហ្នឹង។ នៅកន្លែងខ្ញុំនៅហ្នឹងឯង។

**ស៖** តើលោកចាំដែរឬទេថា មានមនុស្សប្រហែលប៉ុន្មាននាក់ចូលរួមក្នុងកិច្ចប្រជុំនោះ?

**ឆ៖** បាទ ខ្ញុំកាលណោះវាប្រជុំហ្នឹង វាប្រហែលជា ១០នាក់ ជាង១០នាក់។

**ស៖** តើអ្នកដែលចូលរួមហ្នឹងជាអ្នកណាខ្លះក្រៅពី ណាន ហើយនិង ស្រ៊ន? តើអ្នកដទៃទៀតដែលចូលរួមនៅក្នុងការប្រជុំហ្នឹងជាអ្នកណាខ្លះដែរ?

[១០:១២:៥៤]

**ឆ៖** បាទ ចូលរួមប្រជុំនោះ ដែលខ្ញុំនៅជិតនុ៎ង ឃើញតែប្រធានភូមិច្រកសង្កែ និងកម្មាភិបាលថ្នាក់ក្រោមៗគាត់ហ្នឹង ហើយនិងប្រធានភូមិមក ហៅមកតាមភូមិហ្នឹង ក្នុងឃុំស្វាយជុកខាងជើងហ្នឹង។

**ស៖** បន្ទាប់ពីមានការប្រជុំនេះរួចមក តើមានអ្វីកើតឡើងចំពោះជនភៀសខ្លួន ១៧មេសា ត្រូវ

បានគេរកឃើញថាជាទាហាន ឬក៏មន្ត្រីរដ្ឋការ លន់ នល់ ឬក៏ពួកមូលធននិយម តើមានអ្វីកើតឡើងចំពោះពួកទាំងអស់នោះ?

**ឆ៖** វាកើតឡើងដល់ពេលប្រជុំរួចទៅ វាមានជាការធ្វើប្រវត្តិរូបហ្នឹងបាទ។ បានបាត់ខ្លួន អ្នកខ្លះនៅ អ្នកខ្លះបាត់ហ្នឹង។ វាកើតឡើងពី វាកម្ទេចចោលហ្នឹង។

**សៈ** ចុះឪពុកមារបស់លោកយ៉ាងដូម្ដេចដែរ? តើមានអ្វីកើតឡើងចំពោះឪពុកមារបស់លោកដែលជាទាហាននោះ?

**ឆ៖** បាទ ឪពុកមាខ្ញុំគាត់មកដល់ផ្ទះហ្នឹង ក៏មកជួបខ្ញុំ ជួបអ៊ីចឹង។ ខ្ញុំប្រាប់ថា សូមគេចពីកន្លែងហ្នឹងទៅ។ "អញជួបម៉ែហើយ អត់ទេសុខចិត្តងាប់នៅហ្នឹង"។ រួចបានប៉ុន្មានថ្ងៃ បាន៣ថ្ងៃ គេយកគាត់ទៅសម្លាប់ចោលទៅ។

[១០:១៤:២៣]

**សៈ** តើលោកអាចប្រាប់អំពីទីតាំងដែលគេយកមនុស្សទាំងអស់នោះទៅសម្លាប់ តើទីតាំងនៅកន្លែងណាដែល?

**ឆ៖** បាទ ទីតាំងដែលយកពូខ្ញុំទៅសម្លាប់ ហើយនិងប្រជាជនគឺនៅខាងប៉ែកខាងលិចភូមិឆ្ងាយដែលប្រហែលជា បីបួនគីឡូឯណោះ។

**សៈ** ឥឡូវនេះខ្ញុំចង់សួរលោកទាក់ទងទៅនឹងចម្លើយរបស់លោកដទៃទៀត។ គឺឯកសារ D125/68 ដែលមានលេខ ឯកសារភាសាខ្មែរ 00201486, ភាសាអង់គ្លេសមានលេខ 00274648 និងភាសាបារាំង មានលេខ 00338366 ហើយពេលនោះគេសួរលោកអំពីថាតើលោកមានវត្តមាននៅទីតាំងសម្លាប់មនុស្សដែរឬទេ ហើយលោកបានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់ "ពីព្រោះពេលម្ដងនោះគេបានឲ្យខ្ញុំនាំមនុស្សត្រូវសម្លាប់ទៅកាន់ទីនោះ"។ ឥឡូវខ្ញុំសូមបញ្ចប់ការដកស្រង់។ តើលោកអាចជម្រាបបានឬទេ ថាអ្នកណាជាអ្នកបង្គាប់ឲ្យលោកនាំមនុស្សទៅកាន់ទីតាំងសម្លាប់មនុស្សនៅទីនោះ?

[១០:១៧:១២]

**ឆ៖** បាទ ពេលនោះដែលខ្ញុំទៅអាហ្នឹងគេហៅប្រធានភូមិឈ្មោះ តាអួន។ តាអួន ហ្នឹងគាត់ប្រធានភូមិគាត់ថា "ឯងទៅជូនអញទៅនោះមួយភ្លែត ទៅនាំគេទៅមុខ"។ នាំប្រជាជនទៅមុខ ខ្ញុំក៏ទៅដែរ មិនមែនទៅតែខ្ញុំទេ ទៅគ្នាពីរនាក់។ ឈ្លបហ្នឹងក៏ទៅ។ ដល់ពេលទៅហ្នឹង គេទៅគេដាក់មួយកន្លែងប្រជុំមួយដើម្បីគេឲ្យពួកហ្នឹងចាប់ចងដាក់អីយកទៅសម្លាប់ហ្នឹង។ ដល់ពេលខ្ញុំបានទៅនោះ ឮសួរ --

ដល់ពេលហ្នឹងទ័ពស្រុកគេនៅនុំងស្រេចហើយ។ ឥឡូវជូនមកបានតែត្រឹមហ្នឹងឯង។ "ទុកទៅទុកឲ្យខ្ញុំចាត់ការហ្នឹង មិត្តឯងនៅមួយកន្លែងកុំឆ្វេចឆ្វាចដើរទៅណា"។

**ស៖** ក្រុមប្រជាជនត្រូវបានគេបញ្ជូនទៅកន្លែងសម្លាប់នោះគឺបញ្ជូនដោយមេភូមិ ហើយនិងរូបលោកព្រមទាំងឈ្លបដទៃទៀតនោះ តើក្នុងក្រុមមនុស្សដែលគេយកទៅសម្លាប់នោះមានមនុស្សប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ទៅចុងក្រោយគេបង្ករស់ហ្នឹង ប្រហែលជាគ្នា២០នាក់ទាំងកូនតូចតាចអីផង។ ខ្ញុំស្មានថាគេនាំឲ្យភូមិផ្សេងបានខំទៅ។ គេបញ្ជាឲ្យហើយចេះតែទៅ។ ដល់ពេលទៅគេមិនដឹងថាគេយក ទៅសម្លាប់ទេ ស្រាប់តែទៅដល់នោះ មានពួកកងទ័ពស្រុក គេហៅថាទ័ពស្រុកនោះ គេប្រមូលកម្លាំងចាប់ចងចាប់អីហ្នឹងមក។ ហើយខ្ញុំក៏ភ័យខ្លាចដែរជំនាន់នោះព្រោះខ្ញុំនៅមួយកន្លែងហ្នឹង រួចបានរួចអីចឹងទៅខ្ញុំគេចមកវិញមក។ គ្រាន់តែជូនទៅដល់កន្លែងនោះគេចាត់ការគេផ្សេង។

[១០:២០:០០]

**ស៖** តើមនុស្សប្រហែល២០នាក់ហ្នឹង គេដឹកយកទៅកន្លែងសម្លាប់មនុស្សដោយរបៀបណា តើពួកគាត់ហ្នឹងដើរ ឬមួយក៏គេមានដឹករទេះ ដឹកតាមមធ្យោបាយអ្វីផ្សេង?

**ឆ៖** គាត់អ្នកមានគោ មានរទេះហ្នឹង គាត់បរគោបររទេះទៅ។ បើអ្នកមានទេ គេដើរទៅថ្មើរជើង ឲ្យដើរតិចៗទៅ រហូតទៅដល់កន្លែងគេប្រជុំរៀបចំសម្លាប់ហ្នឹង។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីកន្លែងសម្លាប់មនុស្សដែលលោកយកទៅហ្នឹងថា តើកន្លែងហ្នឹងគឺជាកន្លែងដែលលោកនិយាយថា ប្រហែលជាពីរបី -- ប្រហែលជាបីបួនគីឡូខាងលិចនៃភូមិច្រកសង្កែហ្នឹង តើមែនទេ?

**ឆ៖** បាទនៅកន្លែងហ្នឹងហើយ។

**ស៖** លោកទើបតែបញ្ជាក់រួចហើយថានៅពេលដែលលោកមកដល់កន្លែងសម្លាប់មនុស្សហ្នឹងគឺថានៅទីហ្នឹងមានទាហានស្រុក។ តើនៅកន្លែងហ្នឹងមានទាហានស្រុកប្រហែលប៉ុន្មាននាក់ដែរដែលនៅចាំនៅកន្លែង?

**ឆ៖** បាទទាហានទ័ពស្រុកមានតែមួយក្រុមទេ មានតែ និយាយឲ្យអស់ទៅ១២នាក់ហ្នឹង។

[១០:២១:៥៧]

**ស៖** តើទ័ពស្រុកហ្នឹងគឺជាទ័ពស្រុកដែលលោកធ្លាប់ឃើញ ដែលធ្លាប់ជួបពីមុន ឬក៏ជាពួកថ្មីទេ?

**ឆ៖** បាទទ័ពស្រុកហ្នឹង គឺខ្ញុំធ្លាប់ឃើញកាលពីមុននោះ ក៏ធ្លាប់ឃើញដែរ។ កាលពីនៅឆ្នាំ៧៣, ៧៤ហ្នឹង ឃើញវា ធ្លាប់ស្គាល់ដែរអាទ័ពហ្នឹង។ ប៉ុន្តែស្គាល់តែមុខទេ ហើយឈ្មោះ គេចេះតែផ្លាស់ឈ្មោះរហូត។

**ស៖** តើលោកដឹងទេថានៅពេលនុ៎ង អ្នកណាជាមេបញ្ជាការពួកទ័ពស្រុកនោះ?

**ឆ៖** មេបញ្ជាការ ខ្ញុំអត់ស្គាល់ទេ ទាល់តែទ័ពហ្នឹង មេបញ្ជាការវាច្រើនពេក មិនដឹងអ្នកណាមួយ។ ខ្ញុំមិនសូវចាំទេ ទ័ពស្រុកហ្នឹង ខ្ញុំនៅភូមិហ្នឹង។

**ស៖** ខ្ញុំចង់សួរលោកផងដែរ ថាតើហេតុការណ៍ហ្នឹងវាកើតឡើងនៅពេលណា? តើប្រហែលជាប៉ុន្មានថ្ងៃ ប៉ុន្មានខែ ក្រោយថ្ងៃ១៧មេសា ៧៥? គឺខ្ញុំចង់ដឹងថាតើពេលដែលលោកនាំមនុស្សប្រហែលជា២០នាក់ហ្នឹងទៅកន្លែងសម្លាប់មនុស្សហ្នឹង វាកើតឡើងនៅក្នុងអំឡុងពេលណាដែរ?

**ឆ៖** នៅឆ្នាំ៧៥ហ្នឹងដែរ ប៉ុន្តែគ្រាន់តែក្នុងខែ៦ ៧ហ្នឹង ឲ្យជូនទៅ។

[១០:២៤:១៧]

**ស៖** មុននេះបន្តិចលោកបានប្រាប់យើងថា នៅពេលដែលលោកមកដល់កន្លែងសម្លាប់មនុស្សហ្នឹង គឺមនុស្សនៅក្នុងក្រុម២០នាក់ហ្នឹងត្រូវបានគេចង ហើយគេបណ្តើរចេញទៅ។ ថាតើអ្នកណាជាអ្នកចងប្រជាជនទាំង២០នាក់នោះ?

**ឆ៖** អាហ្នឹង ខ្ញុំឃើញវាមុនដំបូងចងតែ១០នាក់ទេ គឺយកទៅទុក១០នាក់សិន ហើយនិងក្មេងៗតូចតាចនេះ វាមិនចងទេ។ ចាប់តែចងតែប្រុសៗមុនទេ ចងយកទៅ១០នាក់ ប៉ុន្តែគឺតែទាហានស្រុកហ្នឹងម្តង ទ័ពស្រុកហ្នឹងម្តង ជាអ្នកចាប់ចង។

**ស៖** តើលោកអាចប្រាប់បានដែរឬទេថា គេចងហ្នឹងចងរបៀបយ៉ាងណាដែរ?

**ឆ៖** បាទ ដែលខ្ញុំនៅជិតហ្នឹង ខ្ញុំឃើញចងនឹងក្រមា ចងស្លាបសេក។ ចងក្រមា ហែកក្រមាចងបាទ ចងស្លាបសេកជាប់ ហើយបញ្ជូនដើរទៅបណ្តោយ។

**ស៖** តើអ្នកណាជាអ្នកនាំមនុស្ស១០នាក់ដែលគេចងហើយហ្នឹង តើនៅពេលដែលគេចង១០នាក់ហើយ អ្នកណាជាអ្នកបណ្តើរពួកគាត់ចេញទៅ?

**ឆ៖** បាទ ហ្នឹងហើយអ្នកចងហ្នឹងហើយអ្នកបណ្តើរទៅ សុំស្មើចង ចងរួចទាហានហ្នឹង ទ័ពស្រុកហ្នឹងហើយអ្នកបណ្តើរយកទៅបណ្តោយ។

[១០:២៦:២៦]

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេថា នៅពេលដែលគេចងមនុស្ស១០នាក់ហ្នឹងហើយគេយកទៅហ្នឹង តើមានអ្វីកើតឡើងចំពោះអ្នកទាំង១០នាក់ ដែលគេចងបណ្ដើរយកទៅនោះ?

**ឆ៖** បាទ គេចងទៅហើយ គឺគេយកទៅសម្លាប់ អត់មានទុកអីទៀតទេ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេថា តើប្រជាជនដែលគេយកទៅហ្នឹងគេសម្លាប់ដោយរបៀបណាដែរ?

**ឆ៖** បាទ ពេលគេសម្លាប់ហ្នឹងមិនដឹងធ្វើម៉េចទេ ប៉ុន្តែតាមដឹងក្រោយគេមានដំបង មានភ្លៅរទេះ ថាតាម -- ដឹងតាមក្រោយ។ គេមិនបាញ់ទេ បាញ់ខ្លាចបែកការណ៍ គេសម្លាប់ដោយភ្លៅរទេះ ដោយដំបងគល់ឫស្សីអីហ្នឹង។

**ស៖** តើលោកធ្វើយ៉ាងម៉េចបានដឹងថា គេប្រើដំបងឫស្សី ឬក៏ភ្លៅរទេះសម្លាប់មនុស្សហ្នឹង តើលោកដឹងដោយរបៀបណាថាគេប្រើវត្ថុទាំងអស់នេះសម្លាប់មនុស្សនោះៗ?

**ឆ៖** បាទ ខ្ញុំដឹងនេះតាមគេដឹងទៅតាមគេថាទេ ហើយមិនបានមើលផ្ទាល់ភ្នែកទេ។ គេថាគ្មានស្អីហួសពីភ្លៅរទេះទេ គល់ឫស្សីទេ គ្មានឮមួយប្រស់ទេ។ ព្រោះថាបាញ់វាឮ គល់ឫស្សី ហើយនិងភ្លៅរទេះហ្នឹងអត់ឮទេ។ នេះតាមដឹងក្រោយមកទៀត។

[១០:២៨:៥៣]

**ស៖** តើពួកទ័ពស្រុកជាអ្នកប្រាប់លោក តើមែនដែរឬទេអំពីការសម្លាប់នេះ?

**ឆ៖** បាទ ទ័ពស្រុកគេមិនប្រាប់អីយើងទេ គ្រាន់តែយើងថាក្នុងការរើស្មានមានតែអ៊ីចឹងទេ ដែលសម្លាប់។

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមឲ្យលោកប្រធានមេត្តាបង្គាប់ដល់សាក្សីកុំឲ្យគាត់ធ្វើការប៉ាន់ស្មាន ព្រោះគាត់កំពុងធ្វើការទាយស្មានអំពីការសម្លាប់។ ដូច្នេះហើយគួរតែជម្រាបដល់សាក្សីឲ្យគាត់និយាយតែអ្វីដែលគាត់បានដឹង បានឮ បានឃើញ។ មិនឲ្យនិយាយពីអ្វីដែលគាត់ទាយស្មាននោះទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមឆ្លើយ គឺថាសាក្សីគាត់បានបញ្ជាក់រួចទៅហើយថា គេជាអ្នកប្រាប់គាត់។ ហើយខ្ញុំគ្រាន់តែសួរបន្តទៅទៀតទាក់ទងទៅនឹងអ្វីដែលគាត់បានឮ។ ដូច្នេះហើយវាហាក់ដូចជាឆាប់រហ័សពេក ដែលខាងមេធាវីការពារក្ដីលើកឡើងថា សាក្សីគាត់ធ្វើការទាយស្មាន។ ឥឡូវនេះ ខ្ញុំកំពុងតែសួរសាក្សីអំពីបញ្ហានេះទៅហើយ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីឲ្យខ្ញុំបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយទី១ សូមរំឭកថាសាក្សីជៀសវាងការប្រើពាក្យពេចន៍នូវចម្លើយរបស់លោកថាស្មាន។ លោកមិនអាចឆ្លើយដោយស្មានៗបានទេ។ លោកត្រូវតែឆ្លើយតាមអ្វីដែលជាភារកិច្ចដែលយើងបានប្រាប់លោករួចហើយ ឃើញ ដឹង ឮ ចាំ មានបទពិសោធន៍ បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួរ។ បាទនេះជាករណីយកិច្ចក្នុងនាមជាសាក្សីដែលផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ពុំដូច្នេះទេ អ្វីដែលជាចម្លើយហ្នឹងវាមិនមានតម្លៃនោះទេនៅក្នុងនីតិវិធីតុលាការនោះ។

[១០:៣១:១៥]

ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី រួមទាំងមេធាវីប្រឹក្សាសាក្សីផង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១នាទី ដល់ម៉ោង ១០:៥៣នាទី)*

[១០:៥៣:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ឥឡូវនេះយើងបន្តទៅលើបញ្ហាដែលយើងបានពិភាក្សាគ្នាមុនពេលឈប់សម្រាក។ តើលោកអាចជម្រាបដែរឬទេ? ព្រោះថា លោកបានបញ្ជាក់ថា ក្រោយមកលោកបានដឹងអំពីឧបករណ៍ដែលគេប្រើដើម្បីសម្លាប់មនុស្ស។ តើលោកបញ្ជាក់ប្រាប់បានទេថា មានគេប្រាប់លោកថាគេប្រើដំបងឈើ គល់ឫស្សី ឬក៏ភ្លៅរទេះ។ ថាតើអ្នកណាជាអ្នកប្រាប់លោកអំពីបញ្ហានេះ?

[១០:៥៤:១៦]

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ គេមិនបានប្រាប់ខ្ញុំទេ ប៉ុន្តែគ្រាន់តែថា ខ្ញុំបាន -- មានអ្វីហួសថាពីធ្វើអ៊ីចឹងទេ។

**ស៖** តើលោកបានមើលឃើញដំបងផ្លូវរទេះ ឬក៏គល់ឫស្សីដែលគេទុកនៅកន្លែងសម្លាប់មនុស្សហ្នឹងដែរឬទេ? តើលោកឃើញមាននៅកន្លែងហ្នឹងដែរឬទេ ឧបករណ៍ទាំងអស់នេះ?

**ឆ៖** បាទ ខ្ញុំមិនបានឃើញទេ។ បាទខ្ញុំមិនបានឃើញ ពិត។

**ស៖** ឥឡូវនេះ ខ្ញុំសូមអាននូវចម្លើយរបស់លោកដែលលោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត គឺD125/68 ដែលឯកសារខ្មែរមានលេខ 00201485, ភាសាអង់គ្លេសមានលេខ 00274647 និងភាសាបារាំងមានលេខ 00338365។ នៅក្នុងកិច្ចសម្ភាសន៍នោះ លោកបានបញ្ជាក់ដូចតទៅនេះ៖ “ការសម្រេចចិត្ត គឺគេយកទៅក្បែរកន្លែងមនុស្សនោះតែម្តង។ នៅពេលដែលមនុស្សទៅដល់កន្លែងជួបជុំគ្នា ពួកគេត្រូវបានបែងចែកជាក្រុមតូចៗ ក្នុងមួយក្រុមៗមានមនុស្សប្រមាណ១០នាក់។ ពួកគេត្រូវបានគេប្រាប់ថា យើងនឹងនាំពួកអ្នកទៅជួបអង្គការ តែមុនទៅយើងសូមចងមុខនិងចងដៃពួកអ្នកទាំងអស់គ្នា”។ ហើយសំណួរបន្ទាប់គេបានសួរលោកដូចតទៅនេះ៖ “សូមលោករៀបរាប់អំពីវិធីសម្លាប់មនុស្ស? អ្នកសម្លាប់បានទៅរង់ចាំសម្លាប់នៅនឹងទីកន្លែងជាមុនស្រេច។ ពេលដែលអ្នកនាំមនុស្សដែលត្រូវសម្លាប់ដោយចងមុខ និងចងដៃ ទៅដល់រណ្តៅត្រូវបានគេជីកទុកមុនជាស្រេច។

អ្នកសម្លាប់បានប្រាប់មនុស្សដែលត្រូវសម្លាប់ឲ្យអង្គុយចុះ នៅក្បែរនឹងមាត់របណ្ដៅ។ ពេលនោះ អ្នកសម្លាប់បានប្រាប់អ្នកដែលត្រូវសម្លាប់ថា សូមស្ដាប់សេចក្ដីប្រកាសរបស់អង្គការ”។

លោកបានបញ្ជាក់នៅក្នុងចម្លើយរបស់លោកថា៖ “ជនភៀសខ្លួន ជនជម្លៀសហ្នឹង ត្រូវបានគេប្រាប់ថាឲ្យទៅជួបអង្គការ”។ ថាតើអ្នកណាជាអ្នកប្រាប់មនុស្សទាំងអស់នុ៎ង ថានាំពួកគាត់ហ្នឹងទៅជួបអង្គការ?

[១០:៥៧:១១]

**ឆ៖** បាទ មានតែប្រធានភូមិទេ ដែលប្រាប់ទៅឲ្យជួបនៅអង្គការហ្នឹង។

**ស៖** ដូច្នេះ ដើម្បីបញ្ជាក់ឲ្យច្បាស់ គឺថាប្រធានភូមិ គឺជាអ្នកប្រាប់ប្រជាជនទាំង២០នាក់នុ៎ង។ គឺមនុស្ស២០នាក់ដែលលោកនាំទៅ ទៅក្បែរភូមិច្រកសង្កែហ្នឹង គឺមេភូមិជាអ្នកប្រាប់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដហើយ។

**ស៖** នៅក្នុងចម្លើយដែលខ្ញុំទើបតែអានហ្នឹង លោកក៏បានបញ្ជាក់ផងដែរថា៖ “នៅពេលគេយកមនុស្សទៅនោះ គេយកទៅសម្លាប់នោះ គឺគេប្រាប់ថាឲ្យស្ដាប់សេចក្ដីប្រកាសរបស់អង្គការ”។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកអាចស្ដាប់ឮអ្វីៗវាកើតឡើងចំពោះមនុស្ស១០នាក់ដែលគេចង ហើយបណ្ដើរចេញទៅហ្នឹង។ តើលោកអាចស្ដាប់ឮហេតុការណ៍ដែលកើតឡើងនៅពេលដែលគេបណ្ដើរគាត់យកទៅហ្នឹង តើលោកអាចស្ដាប់ឮ -- តើលោកនៅអាចស្ដាប់បានឮដែរឬទេ?

**ឆ៖** បាទ បាន -- ខ្ញុំនៅឆ្ងាយដែរ នៅប្រហែលជា៣០ម៉ែត្រ ឮសូរល្វើយៗ ថាគេរាប់ មួយ ពីរ បី ឮតែប៉ុណ្ណឹង។ ព្រោះខ្ញុំដើរចេញមក លែងដឹងថាម៉េចទៀតទៅ។

[១០:៥៩:២១]

**ស៖** នៅក្នុងចម្លើយដដែលដែលខ្ញុំទើបតែអានហ្នឹង លោកក៏បានឆ្លើយផងដែរថា គឺលោកនិយាយអំពីរណ្ដៅដែលត្រូវបានគេជីកទុកមុនជាស្រេច។ ដូច្នេះ ខ្ញុំចង់ដឹងថាហេតុអ្វីបានលោកដឹងថារណ្ដៅហ្នឹងត្រូវបានគេជីកទុកមុនជាស្រេច?

**ឆ៖** ត្រង់នេះ ខ្ញុំសូមមិនឆ្លើយទៅចុះ។

**ប្រធានអង្គជំនុំ៖**

កុំអាល! អញ្ជើញលោកមេធាវី យ៉ាងម៉េចទៅ?

**លោក ម៉ម រិទ្ធា៖**

សូមគោរពលោកប្រធាន។ លោក លោកស្រីចៅក្រម អម្បាញ់មិញនេះសាក្សីគាត់បានឆ្លើយតបថា សូមអត់ឆ្លើយ។

**ប្រធានអង្គជំនុំ៖**

សាក្សី សំណួរអម្បាញ់មិញនេះមិនមានជាប្រភេទសំណួរដាក់បន្ទុកទៅលើខ្លួនលោកទេ។ សួរថាហេតុអ្វីបានជាលោកដឹង ដែលលោកបានឆ្លើយរួចហើយប៉ុណ្ណោះ ហើយករណីយកិច្ចក្នុងនាមលោកជាសាក្សី យើងបានប្រាប់ហើយឆ្លើយតបទៅនឹងសំណួរ លើកលែងតែសំណួរឯណាដែលដាក់បន្ទុកលើកខ្លួនឯង។ លោកមេធាវី សូមរៀបចំនៅការតាមដាននូវសំណួរ ហើយឲ្យបានស៊ីជម្រៅ ហើយនិងដឹងច្បាស់លាស់អំពីសំណួរអ្វីដែលថាដាក់បន្ទុកលើកខ្លួនឯង។ សំណួរពីការដឹងនេះមិនមែនជាសំណួរប្រភេទសំណួរដាក់បន្ទុកលើខ្លួនឯងទេ។ សូមសាក្សីឆ្លើយតបទៅនឹងសំណួរនេះ!

[១១:០១:១៦]

**លោក ឡេវ ឡាំ៖**

**ឆ៖** ខ្ញុំសូមឆ្លើយថា មិនដឹង ព្រោះខ្ញុំមិនបានឃើញរណ្តៅនោះផង។ បានថាខ្ញុំមិនដឹងហ្នឹង។ បានខ្ញុំមិនឆ្លើយ។

**ស៖** សូមអរគុណលោកសាក្សីដែលបានបញ្ជាក់បំភ្លឺទៅលើចំណុចនេះ។ តើលោកចំណាយពេលប្រហែលជាប៉ុន្មាននាទី ប៉ុន្មានម៉ោងដែរនៅកន្លែងសម្លាប់មនុស្សនោះ មុនពេលដែលលោកត្រឡប់មកភូមិច្រកសង្កែវិញ?

**ឆ៖** បាទ ខ្ញុំមិនបាននៅយូរទេ ប្រហែលជាមិនបានប្រាំដណ្តប់នាទី ខ្ញុំគេចមកវិញ។

**ស៖** លោកបានប្រាប់យើងថា ក្នុងក្រុមមនុស្ស២០នាក់ហ្នឹង គឺថាមេភូមិហើយនិងលោក គឺនាំទៅកន្លែងសម្លាប់មនុស្ស ហើយលោកឃើញថាមនុស្ស១០នាក់ត្រូវបានគេចង ហើយយកទៅចេញទៅ។ ចំណែក១០នាក់ទៀតគេអត់ចងទេ។ តើមនុស្ស១០នាក់ ដែលគេអត់ចងហ្នឹង គេត្រឡប់មកវិញជាមួយលោក នៅពេលដែលលោកត្រឡប់មកវិញវិញ ឬមួយក៏យ៉ាងណា?

[១១:០២:៤៥]

**ឆ៖** បាទ អ្នកដែលអត់ចងហ្នឹង គឺក៏អត់បានមកវិញដែរ គឺគេយកទៅទាំងអស់។

**ស៖** តើក្នុងចំណោម១០នាក់ ដែលគេអត់ចងដែរហ្នឹង មានក្មេងៗប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** ក្មេងៗប្រហែលជាប្រាំប្រាំមួយនាក់ ខ្ញុំឃើញ។

**ស៖** តើលោកអាចធ្វើការប៉ាន់ប្រមាណអំពីចំនួនមនុស្សដែលត្រូវបានគេសម្លាប់ជារួម សម្លាប់ទាំងអស់នៅទីតាំងសម្លាប់មនុស្សហ្នឹង តើមានមនុស្សប្រហែលប៉ុន្មាននាក់ដែរជារួម?

**ឆ៖** បាទ ប្រហែលជារួម ជាសម្លាប់ច្រើនដែរ ប្រហែលជាចាប់ពី ៧០ ទៅ៨០នាក់ហ្នឹង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមលោកប្រធានមេត្តាបង្គាប់ទៅដល់សាក្សីកុំឱ្យគាត់ទាយស្មានព្រោះថាគាត់អត់ដឹង។ ដូច្នេះ គាត់មិនគួរហ្នឹងទាយស្មានថាមានប្រហែលជា៥០-៦០, ៧០នាក់ បែបនេះទេ។

[១១:០៤:៤៤]

**សួរដោយលោក ឌែល លីសាក់៖**

លោកប្រធាន ខ្ញុំសូមបន្តសួរសំណួរដើម្បីរកឱ្យឃើញនៅមូលដ្ឋានដែលសាក្សីគាត់បានឆ្លើយនេះ ហើយខ្ញុំគិតថាវាជាការមិនសមស្របទេ ដែលមេធាវីការពារក្តីគាត់ឡើងជំទាស់ ដូចជាឆាប់ពេក។ ដូច្នេះ ខ្ញុំសូមសួរបន្តដើម្បីបង្កើតជាមូលដ្ឋានទៅលើចម្លើយរបស់សាក្សីនេះ។

**ស៖** លោកសាក្សីនៅក្នុងកិច្ចសម្ភាសន៍របស់លោក លោកបាន និយាយថាមានការប៉ាន់ស្មានថានៅទីតាំងសម្លាប់មនុស្សនោះ គឺរណ្តៅកប់សពក្រោយឆ្នាំ៧៩ តើលោកប្រាប់បានដែរឬទេអំពីការគាស់រណ្តៅសាកសពក្រោយឆ្នាំ៧៩នោះ? តើវាមានអ្វីកើតឡើងនៅពេលដែលគេគាស់រណ្តៅសាកសពនៅក្រោយឆ្នាំ៧៩នោះ?

**ឆ៖** បាទ គឺខ្ញុំបានទៅ ដើរទៅបណ្តើរវ័ន្តេ ឃើញរណ្តៅខ្មោចគេគាស់រកមាសនៅអាហ្នឹងខាងលិចគុកដំរីស្រុតទេ គេហៅថាព្រៃទទឹង។ ខ្ញុំដើរទៅបណ្តើរវ័ន្តេទៅឃើញក្បាលខ្មោច ឃើញអីនៅជីកចោលគរពេញហ្នឹង។ អាន៎ុងខាងលិចគុកដំរីស្រុត អាហ្នឹងគេហៅថាព្រៃទទឹង។

**ស៖** ដើម្បីបញ្ជាក់ឱ្យបានច្បាស់ ថាតើកន្លែងដែលគេគាស់រណ្តៅហ្នឹងវាដូចគ្នាហ្នឹងកន្លែងដែលគេនាំដែលលោកនាំមនុស្ស ២០នាក់ហ្នឹងទៅ ឬមួយក៏វាជាកន្លែងផ្សេងគ្នា?

[១១:០៦:៥៦]

**ធ៖** បាទ អាកន្លែងខ្ញុំនាំហ្នឹង គឺខ្ញុំអត់បានឃើញរណ្ដៅទេ។ ប៉ុន្តែក្រោយពីឆ្នាំ៨១, ៨២ ហ្នឹងគឺខ្ញុំដើរបណ្ដើរវន្តែហ្នឹងឃើញរណ្ដៅគេជីក។ ខ្ញុំសួររណ្ដៅគេជីស្អីហ្នឹង? គេជីករកមាស បាទ ជីករកមាសអីចឹងបានជាឃើញក្បាលខ្មោចគរគោកដីអីចឹង។

**ស៖** ឥឡូវនេះខ្ញុំនឹងអាននូវចម្លើយរបស់លោកដែលលោកបានឆ្លើយ គឺឯកសារ D125/68។ គឺឯកសារខ្មែរមានលេខ 00201484, ភាសាអង់គ្លេស មានលេខ 00274646, ភាសាបារាំង មានលេខ 00338364 ហើយក្នុងការសម្ភាសនោះលោកបានឆ្លើយដូចតទៅនេះ "បន្ទាប់ពី -- ក្រោយឆ្នាំ១៩៧៩ ប្រជាជនមកគាស់រណ្ដៅសាកសពនៅទីនេះដើម្បីស្វែងរកមាសនិងវត្ថុមានតម្លៃផ្សេងៗ។ សំណួរ៖ សូមលោកបញ្ជាក់អំពីការគាស់រណ្ដៅសាកសពរួមនេះ? ឆ្លើយ៖ នៅពេលនោះប្រជាជនបានគាស់រណ្ដៅប្រមាណ ២០ ទៅ ៣០ រណ្ដៅដែលរួមទាំងអស់មានសាកសពប្រមាណពី ៧០០ ទៅ ៨០០ សាកសព។ នៅមានរណ្ដៅមួយចំនួនទៀតដែលមិនទាន់ត្រូវបានគាស់ទេ។ ដូច្នេះយើងមិនអាចដឹងចំនួនមនុស្សទាំងអស់ដែលត្រូវបានសម្លាប់នៅទីនេះទេ"។

អ្វីដែលខ្ញុំចង់សួរលោកគឺថា លោកបានប្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលលោកធ្វើការប៉ាន់ថាប្រហែលជាមាន៧០០ ទៅ ៨០០សាកសព ដែលគេកប់នៅរណ្ដៅសាកសពរួម។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកផ្អែកទៅលើអ្វីទើបលោកអាចប៉ាន់ប្រមាណថាមានប្រហែល ៧០០ ទៅ ៨០០សាកសពនេះ?

[១១:០៩:២៥]

**ធ៖** បាទ ខ្ញុំបានទៅឃើញក្នុងរណ្ដៅហ្នឹង រណ្ដៅមួយៗក្បាលជាង ២០នាក់ជាង មាន ៣០នាក់ជាងក្បាល ក្បាលខ្មោចហ្នឹង។ ហើយរណ្ដៅដែលមិនទាន់ជីកហ្នឹងក៏ឃើញនៅ ផតនៅច្រើននៅឡើយ គេមិនទាន់ជីកអស់។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ គឺថាលោកបាននិយាយថា ឃើញក្បាលខ្មោចប្រហែលជា ២០ ទៅ ៣០ក្បាលនៅក្នុងរណ្ដៅដែលគេជីកមួយៗ។ តើលោកអាចប្រាប់បានដែរឬទេថា លោកឃើញមានរណ្ដៅប្រហែលជាប៉ុន្មានដែរនៅកន្លែងនោះ?

**ធ៖** បាទ ខ្ញុំឃើញប្រហែលជា ២០រណ្ដៅៗ។

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក។ ឥឡូវនេះ ខ្ញុំសូមលើកយកនូវប្រធានបទផ្សេងបន្តទៀតមុននឹងខ្ញុំបញ្ចប់ការសាកសួររបស់ខ្ញុំ។ ក្នុងនេះ គឺលោកបានបញ្ជាក់អំពីបុគ្គលម្នាក់ដែលជា

ប្រធានឃុំស្វាយជុក ឈ្មោះ ណាន។ តើលោកដឹងដែរឬទេថា ណាន ហ្នឹងគឺជាបងប្អូនរបស់ នួន ជា?

**ឆ៖** បាទ ណាន ហ្នឹងខ្ញុំមិនដឹងទេរឿងបងប្អូនគេនៅត្រង់ណា នៅភូមិខុសគ្នាដែរ។

**ស៖** តើលោកដឹងដែរឬទេថា នួន ជា មានសាច់ញាតិរស់នៅក្នុងឃុំពាម?

**ឆ៖** បាទខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកពីរបីសំណួរពាក់ព័ន្ធទៅនឹងចម្លើយដទៃទៀតដែលបានផ្ដល់ឲ្យក្នុងនាមជាសាក្សីពាក់ព័ន្ធទៅនឹងការសម្លាប់នៅក្នុងស្រុកកំពង់ត្រឡាចលើ។

[១១:១២:០៩]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីផ្ដល់នូវសាក្សីនេះនូវកិច្ចសម្ភាសន៍។ ឯកសារដែលមានលេខ D125/93 ។ ហើយនិងឯកសារមួយទៀត D232/40។ ហើយខ្ញុំនឹងមិនអានឈ្មោះរបស់សាក្សីនេះទេ ហើយខ្ញុំក៏សូមអនុញ្ញាតលោកប្រធានមេត្តាបង្គាប់ដល់សាក្សីកុំឲ្យអានឈ្មោះសាក្សីនៅក្នុងឯកសារទាំងពីរដែលខ្ញុំបានផ្ដល់នេះ។ សូមលោកប្រធានអនុញ្ញាតដើម្បីខ្ញុំអាចប្រគល់ឯកសារនេះជូនដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។ ហើយសាក្សីសូមកុំអានរួច កុំបញ្ចេញឈ្មោះអ្នកដែលមាននៅក្នុងកំណត់ហេតុនោះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរទី១របស់ខ្ញុំដែលចង់សួរលោក ហើយសង្ឃឹមថាមេធាវីអាចជួយលោកបាន។ សូមលោកមើលឈ្មោះរបស់សាក្សីទាំងពីររូបនេះដែលបានផ្ដល់ចម្លើយ ហើយលោកមិនចាំបាច់បញ្ចោញពីឈ្មោះនោះទេ ប៉ុន្តែលោកសូមប្រាប់យើងខ្ញុំថា តើលោកស្គាល់មនុស្សទាំងពីរនាក់នេះដែរឬទេ?

**ឆ៖** បាទ ឈ្មោះនេះ ខ្ញុំអត់ដែលស្គាល់ទេ។ អត់ស្គាល់ទាំងពីរ។

[១១:១៤:៤៨]

**ស៖** លោកសាក្សីនៅក្នុងឯកសារ D125/93 ហើយខ្ញុំចង់និយាយពីទំព័រ 00212084 ដល់ 85 ភាសាអង់គ្លេសមានលេខ 00275128 ដល់ 29 និងភាសាបារាំងមានលេខ 00293909 ដល់ 11។ សាក្សីរូបនេះបានរៀបរាប់អំពីកម្មាភិបាលស្ត្រីពីររូបមកពីស្វាយជុក គឺ យាយណាន – គឺមនុស្សតែមួយ

ដែលលោកបាននិយាយ – ហើយនិងកម្មាភិបាលស្ត្រីម្នាក់ទៀតឈ្មោះ យាយ ភុន ដែលកម្មាភិបាលទាំងពីររូបនេះគាត់បានធ្វើការប្រជុំនៅភូមិថ្នាយខ្មែរ ដែលនិយាយអំពីការប្រជុំទាក់ទងទៅនឹងគ្រួសារប្រជាជន១៧មេសា ចំនួន៣០គ្រួសារដែលត្រូវគេយកទៅសម្លាប់នៅខាងជើងភូមិថ្នាយខ្មែរ ឈ្មោះ ភូមិព្រៃស្រេវ៉ាល់ ហើយចម្លើយដែលខ្ញុំផ្តល់ជូនលោកមួយទៀតគឺ D232/40 គឺជាចម្លើយរបស់មេក្រុមភូមិថ្នាយខ្មែរ ដែលបានបញ្ជាក់ផងដែរអំពីការសម្លាប់ប្រជាជនដែលទើបជម្លៀសមកនៅទីតាំងព្រៃស្រេវ៉ាល់។

[១១:១៦:៤៣]

ដូច្នេះអ្វីដែលខ្ញុំចង់សួរលោកនៅពេលនេះគឺថា តើលោកស្គាល់ទីតាំងដែលខ្ញុំលើកឡើងនេះដែរឬទេ គឺភូមិៗស្រែ -- ថ្នាយខ្មែរ និងភូមិព្រៃស្រេវ៉ាល់នោះដែរឬទេ? តើលោកដឹងអំពីការសម្លាប់មនុស្សនៅទីតាំងទាំងពីរនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ ប៉ុន្តែភូមិថ្មីខ្មែរ ខ្ញុំធ្លាប់ -- ខ្ញុំស្គាល់ ហើយភូមិស្រេវ៉ាល់ហ្នឹងអត់ស្គាល់។ មានតែស្វាយផ្អែម។ បើថាភូមិស្វាយផ្អែមគឺភូមិចាម អាហ្នឹងស្គាល់។

**សៈ** តើភូមិមួយទៀតដែលលោកស្គាល់ហ្នឹងឈ្មោះអីដែរ ខ្ញុំស្តាប់អត់ទាន់អំមិញ?

**ឆ៖** បាទ ស្គាល់ភូមិៗចាម គឺ ភូមិហៅថា "ភូមិស្វាយផ្អែម" ភូមិចាមទេអាហ្នឹងជនជាតិចាម។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់នូវឯកសារចំនួនពីរទៀតជូនទៅដល់សាក្សី គឺ ឯកសារ D232/42 ៗ និង D232/63។ សូមលោកប្រធានអនុញ្ញាតដើម្បីឲ្យខ្ញុំអាចប្រគល់ឯកសារនេះជូនទៅដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១១:១៩:០២]

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** លោកសាក្សី មុនពេលដែលលោកចាប់ផ្តើមមើលឯកសារនេះ ពាក់ព័ន្ធទៅនឹងភូមិថ្មីខ្មែរ តើភូមិថ្មីខ្មែរហ្នឹងស្ថិតនៅក្នុងឃុំស្វាយជុក ឬក៏ស្ថិតនៅឃុំផ្សេងទេ?

**លោក ឡេវ ឡាំ៖**

**ឆ៖** ភូមិថ្មីខ្មែរនេះនៅក្នុងភូមិស្វាយជុក នៅក្នុងឃុំស្វាយជុកខាងត្បូង។ គេចែកឃុំស្វាយជុកជាពីរផ្នែក មួយស្វាយជុកខាងជើង មួយស្វាយជុកខាងត្បូង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះសូមលោកពិនិត្យមើលទៅលើឯកសារទាំងពីរដែលខ្ញុំទើបតែប្រគល់ជូនលោក ហើយលោកមិនចាំបាច់បញ្ជាក់ មិនបាច់និយាយអំពីឈ្មោះមនុស្សនេះទេ។ តើលោកអាចប្រាប់ខ្ញុំទេ ថាតើលោកស្គាល់មនុស្សទាំងពីរនាក់ហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ អត់ស្គាល់។

[១១:២០:២០]

**ស៖** នៅក្នុងចម្លើយទាំងពីរនេះ គឺបុគ្គលទាំងពីរនាក់នេះ គឺគាត់មកពីភូមិត្បែងខ្ពស់ គឺសាក្សីនេះគាត់បាននិយាយអំពីការមកដល់របស់អ្នកជម្លៀស១៧ មេសា មកពីទីក្រុងភ្នំពេញ រួមទាំងមន្ត្រីរដ្ឋការលន់ នល់ និងទាហានលន់ នល់ ដែលពួកគាត់ហ្នឹងត្រូវបានគេទុកនៅវត្តត្បែងខ្ពស់ ហើយបន្ទាប់មកទៀតគេយកទៅសម្លាប់នៅទីតាំងបីកន្លែង។ ប្រសិនបើលោកមើលទៅចម្លើយទី៦ នៅក្នុងការសម្ភាស D232/42នោះ មានទីតាំងសម្លាប់មនុស្សចំនួនបីដែលគាត់បានបញ្ជាក់។ គឺសាក្សីហ្នឹងគាត់បានបញ្ជាក់ចំនួនបីកន្លែង។ ទី១ គឺកុករនាម, ទី២ គឺត្រពាំងអណ្តូង និងទី៣ គឺត្រពាំងខ្លុង។ ខ្ញុំចង់សួរលោកថាតើលោកស្គាល់ទីតាំងទាំងបីកន្លែងនេះដែរឬទេ? ហើយនៅក្នុងអំឡុងឆ្នាំ៧៥ តើលោកធ្លាប់ឮអំពីការសម្លាប់មនុស្សនៅទីតាំងទាំងបីកន្លែងនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ ដឹងតែនៅខាងភូមិខ្ញុំនេះទេ ដល់ភូមិគេផ្សេងទៀត មិនបានដឹងទេ។

**ស៖** តើនៅក្នុងស្រុកកំពង់ត្រឡាចលើ មានឃុំឈ្មោះត្បែងខ្ពស់ហ្នឹងដែរឬទេ?

**ឆ៖** បាទ មានឃុំត្បែងខ្ពស់។ វត្តត្បែងខ្ពស់ហ្នឹងតែម្តង ឃុំត្បែង វត្តត្បែងខ្ពស់។

**ស៖** តើភូមិហ្នឹង -- ឃុំហ្នឹងធៀបនឹងជាមួយនឹងឃុំស្វាយជុកហ្នឹងនៅមានចម្ងាយពីគ្នា ឬក៏ជិតពីគ្នាយ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ នៅឆ្ងាយពីគ្នាប្រហែលជា២គីឡូ បើផ្លូវថ្នល់រទេះភ្លើង គឺត្បែងខ្ពង់ ឃុំត្បែងខ្ពស់ខាងលិចថ្នល់រទេះភ្លើង គឺខាងឃុំស្វាយជុក។ ប៉ុន្តែភូមិដាច់គ្នាប្រហែលជា២គីឡូពីគ្នា ពីឃុំមួយទៅឃុំមួយ។

[១១:២៣:២៦]

**ស៖** សូមអរគុណ។ ចំណុចចុងក្រោយដែលខ្ញុំចង់សួរលោកអំពីប្រធានបទមួយនៅក្នុងឯកសារ គឺថា E3/135។ នេះគឺឯកសារបោះពុម្ពផ្សាយទង់បដិវត្ត គឺឆ្នាំ១៩៧៦ គឺនិយាយអំពីកំពង់ត្រឡាចលើ ស្រុកកំពង់ត្រឡាចលើ ត្រូវបានគណៈមជ្ឈិមជ្រើសគំរូនៅក្នុងប្រទេសចាប់ពីឆ្នាំ១៩៧៦ ហើយគេផ្ដល់ទង់កិត្តិយស ទង់ក្រហមរបស់បក្សនោះ។ ខ្ញុំចង់សួរលោកថា តើលោកធ្លាប់ឮទេថាគេប្រកាសឲ្យទៅប្រជាជននៅក្នុងស្រុកស្ដាប់ បានឮទេនៅក្នុងពេលនោះ ថាតើស្រុកកំពង់ត្រឡាចលើហ្នឹងគឺត្រូវបានគេចាត់ទុកជាស្រុកគំរូ ហើយទទួលបានទង់ក្រហម កិត្តិយសផងដែរ នៅក្នុងឆ្នាំ១៩៧៦?

**ឆ៖** បាទ ខ្ញុំមិនសូវបានដឹងទេ ព្រោះអីវាមិនដែរ មិនគិតអារឿងអ៊ីចឹងទេ។ អត់បានដឹងទេ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំគឺថា តើនៅពេលណាមួយនៅចន្លោះខែមេសា ឆ្នាំ១៩៧៥ រហូតមកដល់ខែមករា ឆ្នាំ១៩៧៩ តើលោកបានដឹងថាតើមេដឹកនាំខ្មែរក្រហមធ្លាប់បានទៅធ្វើទស្សនកិច្ចនៅស្រុករបស់លោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដែលដឹងទេ។

[១១:២៥:៤៥]

**លោក ខេល លីសាក់៖**

សហព្រះរាជអាជ្ញាជាតិនឹងមានសំណួរមួយចំនួនត្រូវសួរលោក ហើយខ្ញុំសូមអរគុណអង្គជំនុំជម្រះ ហើយនិងលោកសាក្សីបាទ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនតូចទេចង់សួរលោកបញ្ជាក់បន្ថែម។ កាលពីព្រឹកមិញនេះ លោកបានជម្រាបជូនអង្គសវនាការថា លោកបានចូលរួមក្នុងកិច្ចប្រជុំមួយដែលដឹកនាំដោយឈ្មោះ ស្រ៊ន និងឈ្មោះ ណាន នៅមន្ទីរកងឈ្លប ហើយក្នុងច្រកសង្កែ។ ហើយលោកក៏បានឮ ស្រ៊ន បានដាក់ចេញនូវសេចក្ដីសម្រេចដើម្បីជ្រើសរើសយកទាហាន លន់ នល់ ដែលៗគេជម្លៀសមកហ្នឹង គឺយកទៅសម្លាប់។ សំណួររបស់ខ្ញុំចង់ដឹងថា តើលោកបានដឹងដោយវិធីណាដែលទេថាសេចក្ដីសម្រេចដែល ស្រ៊ន បានដាច់ចេញនេះ។ គាត់ដាក់ចេញដោយខ្លួនឯង ឬក៏មានថ្នាក់ដឹកនាំណាផ្សេងទៀតបញ្ជាមក ស្រ៊ន ឲ្យអនុវត្តតាម?

**លោក ឡេវ ឡាំ៖**

**ឆ៖** ខ្ញុំបានដឹងថា ឮ ស្រ៊ន ហ្នឹងគាត់ ខ្ញុំនៅក្បែរនុំង បានឮសួរ ស្រ៊ន និយាយ។ អ៊ីចឹងបានថា ខ្ញុំវាដល់ទៅសម្ភាស ខ្ញុំថាឮសូរសំឡេងគាត់ថាអ៊ីចឹង បានខ្ញុំដាក់អ៊ីចឹងមក។

[១១:២៧:២០]

**ស៖** បាទ អរគុណលោកសាក្សី។ សំណួរខ្ញុំគឺចង់ដឹងអ៊ីចេះ។ ក្រៅពីលោកបានដឹងហ្នឹង តើលោកបានដឹងដោយវិធីណាផ្សេងទៀតទេ។ ឧទាហរណ៍ថាមានអ្នកណាប្រាប់ផ្សេង ថាសេចក្ដីសម្រេចនេះ មានថ្នាក់លើណាផ្សេងទៀត ជាអ្នកបញ្ជាមកឲ្យ ស្រ៊ន ធ្វើអ៊ីចឹង ឬក៏លោកអត់បានដឹងទេ?

**ឆ៖** ខ្ញុំបាទអត់បានដឹងទេ ព្រោះគ្រាន់តែថា ស្រ៊ន ហ្នឹងជា-- ព្រោះអត់មានឃើញពីណា ថ្នាក់លើពីណាមកទៀត មានតែ ស្រ៊ន ហ្នឹងហើយដែលអាចសម្រេចចិត្ត។ មានតែប៉ុណ្ណឹង។

**ស៖** បាទអរគុណ។ លោកក៏បានជម្រាបជូនអង្គសវនាការដែរថា ស្រ៊ន គាត់ជាគណៈស្រុក។ ចុះលោកដឹងទេថា លេខាតំបន់ ឬក៏លេខាភូមិភាគជាអ្នកណាដែរ លោកស្គាល់ទេ?

**ឆ៖** ខ្ញុំបាទ ខ្ញុំបានតែឮតែឈ្មោះទេ ខ្ញុំមិនបានដែលឃើញទេបាទ គណៈតំបន់ៗ ឬគណៈស្រុកគណៈតំបន់។ ត្រឹមគណៈតំបន់គេហៅថា តាសារុនៗ ហ្នឹង មិនដែលបានជួបមុខ តាសារុន ហ្នឹងម៉េចផង។

[១១:២៨:៥៥]

**ស៖** ចុះក្រៅពី តាសារុន តើលោកបានដឹង ឬក៏ឮថាមានអ្នកណាផ្សេងទៀតទេ ដែលនៅក្នុងគណៈតំបន់ ឬក៏ថ្នាក់លើផ្សេងទៀតដែលនៅជាគណៈភូមិភាគ? តើលោកស្គាល់ដែរទេ? ស្គាល់ឈ្មោះ ឬក៏ឮឈ្មោះដែរទេ?

**ឆ៖** បាទ គណៈភូមិភាគភាគហ្នឹង ខ្ញុំអត់ដែលឮសូរផង អត់ដែលស្គាល់ អត់ដែលឮសូរឈ្មោះថាឈ្មោះណាគណៈភូមិភាគទេ ស្គាល់តែតាសារុនៗ ហ្នឹងក៏មិនដែលឃើញមុខគាត់ផង ឮថា តាសារុនហ្នឹងគណៈតំបន់ តែប៉ុណ្ណឹងបាទ។ អរគុណ។

**ស៖** បាទ អរគុណ។ ទាក់ទងនឹងកិច្ចប្រជុំដែលខ្ញុំបានសួរលោកអម្បាញ់មិញ ដែលលោកបានឮថា -- ដែល ស្រ៊ន និង ណាន បានដឹកនាំប្រជុំនោះ។ តើលោកនៅចាំទេថាកិច្ចប្រជុំហ្នឹងគេធ្វើឡើងបន្ទាប់ពីការមកដល់របស់អ្នកជម្លៀស ឬក៏ធ្វើឡើងមុនពេលការមកដល់របស់អ្នកទាំងនោះ?

**ឆ៖** បាទ ខ្ញុំដឹងថា គាត់ហ្នឹងវាអ្នក១៧ មកហើយទេ បានគេធ្វើ។

**ស៖** បាទ អរគុណ។ ចុះលោកមានដឹងទេថា មុនពេលដែលអ្នកជម្លៀសត្រូវបានគេបញ្ជូនមកដល់ហ្នឹង មានបានធ្វើជាកិច្ចប្រជុំអីដើម្បីត្រៀមរៀបចំថា តើត្រូវចាត់ចែងយ៉ាងណាចំពោះអ្នកដែលជម្លៀស ដែលនឹងមកដល់ហ្នឹងដែរឬទេ? មានទេ?

**ឆ៖** បាទ ៗត្រង់ហ្នឹង គឺខ្ញុំអត់ដឹងទេ។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀតដែរ គឺលោកបានជម្រាបជូនអ្នកស៊ើបអង្កេតថា នៅក្នុងឯកសារ D125/66 ហ្នឹងលោកបានជម្រាបថា៖ "ប្រជាជនភ្នំពេញត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ហើយមួយចំនួនត្រូវបានបង្ខំឲ្យមកកាន់ទីនេះ ដែលមួយចំនួនត្រូវបានសម្លាប់នៅទីនេះ"។ ដើម្បីប្រតិចារឹកឯកសារហ្នឹង គឺមាននៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00201484, ជាភាសាអង់គ្លេសគឺ 00274646, ជាភាសាបារាំងគឺ 00338363។

[១១:៣២:០៣]

សំណួររបស់ខ្ញុំ គឺអ៊ីចេះថា តើលោកដឹងដោយរបៀបណាដែរទេ ដែលថាប្រជាជនទីក្រុងភ្នំពេញត្រូវបានគេបង្ខំឲ្យចេញពីទីក្រុង ឬក៏លោកបានទទួលព័ត៌មានអ្វីខ្លះទាក់ទងទៅនឹងបញ្ហានេះនៅកន្លែងលោកដែរ?

**ឆ៖** បាទ ត្រង់ហ្នឹង ខ្ញុំជម្រាបថា ឃើញតែអ្នកជម្លៀសចេញមកពីភ្នំពេញ ចេញមកពីកំពង់ឆ្នាំងទេ ប៉ុន្តែមិនដឹងថាគេបង្ខំអី បង្ខិតបង្ខំនៅខាងហ្នឹង នៅខាងនេះហ្នឹង ក៏ខ្ញុំមិនដឹងទេបាទ។ ប៉ុន្តែឃើញថាអ្នក១៧ ទៅដល់ហ្នឹងតែហើយ។

**ស៖** បាទ អរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ គឺលោកបានជម្រាបជូនអង្គសវនាការពីព្រឹកមិញថាបន្ទាប់ពីទទួលសេចក្ដីណែនាំពី ស្រ៊ន, ឈ្មោះ ណាន បានកត់ត្រាប្រវត្តិរូបគំរូរបស់ប្រជាជន១៧ មេសាហ្នឹង គឺជាការរៀបចំដើម្បីសម្លាប់មនុស្ស ហើយលោកបានឆ្លើយថា ភ្លាមៗបន្ទាប់ពីថ្ងៃ១៧ មេសា ខ្ញុំធ្វើជាឈ្លបនៅឡើយ ហើយធ្វើការជាមួយ ណាន។ ឃើញថា ដោយសារតែលោកធ្វើការជាមួយ ណាន ដែលជាគណៈស្រុកស្វាយជុកនៅពេលនោះ តើលោកនៅពេលនោះឈ្មោះ ណាន បានប្រគល់ការងារអ្វីខ្លះឲ្យលោកធ្វើដែរទេ ទាក់ទងទៅនឹងប្រជាជនដែលត្រូវបានគេជម្លៀសមកដល់កន្លែងលោកហ្នឹង?

[១១:៣៣:៤៧]

**ឆ៖** បាទ កាលណោះ ណាន ក៏មិនអាចនេះ-- ប្រើខ្ញុំដែរទេ ព្រោះខ្ញុំនៅជាប់នៅតែនាការ(?) អ៊ីចឹងទេ ខ្ញុំនៅតែមន្ទីរហ្នឹង នៅកន្លែងឡើងត្នោតហ្នឹងទេ អត់មានបាទ។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណ។ ខ្ញុំអស់សំណួរហើយលោកប្រធាន ហើយក៏សូមអរគុណលោកសាក្សីផងដែរ ដែលបានចូលមកក្នុង -- ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ដើម្បីស្វែងរកការពិត និងយុត្តិធម៌បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១១:៣៤:៤៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺលោកស្រី បេនី យេ គាត់ឡើងសួរលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី បេនី យេ៖**

សូមជម្រាបលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។

**ស៖** សូមជម្រាបសួរលោក ឡេវ ឡាំ ខ្ញុំឈ្មោះ បេនីយេ ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសួរសំណួរមួយចំនួនទៅលោកជាបន្ត។ ខ្ញុំចង់ផ្តោតអារម្មណ៍ទៅលើពេលវេលាចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយនិងខែមិថុនា ឆ្នាំ១៩៧៥។ លោកនិយាយថានៅក្នុងពេលនេះ លោកបានឃើញប្រជាជនជម្លៀសនៅកំពង់ឆ្នាំង ចេញពីកំពង់ឆ្នាំង ហើយនៅក្នុងពេលនោះដែរគឺមួយសប្តាហ៍ក្រោយមកក៏ឃើញអ្នកជម្លៀសមកពីភ្នំពេញដែរ។ តើលោកអាចប៉ាន់ប្រមាណថាតើលោកបានឃើញប្រជាជនជម្លៀសប្រហែលចំនួនប៉ុន្មានដែលបានទៅដល់តំបន់ដែល លោករស់នៅពេលនោះ?

**ឆ៖** បាទ ខ្ញុំបានឃើញប្រហែលជាពីរទៅ៣០០គ្រួសារប៉ុណ្ណោះទេ មិនបានឃើញច្រើន ព្រោះអីគេបែងចែកទៅតាមភូមិ មកនៅជ្រកនៅតាមភូមិគេផ្សេងៗទៀត គ្រាន់តែមកភូមិខ្ញុំប្រហែល ៣០០ គ្រួសារប៉ុណ្ណឹង។

[១១:៣៦:១៣]

**ស៖** នៅពេលដែលលោកថាគ្រួសារនោះ តើក្នុងមួយគ្រួសារហ្នឹងមានសមាជិកប្រហែលប៉ុន្មានជាធម្មតានោះ?

**ឆ៖** សមាជិកប្រហែលជាប្រាំទៅប្រាំមួយនាក់ទេ ប៉ុណ្ណឹងទេក្នុងគ្រួសារនីមួយៗមិនមានច្រើនទេ។

**ស៖** នៅពេលដែលប្រជាជនជម្លៀសនោះទៅដល់ តើគេធ្វើដំណើរតាមវិធីណាដែលលោកឃើញថាទៅដល់នោះ?

**ឆ៖** បាទ ខ្លះឃើញគេរុញរទេះ ខ្លះឃើញដើរ ភាគច្រើនឃើញដើររែក កន្ទេល រែកចាន រែកឆ្នាំង ទៅៗរហូតមកដល់ភូមិហ្នឹង។

**ស៖** សូមអរគុណ។ សូមលោករៀបរាប់អំពីលក្ខខណ្ឌជីវភាពដែលគេមកដល់ក្នុងតំបន់ដែលលោករស់នៅពេលនោះ?

**ឆ៖** បាទ ជីវភាពមកហ្នឹងគ្នាដាច់បាយដាច់ទឹកដែរហ្នឹង បានវាមានអង្ករឯណាឲ្យស៊ីគ្រប់គ្នា។

**ស៖** សូមអរគុណ។ តើលោកបានសង្កេតឃើញថាមានបញ្ហាសុខភាពដែរឬទេ ក្នុងចំណោមអ្នកដែលជម្លៀសទាំងអស់នោះ?

[១១:៣៨:២០]

**ឆ៖** បាទ ខ្លះវាឃើញដែរ ឃើញគ្រុន ប៉ុនគ្រុនហើយចេះតែខំប្រឹងដើរទៅ បំណាច់គេឲ្យទៅហើយចេះតែទៅៗ។

**ស៖** សូមអរគុណ។ នៅពេលដែលគេទៅដល់កន្លែងនោះ តើមានគេផ្តល់អាហារឬក៏ថ្នាំសង្កូវអីទេ នៅពេលទៅដល់មូលដ្ឋានដែលលោកបានឃើញនោះ?

**ឆ៖** បាទ គេមិនឲ្យស្អីទេ ប៉ុន្តែគេស្មើដែរ ស្មើរកអង្កហូបគ្នាទៅវាដាច់បាយ ទៅគេឲ្យដែរអង្ករមួយកំប៉ុង ពីរកំប៉ុងអីហ្នឹង ប៉ុន្តែរឿងថ្នាំពេទ្យថ្នាំអីគឺគ្មានទេ។

**ស៖** សូមអរគុណ។ ថាតើអ្នកភូមិប្រជាជនមូលដ្ឋាននោះថាតើអ្នកទាំងអស់នោះអ្នកមូលដ្ឋាននោះថាតើយល់យ៉ាងដូចម្តេចឬក៏ឆ្លើយតបទៅនឹងប្រជាជនជម្លៀសនោះដូចម្តេច?

**ឆ៖** បាទ តាមប្រជាជនគ្នាឯងដែលបានឃើញអ្នក១៧ទៅ ក៏គ្នាអាណិតអាសូរអ៊ីចឹងដែរ មិនមែនថាដាច់អហង្ការដូចពួកគេនោះ។ ប្រជាជនចិត្តវាមិនដាច់ សុំអីឲ្យហ្នឹង សុំអង្ករឲ្យអង្ករ សុំបន្លែឲ្យបន្លែ។

[១១:៤០:០០]

**ស៖** សូមអរគុណលោក ឡេវ ឡាំ។ ឥឡូវនេះខ្ញុំនឹងចូលទៅប្រធានបទថ្មី។ ខាងដើមនោះលោកនិយាយថា គេបានណែនាំឲ្យលោកយកមនុស្សទៅកន្លែងសម្លាប់ ហើយនៅក្នុងចំណោមអ្នកទាំងនោះមានក្មេងប្រាំនាក់ផង។ តើឪពុកម្ដាយកុមារទាំងអស់នោះនៅក្នុងក្រុមដែលលោកជូនទៅទាំងអស់ហ្នឹង ឬក៏ក្រុមខុសគ្នា?

**ឆ៖** បាទក្រុមហ្នឹងក្មេងប្រាំនាក់ហ្នឹង ក្រុមតែមួយទេ។ ឪពុកម្ដាយក៏ទៅ នាំកូននាំចៅទៅហ្នឹង។

**ស៖** សូមអរគុណ។ តើខ្ញុំយល់ត្រឹមត្រូវដែរទេគឺថាកុមារៗទាំងអស់នោះគឺជាកូនរបស់អតីតទាហាន លន់ នល់ និងពួករាជការមន្ត្រីលន់ នល់ ដែលគេធ្វើប្រវត្តិរូបហើយមុននឹងគេយកទៅសម្លាប់នោះ?

[១១:៤១:២៣]

**ឆ៖** បាទតែគេធ្វើប្រវត្តិរូបហើយគេយកទៅហ្នឹង គឺសុទ្ធតែគេហៅថា ស្វ័យត្រាណៗ – កងស្វ័យត្រាណ។

**ស៖** សូមអរគុណ។ ក្រៅពីក្រុមដែលលោកបញ្ជូនយកទៅកន្លែងគេសម្លាប់ហ្នឹង តើមានក្រុមមនុស្សផ្សេងទៀតទេដែលគេយកបញ្ជូនទៅកន្លែងសម្លាប់ដែលថាល្បាយផ្សេងក៏បញ្ជូនទៅកន្លែងហ្នឹងដែរ តើមានអីចឹងដែរឬទេ?

**ឆ៖** បាទ កន្លែងហ្នឹងវាមានពីមុនមកហើយ ប៉ុន្តែមិនដឹងអ្នកណាបញ្ជូនទៅ។ ប៉ុន្តែគ្រាន់តែខ្ញុំថាជូនហ្នឹងគឺថា ដូចថាចាញ់នយោបាយគេដែរថា "អ្អែង! យកប៉ុន្មានគ្រួសារហ្នឹង ពីរបីគ្រួសារហ្នឹងទៅ។ ទៅឲ្យទៅនៅភូមិមួយទៀតទៅ"។ បានក៏ទៅតាមគេហ្នឹងទៅ ចេះតែទៅៗ គេបញ្ជាទៅហើយ។

**ស៖** តើលោកពន្យល់បានទេថា ចាញ់នយោបាយគេ ឬគេបញ្ឆោតលោកហ្នឹង តើអាចពន្យល់បានឲ្យពិស្ដារបន្តិចបានទេ?

[១១:៤២:៥៣]

**ឆ៖** បាទ គេថាឲ្យទៅហ្នឹង គេថា ហ្អឺ! អ្អែងយកប៉ុន្មានគ្រួសារហ្នឹង អាពីរនាក់ហ្នឹងដែលជូនទៅនៅភូមិផ្សេង អាភូមិចាប់ក្រសាំង។ ដល់ពេលអីចឹង វាមិនមែនទៅឲ្យទៅអីចឹងណា។ បានថាគេយកទៅសម្លាប់ អត់ -- ដឹងថាយកទៅសម្លាប់ហើយ ខ្ញុំមិនទៅទេ គេថា។

**ស៖** សូមអរគុណ។ ហើយក្នុងចំណោមគ្រួសារទាំងអស់នេះដែលត្រូវបានគេបញ្ជូនទៅ នោះគឺថាតើមានកុមារនៅក្នុងចំណោមអ្នកទាំងអស់នោះដែរឬទេ?

**ឆ៖** បាទ ចំណោមនៅក្នុងគ្រួសារហ្នឹងតែម្តង។ ឪពុកម្តាយៗ កូនហ្នឹងតែម្តងទេ អត់មានពីក្រៅពីផ្សេងពីឪពុកម្តាយទេ។

**សៈ** សូមអរគុណ។ ហើយនៅតាមផ្លូវដែលលោកជូនក្រុមមនុស្សដែលបញ្ជូនទៅកន្លែងសម្លាប់ តើលោកអាចរៀបរាប់អំពីអាកប្បកិរិយា ឬក៏សម្តីសំដៅ ពេលដែលធ្វើដំណើរទៅហ្នឹងបានទេ? តើលោកសង្កេតឃើញដូចម្តេច?

**ឆ៖** បាទ ឲ្យនាំទៅហ្នឹងគឺឲ្យអ្នកនាំផ្លូវ ឲ្យនាំផ្លូវមុន អ្នកនៅខាងក្រោយគឺនៅខាងក្រោយ។ នាំទៅ វាអត់មាននិយាយហេតុការណ៍អីទេ។ បាទនាំទៅដល់ ទាល់តែដល់កន្លែងសម្រាកហ្នឹងតែម្តង។

[១១:៤៤:៥៥]

**សៈ** តើលោកសង្កេតឃើញថា អ្នកទាំងនោះមានប្រតិកម្ម ឬក៏ប្រឆាំងអ្វីទេនៅពេលដែលគេចាប់ចងអ្នកខ្លះនៅក្នុងក្រុមទាំងអស់នោះ តើលោកបានឃើញពីហេតុការណ៍ហ្នឹងយ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ គេថាអានេះទៅជួប -- គេឲ្យទៅជួបអង្គការ។ ដល់អង្គការៗសុំ អង្គការឲ្យចងសិន ហើយបានទៅជួបគេក្រោយ។ បានគេព្រមឲ្យចង ហើយឲ្យរក -- គេឲ្យស្បៀងឲ្យអី ជួបអង្គការក្រែងលោបានស្បៀងបានអង្ករអីហូបហ្នឹង។ អាហ្នឹងវាប៉ុណ្ណឹង។

**សៈ** ខ្ញុំចង់សួរអំពីប្រតិកម្មអ្នកដែលជនរងគ្រោះដែលត្រូវបានគេចងនោះ តើអ្នកហ្នឹងប្រតិកម្ម ឬក៏ប្រឆាំងអីទេនឹងការចាប់ចងហ្នឹង?

**ឆ៖** បាទ គ្នាមិនប៉ានប្រឆាំងទេ មើល៍អត់មាននេះ ឲ្យគេចងស្រួល។

**សៈ** សូមអរគុណ។ លោកបាននិយាយបន្តទៅទៀតដែរថាៗ ស្រ៊ន ជាអ្នកបែងចែកប្រវត្តិរូបជាពីរប្រភេទ។ មួយ គឺមាននាយទុន ហើយមួយទៀតគឺថា មានទាហាន លន់ នល់, រាជការ លន់ នល់ ហើយក្រុមមួយទៀតគឺមានក្រុមកសិករ។ ចំពោះខ្ញុំសួរលោកថា ចុះក្រុមប្រជាជនដែលស្ថិតនៅក្រុមប្រភេទជាកសិករនោះ ក្រោយមកយ៉ាងដូចម្តេចដែរ?

[១១:៤៧:០២]

**ឆ៖** បាទ ខ្ញុំឆ្លើយត្រង់ថា កសិករហ្នឹងគាត់បាន -- គាត់ថាគាត់អ្នកកសិករ គាត់ធ្វើស្រែ ធ្វើចម្ការអីចឹងទៅ។ គាត់គេឲ្យនៅមួយកន្លែងអីចឹង ក៏នៅធ្វើការហ្នឹងទៅជាធម្មតារាល់ថ្ងៃ រហូតទៅដល់យួនចូលមក ទៅផ្ទះស្រុកសម្បែងគាត់វិញអស់។

**សៈ** លោកនិយាយថា លោកបានឃើញ២០០ ឬ៣០០គ្រួសារមកពីកំពង់ឆ្នាំង ហើយនិង

ភ្នំពេញ។ តើលោកឃើញប៉ុន្មានគ្រួសារដែលលោកបានឃើញគេយកទៅកន្លែងសម្លាប់មនុស្សហ្នឹង?

**ឆ៖** បាទ ខ្ញុំបានឃើញប្រហែលជា១០០គ្រួសារ។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរចុងក្រោយមួយរបស់ខ្ញុំ។ តើលោកយល់ដូចម្ដេចនៅពេលឃើញថាឪពុកមារបស់លោកហ្នឹងក៏ជាជនរងគ្រោះផងដែរ?

**ឆ៖** បាទ ថា -- ខ្ញុំយល់ថា គ្រាន់តែមានការឈឺចាប់តែប៉ុណ្ណោះទេ តែមិនប៉ាននិយាយអីចេញបានទេ។

**លោកស្រី បេនី យេះ**

សូមអរគុណលោក ឡេវ ឡាំ។ ខ្ញុំសូមសោកស្ដាយដែលលោកបានបាត់បង់ឪពុកមា ហើយសូមអរគុណចំពោះកិច្ចប្រឹងប្រែងរបស់លោកឲ្យធ្វើដំណើរទៅដោយសុវត្ថិភាព។ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី។ ឥឡូវដល់ពេលសមល្មមសម្រាកហើយដែរ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ត្រឹមនេះរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬក៏ទីកន្លែងណាមួយសមស្របសម្រាប់សាក្សីនេះសម្រាកនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងមួយសាមសិបនាទី រួមជាមួយនឹងមេធាវីប្រឹក្សាសាក្សីផង។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៥០ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ។ សូមគោរពលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ជម្រាបសួរលោក ឡេវ ឡាំ។ ខ្ញុំឈ្មោះ សុន អរុណ ជាមេធាវីការពារលោក នួន ជា។ ថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក ហើយនិងបន្ទាប់មក បានសហភាតាខ្ញុំបានមានសំណួរមួយចំនួនទៀត។ សំណួរទី១ ខ្ញុំសូមសួរលោកថា -- ខ្ញុំយកចម្លើយរបស់លោកដែលសួរដោយសហចៅក្រមស៊ើបអង្កេត។ ពេលនោះលោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតថា នៅក្នុងគុកដំរីស្រុតនោះមានអ្នកជាប់ឃុំចំនួនប្រហែល -- ដូចមានប្រសាសន៍ មាននិយាយពីព្រឹកមិញ មានប្រហែល២០-៣០នាក់ អ៊ីចឹង? បើខ្ញុំនិយាយខុស សូមកែខ្ញុំផង។ អ៊ីចឹងទេមែនទេ?

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ ពិតមែនហើយ។

[១៣:៣៥:២៩]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ចេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនយល់ថាបញ្ហាពីរឿងបកប្រែ ឬអត់ទេ។ គឺថាបើសិនជាប្រធានបទនៃការសួរតែពីរឿងដំរីស្រុតនោះ គុកដំរីស្រុតនោះ គឺមិនស្ថិតនៅក្នុងវិសាលភាពនៃសវនាការនេះទេ។ គឺថាហើយតើមានបញ្ហាពីរឿងអ្នកបកប្រែ ឬអត់ទេ គឺនិយាយអំពីគុកដំរីស្រុតនេះ គឺកើតឡើងនៅក្នុងឆ្នាំ១៩៧៦នេះ ខ្ញុំសូមជំទាស់ ដោយសារថាវាក្រៅវិសាលភាព។

**លោក សុន អរុណ៖**

ពីព្រឹកមិញ ខ្ញុំឃើញព្រះរាជអាជ្ញាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយពីរឿងគុកដំរី

ស្រុកហ្នឹងអស់រយៈពេលមួយព្រឹករួចទៅហើយ។ ហើយដល់ពេលខ្ញុំឡើងសំណួរហ្នឹងដដែល ហើយមាននៅក្នុងឯកសាររបស់ចៅក្រមស៊ើបអង្កេត លោកថាខុស-- ហួសវិសាលភាព។ អានេះសូមលោកប្រធានពិចារណា។

**លោក ខេល លីសាក់៖**

លោកប្រធាន គឺមិនត្រឹមត្រូវដែលមេធាវីពិនិត្យមើលឃើញថា ការកាប់សម្លាប់នេះកើតឡើងនៅក្នុងប៉ុន្មានខែ ក្រោយពីខែមេសា ឆ្នាំ១៩៧៥។ ប៉ុន្តែមេធាវីលើកឡើងនៅក្នុងឆ្នាំ១៩៧៦ និយាយអំពីទីតាំងនៃការសម្លាប់នោះ។ ចំណុចមួយ គឺសាក្សីបញ្ជាក់នៅក្នុងបទសម្ភាសន៍គឺថា១គឺប្រហែលជា៥០០ម៉ែត្រ គឺនៅបន្ទាប់ពីកន្លែងចាស់។ ត្រង់ហ្នឹង គឺថាភស្តុតាងដែលគាត់បង្ហាញព្រឹកមិញនេះ គឺមិនទាក់ទងទៅនឹងអំពីមន្ទីរគុកនោះទេ គឺថាទាល់ឆ្នាំ១៩៧៦ទេ បានព្រៃដំរីស្រុកនោះបង្កើតជាគុក។ ដូច្នេះ ក្រៅវិសាលភាពអ្វីដែលមេធាវីបានលើកឡើងនោះ។

[១៣:៣៧:៤១]

**ប្រធានអង្គជំនុំ៖**

សូមមេធាវីពាក់ព័ន្ធជាមួយនឹងអង្គហេតុ។ អង្គហេតុហ្នឹង គឺនៅទីកន្លែងសម្លាប់មនុស្សនៅខាងលិចភូមិ ភូមិច្រកសង្កែ។ ហើយគោលដៅនៃការសម្លាប់ហ្នឹង គឺការកាប់សម្លាប់ហ្នឹងគឺជន១៧មេសា ដែលជាអតីតជាទាហាន ជាមន្ត្រីរដ្ឋការ ជាសេនាជនណ៎ះ ដែលបែងចែកជាពីរក្រុម។ នេះជាគោលដៅនៃការសួរដេញដោលនៅថ្ងៃនេះ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសួរពីរឿគុកមុនដំបូងសិន ហើយដល់ហើយបានខ្ញុំសួរទៅដល់កន្លែងយកមនុស្សទៅសម្លាប់។ តើវាខុស ឬត្រូវ? មាននៅក្នុងឯកសារសួរចម្លើយចៅក្រមស៊ើបអង្កេត។

**ប្រធានអង្គជំនុំ៖**

វាមិនមែនស្ថិតនៅក្នុងឯកសារចៅក្រមស៊ើបអង្កេតហ្នឹងសុទ្ធតែជាកម្មវត្ថុយកមកដេញដោលនៅទីនេះទេ។ កម្មវត្ថុនៃការដេញដោលនៅទីនេះ គោលបំណងគឺឆ្លុះបញ្ចាំងអំពីគោលនយោបាយនៃការអនុវត្តគោលនយោបាយចំពោះជន១៧មេសា ដូចសំណើ ផ្អែកលើសំណើសុំរបស់សហព្រះរាជអាជ្ញាធ្វើជាមូលដ្ឋានក្នុងការសួរ។ គេដកស្រង់តែអង្គហេតុពាក់ព័ន្ធមួយចំនួនប៉ុណ្ណោះក្នុងការសួរដេញដោលនេះ មិនមែនយកផ្អែកលើកំណត់ខ្លឹមសារនៃកំណត់ហេតុទាំងស្រុងនៃសាក្សីរូបនេះ ដែលបានឆ្លើយនៅចំពោះ

មុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតមកសួរទេ។ ពីព្រោះការសួរនោះ គឺវាសួរទូលំទូលាយនឹងក្របខ័ណ្ឌនៃអង្គហេតុដែលសាក្សីដឹងរឿងរ៉ាវទាំងមូលនៅក្នុងពេញរបបកម្ពុជាប្រជាធិបតេយ្យតែម្តង។

[១៣:៣៩:៣៣]

**លោក សុន អរុណ៖**

ខ្ញុំមិនយល់ដែរ ប៉ុន្តែឥឡូវនេះខ្ញុំផ្ទេរសំណួរនេះទៅឲ្យសហភាតាខ្ញុំនឹងសួរបន្តចុះ។ ខ្ញុំសូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរ លោក លោកស្រីចៅក្រម ភាគីទាំងអស់ ហើយនិងលោកសាក្សីផងដែរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមចាប់ផ្តើមសួរលោកអំពីសំណួរមួយចំនួនលោកសាក្សី គឺសួរអំពីការមកដល់នៃប្រជាជនដែលមកពីភ្នំពេញ ហើយនិងមកពីកំពង់ឆ្នាំង។ ខាងដើមនោះលោកនិយាយថា ប្រហែលជាមាន ២០០ ឬ៣០០គ្រួសារដែលមកដល់នោះ គឺថាក្នុងមនុស្ស ២០០ ឬ ៣០០គ្រួសារនេះ តើគេមកតែម្តង ឬក៏មកជាបន្តបន្ទាប់ក្នុងថ្ងៃខុសៗគ្នា? តើលោកនៅចាំឬទេ នៅពេលដែលលោកបានឃើញពួកគេដំបូងនោះ? តើពេលដែលឃើញហ្នឹង គឺថាមានមនុស្សទាំងអស់ហ្នឹងមកដល់កន្លែងហ្នឹងហើយ ឬយ៉ាងម៉េចសូមលោកពន្យល់?

[១៣:៤១:១១]

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ ខ្ញុំបានឃើញគេមកដល់អស់ហើយ បានជាដឹងជាចំនួនច្រើន ព្រោះថាមកបន្តបន្ទាប់ហ្នឹងក៏ខ្ញុំមិនបានដឹងទេ ដឹងតែត្រឹមថាឃើញគេមកនៅក្រោមផ្ទះខ្ញុំ នៅតាមម្លប់ឈើ នៅក្រោមដើមឈើអីហ្នឹងបាទ ខ្ញុំឃើញអីចឹង។

**ស៖** តើលោកបានឃើញមនុស្សដែលមកពីភ្នំពេញ ឬក៏មកពីទីក្រុងផ្សេងទៀត ឧទាហរណ៍នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ ខែមិថុនា ឆ្នាំ១៩៧៥ តើបានឃើញអីចឹងទេ?

**ឆ៖** បាទ កាលណោះប្រជាជនជម្លៀសចេញពីភ្នំពេញផង ពីកំពង់ឆ្នាំងផង វាច្របូកច្របល់ដឹង

ណាមួយនៅខាងកំពង់ឆ្នាំ ណាមួយនៅភ្នំពេញ វាមិនបានដឹងត្រង់ហ្នឹងទេបាទ។

**ស៖** ខ្ញុំចង់ឲ្យលោកនិយាយឲ្យច្បាស់ កាលណាលោកនិយាយអំពីអ្នកទាំងអស់នោះ លោកមិនបានឃើញ ឬថាមកដល់ហ្នឹងដោយវិធីណាទេ គ្រាន់តែថាឃើញតែពួកគេមកដល់រួមគ្នាហើយ គឺថាក្រោយឆ្នាំ១៩៧០ -- ថ្ងៃ -- ខែមេសា ឆ្នាំ១៩៧៥ លោកបានឃើញពួកគេទាំងអស់នៅកន្លែងហ្នឹងរួចទៅហើយ។ តើអ៊ីចឹងឬម៉េច?

**ឆ៖** បាទ ខ្ញុំបានឃើញនៅតាមភូមិហ្នឹងរួច។

[១៣:៤៣:១២]

**ស៖** មានន័យថាលោកមិនដែលបានឃើញ១អាទិត្យ ឬ២អាទិត្យក្រោយមក ឬ១ខែក្រោយមក ឃើញប្រជាជនថ្មីមកទៀតទេ ក្នុង -- មកពីកំពង់ឆ្នាំង ឬមកពីភ្នំពេញនោះ?

**ឆ៖** បាទ ឃើញតាំងពីនុ៎ងមក អត់មានដែលឃើញចូលមកទៀតទេ។

**ស៖** បាទ តើលោកបាន -- ខ្លួនឯងបាននិយាយទៅកាន់អ្នកទាំងអស់នេះទេ អ្នកណាម្នាក់ក្នុងចំណោម២០០ ទៅ៣០០គ្រួសារនោះ ពេលដែលគេយកមកដល់កន្លែងមួយដែលលោកបានឃើញនោះ?

**ឆ៖** បាទ ខ្ញុំមិនដែលស្គាល់គេ ខ្ញុំអត់ដែលបាននិយាយលេងសើចអីជាមួយនឹងគេទេបាទ។

**ស៖** តើលោកធ្វើម៉េចនឹងដឹងបានថា ពួកគេមកពីភ្នំពេញ ឬមកពីកំពង់ឆ្នាំបើលោកមិនដែលបាននិយាយជាមួយពួកគេផងនោះ?

**ឆ៖** បាទ ខ្ញុំមកហ្នឹងវាឃើញនៅផ្ទះខ្ញុំហ្នឹងហើយ ប៉ុន្តែខ្ញុំមិនបានសួរអារឿងមកពីខាងណាខាងណីអីទេ ប៉ុន្តែថា ឮម្ដាយខ្ញុំថា "គាត់មកពីកំពង់ឆ្នាំងកូនអើយ" អ៊ីចឹង។

**ស៖** តើលោកនិយាយថាតើពួកគេមកនៅក្រោមផ្ទះហ្នឹងតើលោកចង់សំដៅ ចង់និយាយថាម៉េច?

[១៣:៤៥:១០]

**ឆ៖** អ្នកជម្លៀសមកនៅក្នុងក្រោមផ្ទះហ្នឹង វាថាអត់មានទីជម្រក គ្នាចេះតែសុំជ្រកសុំកោនសិនទៅ បានគ្នាសុំនៅហ្នឹង។

**ស៖** តើអ្នកផ្សេងទៀត ក្រុមអ្នកមកថ្មីនោះ តើគេមកនៅក្រោមផ្ទះអ្នកផ្សេងៗ ឬក៏មកនៅក្បែរៗហ្នឹងនៅក្នុងជិតៗផ្ទះអ្នកភូមិមូលដ្ឋានហ្នឹង ឬក៏យ៉ាងម៉េចដែរអ្នកផ្សេងទៀតនោះ?

**ឆ៖** បាទ អ្នកផ្សេងទៀតគេនៅតាមផ្ទះ នៅក្នុងភូមិហ្នឹង ប៉ុន្តែផ្ទះគេមានច្រើនគេនៅតាមផ្ទះទៅផ្ទះឯណោះខ្លះ ផ្ទះឯណោះខ្លះទៅ។ ផ្ទះវាមានទៅដល់១៥០ខ្នងឯណោះអាភូមិខ្ញុំហ្នឹង អ៊ីចឹងគេនៅតាមផ្ទះ

គេខ្លះៗអ៊ីចឹងទៅ នៅក្រោមម្លប់ខ្លះទៅ។

**ស៖** ដូច្នេះតើត្រឹមត្រូវទេ តើនិយាយថាមនុស្ស២០០ទៅ៣០០គ្រួសារដែលមកដល់នោះ គឺរស់នៅរាយប៉ាយនៅក្រោមផ្ទះ នៅតាមផ្ទះរបស់អ្នកភូមិមូលដ្ឋាន? តើអ៊ីចឹងត្រឹមត្រូវដែរទេ? បាទ ប្រសិនបើដូច្នោះមែនថាតើពួកអ្នកទាំងនោះបន្តរស់នៅក្រោមផ្ទះ ឬក៏ជិតៗនោះរយៈពេលប៉ុនណា?

**ឆ៖** បាទ ត្រឹមត្រូវណាស់គេនៅហ្នឹងមែន ប៉ុន្តែអស់រយៈ១អាទិត្យ អស់រយៈជាង១អាទិត្យបាត់មនុស្សអស់ខ្លះ នៅខ្លះ។

**ស៖** តើត្រឹមត្រូវទេបើការដែលខ្ញុំនិយាយថា មិនមានអ្នកណាម្នាក់ក្នុងដែលអ្នកដែលមកពីភ្នំពេញ ឬក៏កំពង់ឆ្នាំងនោះត្រូវបានគេយាមកាម ឬក៏ត្រូវបានគេយកទៅដាក់មួយកន្លែង ហើយគេទុកឲ្យនៅតែកន្លែងហ្នឹង? តើខ្ញុំនិយាយអ៊ីចឹងត្រូវ ឬក៏យ៉ាងណាដែរ?

**ឆ៖** បាទ ត្រូវហើយ ព្រោះគេមកវានៅរាយប៉ាយហ្នឹង ដល់តែពេលនេះទៅគេជ្រើសរើសគេឲ្យទៅនៅផ្សេងទៀតទៅ។

[១៣:៤៧:៥១]

**ស៖** ថាតើលោកនៅចាំទេ ថាតើមានមនុស្សប៉ុន្មាននាក់មកពីកំពង់ឆ្នាំងប៉ុន្មាននាក់? មកពីភ្នំពេញប៉ុន្មាននាក់ នៅជិតផ្ទះ ឬក្រោមផ្ទះលោកនោះ? មានបុរសប៉ុន្មាននាក់ ស្ត្រីប៉ុន្មាននាក់ ហើយនិងកុមារប៉ុន្មាននាក់ដែលនៅជិតផ្ទះរបស់លោកនោះ?

**ឆ៖** បាទ នៅជិតផ្ទះហ្នឹងបានឃើញពីរបីគ្រួសារដែរ ប៉ុន្តែនៅខាងឆ្ងាយពីផ្ទះខ្ញុំមិនដឹងជាមនុស្សជាច្រើន មិនបានរាប់ថាគ្រួសារនេះមានប៉ុន្មានគ្រួសារនោះមានប៉ុន្មានទេ ប៉ុន្តែមានចំនួននៅក្នុងភូមិវាច្រើនពេញភូមិតែម្តង។

**ស៖** លោកនិយាយថា ពីរបីគ្រួសារនៅជិតផ្ទះខ្ញុំ ប៉ុន្តែព្រឹកមិញលោកនិយាយថា មួយគ្រួសារប្រហែលមួយគ្រួសារមួយៗមានមនុស្សប្រាំទៅប្រាំមួយនាក់។ អ៊ីចឹងនៅជិតផ្ទះលោក នៅក្រោមផ្ទះលោក គឺថាអាចមាន១៥នាក់ទៅ២០នាក់ ឬក៏ថាប៉ុន្មានដែលមកពីកំពង់ឆ្នាំង ដែលនៅក្រោមផ្ទះ ឬជិតផ្ទះលោកនោះ?

**ឆ៖** បាទ ដឹងថាអ្នកមកនៅជិតខាងមានតែអ្នកកំពង់ឆ្នាំងទេ។ អ្នកភ្នំពេញគាត់នៅខាងផ្ទះគេផ្សេងៗទៀត។

[១៣:៤៩:២៩]

**សៈ** អ្នកទាំងអស់នេះដែលមកនៅផ្ទះរបស់លោក ក្រោមផ្ទះរបស់លោកមួយរយៈពេល តើលោកបាននិយាយ ឬបាននិយាយលេងជាមួយពួកគាត់ណាម្នាក់ទេ? និយាយជាមួយពួកគាត់អំពីប្រវត្តិការងាររបស់ពួកគេទេ?

**ផៈ** បាទ ខ្ញុំសូវបាននិយាយទេ ព្រោះអីការងារខ្ញុំនេះវាផ្សេង ប៉ុន្តែគ្រាន់តែទៅមើលឃើញតែមុខ។ អ៊ីចឹងទៅផ្ទះហ្នឹងឃើញតែមុខគេ គេចមកវិញមក មិនសូវនៅផ្ទះទេ។

**សៈ** ដូច្នេះខ្ញុំនឹងនិយាយទៅមុខបន្តិចទៀតគិតតាមពេលវេលា។ ព្រឹកមិញនេះលោកបាននិយាយថានៅចំណុចពេលមួយលោកបានដឹងថា អ្នកដែលទើបតែមកដល់មកពីភ្នំពេញឬកំពង់ឆ្នាំងនោះត្រូវតែផ្តល់ឬក៏ផ្តល់ប្រវត្តិរូបរបស់ខ្លួនទៅឱ្យគេ។ តើលោកនៅចាំទេនៅពេលដែលព័ត៌មាននេះត្រូវបានបញ្ជូនទៅដល់អ្នកដែលនៅក្រោមផ្ទះរបស់លោកនោះដែលថាគេឱ្យធ្វើប្រវត្តិរូបនោះតើលោកបានដឹងទេ?

**ផៈ** បាទ គេធ្វើប្រវត្តិរូបនោះខ្ញុំមិនបានដឹងទេ ព្រោះអីខ្ញុំនៅមន្ទីរនោះដែរ។

[១៣:៥១:១៦]

**សៈ** ប៉ុន្តែសូមលោកពន្យល់ឱ្យខ្ញុំយល់ ថាតើក្នុងការអនុវត្តជាក់ស្តែងកាលនោះតើអ្នកទាំងអស់នេះរស់នៅរាយប៉ាយនៅតាមក្រោមផ្ទះជិតផ្ទះ ១៥០ខ្នងនោះ តើពួកគេដឹងដូចម្តេចបានថាពេលមួយពួកគេត្រូវសរសេរជាប្រវត្តិរូបរបស់គេ? ថាតើការផ្សាយព័ត៌មានឱ្យអ្នកទាំងអស់ហ្នឹងដឹងគេធ្វើតាមរបៀបម៉េចដើម្បីគេកត់ត្រាប្រវត្តិរូបបាននោះ?

**ផៈ** បាទ កាលនោះគេដើរកត់ប្រវត្តិរូបទៅតាមផ្ទះលោកប្រធានភូមិគេដើរកត់។

**សៈ** តើប្រធានភូមិធ្វើដូចម្តេចទៅគោះទ្វារ ឬក៏ទៅប្រាប់ ឬក៏គាត់ទៅសួរថាតើអ្នកណាមកពីភ្នំពេញសូមលើកដៃ អ្នកណាមកពីកំពង់ឆ្នាំងសូមលើកដៃតើគេធ្វើរបៀបម៉េចតាមដែលលោកដឹង លោកបានឃើញនោះ?

**ផៈ** បាទ គេទៅៗពីផ្ទះមួយទៅផ្ទះមួយ គេសួរថាអ្នកឯងអញ្ជើញមកពីខាងណា? អាខ្លះថានៅកំពង់ឆ្នាំងៗទៅ ខ្លះថានៅភ្នំពេញៗទៅ។

[១៣:៥២:៥៥]

**សៈ** ហើយក៏មានមនុស្សមួយចំនួនដែលមកពី-- ដែលថាមកដល់ពីភូមិហើយនោះក៏គេប្រាប់ថាពួកគេមកពីកំពង់ឆ្នាំង ឬមកពីភ្នំពេញ។ តើអ៊ីចឹងឬទេ?

**ផៈ** បាទកាលនោះប្រធានភូមិគេសួរ។ អ៊ីចឹងហើយថាមកពីកំពង់ឆ្នាំង ប្រាប់ថាមកពីកំពង់ឆ្នាំង

បើថាមកពីភ្នំពេញ ប្រាប់ថាខ្ញុំមកពីភ្នំពេញ។ ថាអ៊ីចឹង។

**ស៖** តើមេភូមិប្រាប់ពួកគេដូចម្ដេចទៀត? តើមេភូមិនោះសួរអ្នកទាំងអស់នោះឲ្យធ្វើម៉េចក្រៅពីសរសេរថាមកពីណា? តើគាត់ណែនាំឲ្យអ្នកទាំងអស់នោះសរសេរបំពេញប្រវត្តិរូបនោះក្រៅពីបញ្ជាក់មកពីណាហ្នឹងណែនាំឲ្យសរសេរដូចម្ដេចទៀត?

**ឆ៖** ការណែនាំឲ្យសរសេរទៀតខ្ញុំមិនបានដឹងទេ ព្រោះមិនបាននៅជាប់ជាមួយប្រធានភូមិទេ។

**ស៖** គឺអាចអ៊ីចឹង ក៏ប៉ុន្តែនិយាយអំពីអ្នកដែលរស់នៅផ្ទះរបស់លោកនោះ ក្រោមផ្ទះរបស់លោកនោះ តើគេបាននិយាយប្រាប់លោក ឬលោកបានដឹងទេថាគេណែនាំឲ្យពួកគាត់សរសេរដូចម្ដេច ដាក់ដូចម្ដេចក្នុងប្រវត្តិរូបរបស់ពួកគេទេ?

**ឆ៖** បាទ គាត់សរសេរប្រវត្តិរូប គាត់ថាគាត់ជាកសិករ គាត់មានគោ មានរទេះ។ អ៊ីចឹងគាត់ថាធ្វើអ្នកធ្វើស្រែ។ ប៉ុន្តែអ្នកនៅក្រោមផ្ទះខ្ញុំគឺនៅរស់រាល់ថ្ងៃទល់ឥឡូវ នៅកំពង់ឆ្នាំង។

[១៣:៥៥:១២]

**ស៖** តើលោកចាំដែរឬទេថាតើពួកគេត្រូវសរសេរប្រវត្តិរូបនៅកន្លែងណា? តើពួកគេត្រូវបំពេញប្រវត្តិនៅក្រោមផ្ទះរបស់លោក ឬក៏គេត្រូវទៅកន្លែងណាផ្សេងដើម្បីសរសេរប្រវត្តិហ្នឹងដែរឬទេ?

**ឆ៖** បាទត្រង់ហ្នឹងគឺគេដើរទៅតាមផ្ទះហើយ ដល់ពេលគេហៅប្រជុំ គឺទៅប្រជុំទៅ ទៅផ្ទះប្រធានភូមិ គេហៅទៅប្រជុំ គេកត់ប្រវត្តិរូបបន្តទៀតនៅផ្ទះប្រធានភូមិនោះទេ។ មិនបាននៅកត់នេះទេ ទៅកត់កន្លែងផ្ទះប្រធានភូមិនោះ ជួបជុំគ្នាផ្ទះប្រធានភូមិ។

**ស៖** តើមនុស្សទាំងអស់ ដូចថា៧០០នាក់ដែលលោកថាហ្នឹង ទាំងអស់គ្នាទៅតែពេលម្ដង ឬក៏ដូចម្ដេច?

**ឆ៖** បាទ វាមិនទៅម្ដង មិនទៅទាំងអស់ទេ។ ម្ដងវា ដោយសារគេរើស ម្ដង៣០នាក់ ៣០គ្រួសារ ៤០គ្រួសារអ៊ីចឹងទៅ ទៅម្ដងអ៊ីចឹងទៅ។ រួចពីហ្នឹងគេទៅម្ដងទៀតអ៊ីចឹងទៅ។

**ស៖** ប៉ុន្តែតើលោកបានឃើញដោយផ្ទាល់ភ្នែកទេដែលថា គេប្រាប់ឲ្យទៅ ហើយគេទៅប្រមូលផ្ដុំនៅតាមផ្ទះមេភូមិ លោកឃើញដូចផ្ទាល់ភ្នែកទេ?

**ឆ៖** បាទ ខ្ញុំបានឃើញដែរ ប៉ុន្តែគ្រាន់តែខ្ញុំមិនមានការទៅប្រជុំជាមួយគេ គ្រាន់តែឃើញ ព្រោះខ្ញុំដើរចេញទៅ។

[១៣:៥៧:១៨]

**សៈ** នៅក្នុងការផ្តល់សក្ខីកម្មរបស់លោក គឺថាមនុស្សដែលនៅក្រោមផ្ទះរបស់លោកគឺថាអ្នកទាំងអស់នោះគឺនៅក្រោមផ្ទះលោកបញ្ជាក់ថាពួកគាត់សុទ្ធតែកសិករ។ តើអ៊ីចឹងទេ?

**ឆៈ** បាទនៅក្រោមផ្ទះខ្ញុំគាត់ជាអ្នកកសិករ ហើយនៅជិតហ្នឹងក៏ជាអ្នកកសិករដែរ។ ហើយបើនៅផ្ទះគេខ្លះផ្សេងៗហ្នឹងក៏មានកសិករ ក៏មានខាងស្វ័យត្រាណហ្នឹងដែរ។

[១៣:៥៧:៥៨]

**សៈ** លោកបានផ្តល់សក្ខីកម្មកាលពីមុននោះ គេមិនឲ្យ ថាមិនឲ្យលោកដឹងថាគេសរសេរប្រវត្តិអីនោះទេ។ អ្វីដែលលោកដឹងនោះ អ្វីដែលសរសេរនោះគឺអ្វីដែលលោកបានឮពីមនុស្សដែលរស់នៅក្នុងផ្ទះរបស់លោកទេ តើលោកអាចពន្យល់បន្ថែមអ្វីបាន?

**ឆៈ** ប្រាប់ថា ប៉ុណ្ណឹងរាក់បន្តិចហើយ។ សូមម្តងទៀតបាទ។

**សៈ** កាលពីព្រឹកនេះគឺថាលោកមិនមានលទ្ធភាពបើកមើលប្រវត្តិរូបទេនៅពេលដែលគេសរសេរហើយនោះ។ ប៉ុន្តែតាមពិតគឺអ្នកនៅក្រោមផ្ទះរបស់លោកទេបាននិយាយថាគេប្រាប់លោកថា គេបំពេញបែបនេះ បែបនោះក្រោយពីគេធ្វើហើយនោះ?

**ឆៈ** បាទ អារឿងធ្វើប្រវត្តិរូបហ្នឹង គេមកពីធ្វើវិញ គេប្រាប់។ មិនមែនប្រាប់ខ្ញុំទេ ប្រាប់ម្តាយខ្ញុំថាគេធ្វើប្រវត្តិរូបហើយ។ ប៉ុន្តែគេយកទៅណា ឬយកទៅដាក់នៅកន្លែងណាទេ ប៉ុន្តែគ្រាន់តែខ្ញុំជាកសិករខ្ញុំធ្វើប្រវត្តិរូបអ្វី តែប៉ុណ្ណឹងទេ។

**សៈ** តើលោកដឹងដែរឬទេថាប្រធានភូមិនោះធ្វើដូចម្តេចដើម្បីឲ្យប្រាកដថាប្រជាជនដែលសរសេរប្រវត្តិរូបនោះត្រូវ ឬមិនត្រូវ? តើគាត់ផ្ទៀងផ្ទាត់ បាទដូចជាអ្នកដែលនៅក្រោមផ្ទះរបស់លោកហ្នឹងគេផ្ទៀងផ្ទាត់ម៉េច ដូចជាដើម្បីឲ្យប្រាកដថាអ្នកហ្នឹងប្រាកដជាកសិករមកពីកំពង់ឆ្នាំង ឧទាហរណ៍។ តើគេធ្វើម៉េចដើម្បីផ្ទៀងផ្ទាត់នោះ?

[១៤:០០:០០]

**ឆៈ** បាទ អារឿងការផ្ទៀងផ្ទាត់នេះ គេមើលទៅតាមដែលយើងមានគោ ឬមានរទេះសម្រាប់ឧបករណ៍ធ្វើស្រែចម្ការហ្នឹងខ្លះ ហើយនិងពិនិត្យទៅប្រវត្តិរូបគឺជាអ្នកកសិករពិតបានថា ព្រោះបានរស់នៅរាល់ថ្ងៃ។

**សៈ** ប៉ុន្តែតើលោកដឹងដូចម្តេចថាប្រធានភូមិ ឬក៏អ្នកផ្សេងនៅក្នុងការអនុវត្តប្រសិនជានរណាម្នាក់គ្រាន់ដាក់ថា ខ្ញុំមានគោពីរនៅខេត្តកំពង់ឆ្នាំង។ តើមេភូមិគាត់ធ្វើម៉េចនឹងដឹងថារឿងហ្នឹងជាការពិត

បើគេគ្រាន់តែសរសេរអ៊ីចឹង គេធ្វើម៉េចឲ្យដឹងថាអ្នកហ្នឹងនិយាយពិត?

**ឆ៖** បាទ រឿងហ្នឹងក៏ខ្ញុំមិនដឹងដែរ ប៉ុន្តែគេមើលតែតាមប្រវត្តិរូបហ្នឹង បើថាគេដាក់ប៉ុន្មានគឺថា ប្រជាជន ជាអ្នកធ្វើស្រែ គឺធ្វើស្រែហើយ។ ហើយបើថាអ្នកស្ម័យត្រាណ អ្នកស្ម័យត្រាណហើយ ធ្វើរបៀបហៅថាត្រួសៗ មិនបាច់និយាយអីច្រើនទេ គឺថាធ្វើហ្នឹងវាដើម្បីត្រួសៗមិនបាច់ -- មិនមែននៅពិតប្រាកដ មិនពិតប្រាកដប៉ុន្មានទេ។

**ស៖** ប៉ុន្តែមិនមានអ្នកណាប្រាប់លោកអំពីរបៀបដែលគេយកប្រវត្តិរូបហ្នឹងទៅផ្ទៀងផ្ទាត់អ្វីទេ។ តើមាននរណាម្នាក់សួរលោកដើម្បីឲ្យផ្ទៀងផ្ទាត់ប្រវត្តិរូប ដើម្បីឲ្យដឹងថាអ្នកហ្នឹងនិយាយពិត ឬមិនពិតដែរឬទេ?

[១៤:០១:៥៤]

**ឆ៖** បាទ បើគេថាប្រវត្តិ គេមើលតាមប្រវត្តិរូបហើយ។ បើថាពិតនោះ វាដឹងគេកុហក គេថា-- បើសិនជាគេជាកសិករហើយ ព្រោះបែរថាធ្វើទាហានវិញ ក៏អាហ្នឹងស្រេចតែលើសាមីខ្លួនគេនោះទេ។ ប៉ុន្តែបើតាមការពិត គេស្រាវជ្រាវប្រវត្តិរូបនេះ បើថាកសិករគេដាក់ឲ្យនៅខាងកសិករអ៊ីចឹងតែម្តង។ បើទាហាន គេដាក់ថាស្ម័យត្រាណ គេដាក់ឲ្យនៅតាមស្ម័យត្រាណអ៊ីចឹងទៅ។

**ស៖** ដូច្នេះអ្វីដែលលោកនិយាយគឺថា ប្រសិនបើទាហាន គេដាក់ថា គេជាទាហាន ប៉ុន្តែគេដាក់ក្នុងប្រវត្តិរូបថាជាកសិករ តើអ្នកដែលប្រាប់ការណ៍មិនពិតហ្នឹងគឺមានសំណាង គឺថាអាចរស់បាន។ រីឯអ្នកដែលបញ្ជាក់ពីការពិតមិនមានសំណាងទេ តើអាចអ៊ីចឹងទេបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំគិតថាសំណួរទាំងអស់នេះគឺចង់សួរឲ្យសាក្សីធ្វើការស្មានដើម្បីផ្តល់ការសន្និដ្ឋានថា តើអ្នកណាសំណាង ឬមិនអ្នកណាមិនមានសំណាង។ ដូច្នេះហើយគឺថា -- ដូច្នេះគឺថាគាត់សួរចំណុចនេះគឺឲ្យសាក្សីធ្វើការស្មានហើយបាទ។

[១៤:០៣:៣៧]

**លោក វ៉ិចទ័រ កូប៉េ៖**

នេះគឺជាជំទាស់ដ៏ចម្លែកមួយ គឺថាយើងបានឈានដល់ចំណុចមួយគឺយើងដល់ខ្លឹមសារនៃចំណុចសំខាន់នៃសាក្សីនេះ អំពីគោលនយោបាយអំពីការកំណត់ទិសដៅ យកទាហានលន់ នល់ ឬមន្ត្រីលន់ នល់ជាទិសនោះ។ វិធីនៃការជ្រើសរើស ដូច្នេះសាក្សីអាចបញ្ជាក់ពីការពិតអំពីដំណើរការហ្នឹងបាន ដោយថាសំណួរសួរគាត់អំពីការដឹងរបស់គាត់ទៅលើដំណើរការនៃការជ្រើសរើសនេះ។ គឺជាកត្តាសំខាន់ណាស់ជាពិសេសគឺទាក់ទងទៅនឹងសក្ខីកម្មដែលខ្ញុំហៅថា "អ្នកមិនសំណាងហ្នឹងគឺគេយកទៅសម្លាប់"។ បាទ ដូច្នេះ ខ្ញុំមិនយល់ថាសហព្រះរាជអាជ្ញាជំទាស់ក្នុងគោលបំណងអ្វី ហើយមានមូលដ្ឋានអ្វីនោះទេ លោកប្រធាន។

[១៤:០៥:២៦]

**លោក ឌេល លីសាក់៖**

ខ្ញុំមិនមានជំទាស់ទេ បើសិនជាមេធាវីសួរនូវសំណួរពីអង្គហេតុ ប៉ុន្តែគាត់សួរសាក្សីឲ្យសាក្សីធ្វើការស្មានថា តើអ្វីអាចកើតមានឡើង ប្រសិនបើៗគេនិយាយក្នុងប្រវត្តិរូបពិត មិនពិត តើគេមានសំណាង ឬមិនមានសំណាង។ ដូច្នេះហើយវាអាចនឹងជាសំណួរធ្វើឲ្យសាក្សីធ្វើការស្មាន និយាយស្មានទៅវិញ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយដែលសួរឡើងដោយមេធាវី វ៉ិចទ័រ កូប៉េ ដែលទៅលើចំពោះសាក្សីរូបនេះគឺជាសេចក្តីជំទាស់មានមូលដ្ឋានត្រឹមត្រូវ សមស្របបំផុតហើយ។ ដូច្នេះ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរបែបស្មានៗដូច្នេះទេ។ សូមលោកមេធាវីរៀបចំនូវសំណួរឲ្យបានច្បាស់លាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងអនុវត្តតាមលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកអាចបញ្ជាក់អំពីផ្ទៀងផ្ទាត់ប្រវត្តិរូបទាំងហ្នឹងបន្តិចបានទេ? តើមានអ្នកណាគេឲ្យលោកទៅពិនិត្យមើលខ្លឹមសារនៃប្រវត្តិរូបហ្នឹងដែរឬទេ?

[១៤:០៦:០៤]

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ គេមិនឲ្យខ្ញុំពិនិត្យទេ រឿងការងារគេឯណោះផ្សេង។ ការងារខ្ញុំផ្សេង វាខុសគ្នា។ អ៊ីចឹងគេមិនឲ្យខ្ញុំទៅជិត ទៅពិនិត្យអីអ៊ីចឹងៗទេ។

**ស៖** តើលោកដឹងទេ ប៉ុន្មានសប្ដាហ៍ក្រោយពីថ្ងៃ១៧មេសានុ៎ង មានអ្នកណាម្នាក់ត្រូវបានគេចោទប្រកាន់ ដោយសារតែមិនប្រាប់ការពិត នៅពេលខ្លួនសរសេរប្រវត្តិរូបហ្នឹងដែរឬទេ?

**ឆ៖** បាទ អត់មានគេចោទប្រកាន់អីទៀតទេ ព្រោះអីយើងប្រាប់គេត្រង់ហើយ គេថាយើង -- មុននឹងសរសេរប្រវត្តិរូបគេប្រាប់ថា "អ្នកឯងបើធ្វើអី ប្រាប់គេឲ្យត្រង់។ បើប្រាប់មិនត្រង់ វាអត់រួចខ្លួនទេ"។ អ៊ីចឹងគឺថាប្រាប់គេតាមត្រង់អ៊ីចឹងទៅ រួចមកអត់មានសកម្មភាពអីបន្តអីទៀតទេ។

[១៤:០៧:២៩]

**ស៖** ប៉ុន្តែថាតើលោកមានបានចូលរួមក្នុងការពិភាក្សា ឬនិយាយអ្នកណាជាមួយអ្នកណា ដែលគេនិយាយថាត្រូវចាត់តាំងមនុស្សណាឲ្យតាមដានចំពោះអ្នកដែលនិយាយមិនពិតក្នុងការសរសេរប្រវត្តិ-រូបនោះដែរឬទេ?

**ឆ៖** បាទ កាលហ្នឹងគ្មានទេ អត់មានអ្នកណាឲ្យតាមដានអារឿងប្រវត្តិរូបអីទេ។ អាហ្នឹងស្រេចទៅលើតែកម្មាភិបាលតែមួយមុខហ្នឹងទេ។ កម្មាភិបាលប្រធានភូមិនោះទេ អត់អ្នកណាសម្រេចតាមដានទៅអីអត់ទេ។

**ស៖** លោកសាក្សី តើលោកមានដឹងអំពីការបែកញែកពីគ្នា ឬការបំបែកពីគ្នារវាងពួកមូលធន ឬក៏ប្រភេទប្រជាជនហ្នឹង? ឧទាហរណ៍ គេមើលទៅប្រវត្តិរូប ដើម្បីចង់ដឹងថាអ្នកណាជាទាយទុន ហើយអ្នកណាមិនមែនជានាយទុន។ អ៊ីចឹងលោកដឹងទេ?

**ឆ៖** បាទ អារឿងហ្នឹង ខ្ញុំមិនដឹងទេ។

[១៤:០៨:២៥]

**ស៖** តើស្រ៊ន ឬក៏អ្នកដទៃទៀត មានសម្រេចថាអ្នកណាជាមន្ត្រីលន់ នល់ ហើយមន្ត្រីលន់ នល់ហ្នឹងចងសំដៅថាម៉េចដែរ លោកដឹងដែរឬទេ?

**ឆ៖** បាទ ត្រង់ហ្នឹងអត់ដឹងទេ។

**ស៖** តើលោកដឹង ស្រ៊ន ឬក៏អ្នកដទៃទៀត ក្រោយពីអានប្រវត្តិរូបរបស់អ្នកទាំងនោះហើយ មានសម្រេចថាអ្នកណាជាខ្មាំង អ្នកណាមិនមែនជាខ្មាំងយ៉ាងដូចម្ដេចដែរទេ?

**ឆ៖** បាទ អត់ទេ អត់ដឹងរឿងហ្នឹង។

**ស៖** តើលោកដឹងថា ស្រ៊ន ឬអ្នកដទៃទៀត ដឹងថាអ្នកណាមកពីភ្នំពេញ? អ្នកណាមកពីកំពង់ឆ្នាំងអីដែរទេ ក្រោយពីគេអានប្រវត្តិរូបហ្នឹង តើគេមានរាប់ចំនួនហ្នឹង អ្នកណាមកពីភ្នំពេញ អ្នកណាមកពីកំពង់ឆ្នាំងដែរទេ?

**ឆ៖** បាទ អត់ៗដែរទេខ្ញុំ ត្រង់ហ្នឹងបាទ។

**ស៖** លោកដឹងថា គេមានទម្រង់បែបបទប្រវត្តិរូបហ្នឹង តើប្រជាជនសរសេរនៅលើក្រដាសបែបណាដែរប្រវត្តិរូបហ្នឹង? តើគេសរសេរប្រវត្តិរូបហ្នឹងជាមួយទម្រង់ក្រដាសបែបណា? នៅលើក្រដាសបែបណាលោកដឹងទេ?

[១៤:១១:០២]

**ឆ៖** បាទ ប្រហែលក្រដាសហ្នឹងមានតែក្រដាសសៀវភៅក្មេងរៀន អានេះហ្នឹង អា -- មិនមែនមានក្រដាសរ៉ាម មានក្រដាសអីត្រឹមត្រូវទេ។ អាក្រដាសសៀវភៅធម្មតា។

**ស៖** លោកសាក្សីសូមកុំនិយាយថា តាមធម្មតា បើលោកដឹងអ្វីលោកនិយាយថាអ៊ីចឹងទៅ។ ខ្ញុំអត់ចង់ដឹងពីរឿងតាមធម្មតាទេ ខ្ញុំចង់ដឹងថាតាមដែលលោកដឹង ចាំហ្នឹង តើទម្រង់ក្រដាសបែបណា? ប្រភេទក្រដាសបែបណា ដែលគេយកទៅសរសេរប្រវត្តិរូបនោះ?

**ឆ៖** បាទ ដែលខ្ញុំដឹង គឺក្រដាសសៀវភៅ មិនជាក្រាស់ទេសៀវភៅហ្នឹង គឺសៀវភៅសម្រាប់ក្មេងរៀន អាកាលពីសម័យនោះ ឃើញតែក្រដាសសៀវភៅ ក្រដាសបួនជ្រុងហ្នឹង ក្រដាសតូចៗ ក្រដាសសៀវភៅក្មេងរៀនហ្នឹង។

**ស៖** លោកសាក្សី តើលោកដឹងទេថា តើបុគ្គលម្នាក់ហ្នឹងត្រូវសរសេរលម្អិតប៉ុនណាដែរ ឧទាហរណ៍ឈ្មោះឪពុក ឈ្មោះម្តាយ តើមានកូនប៉ុន្មាននាក់? លោកមានមដឹងទេ គេសរសេរលម្អិតប៉ុនណាដែរលោក?

**ឆ៖** បាទ ខ្ញុំមិនដឹងទេអារឿងការសរសេរលម្អិតនេះគឺខ្ញុំមិនបាននៅជិតទេ។ អត់មានដឹងទេ។

[១៤:១៣:១១]

**ស៖** បាទ ខ្ញុំសូមចូលទៅដំណាក់កាលបន្ទាប់មកទៀត នៅ -- គិតថាមនុស្សទាំងអស់ហ្នឹងបានបានសរសេរប្រវត្តិរូបគ្រប់ៗគ្នាហើយ ត្រឡប់មកកន្លែងដើមវិញ អ្នកខ្លះមកចូលផ្ទះ មកកាន់ផ្ទះរបស់លោកវិញ តើមានអ្វីកើតឡើងចំពោះអ្នកទាំងនោះក្រោយពីសរសេរប្រវត្តិរូបរួចរាល់ទាំងអស់គ្នាហើយ?

**ឆ៖** បាទ ត្រូវហើយ គេសរសេរប្រវត្តិរូបរួចហើយ វាអ្នកមកផ្ទះវិញ ហើយក្រោយមកវាអាណាទៅធ្វើទាហានហ្នឹងវា គេឲ្យបញ្ជូនទៅកន្លែងផ្សេងអ៊ីចឹងទៅ។

**ស៖** តើលោកដឹងរឿងនេះតាមរយៈអ្វីដែរ? លោកបានស្ដាប់ឮ លោកបានឃើញ ឬក៏អ្នកណាម្នាក់ដើរនិយាយនៅក្នុងភូមិថាអ្នកដែលសរសេរប្រវត្តិរូបជាទាហានត្រូវបានគេហៅទៅណាទៅណីអ៊ីចឹង លោកដឹងដោយរបៀបណា?

**ឆ៖** បាទ អានេះខ្ញុំដឹងដោយសារគេថាដែរ ឮគេថាដែរទេអារឿងសរសេរប្រវត្តិរូបរួចហ្នឹង គេសរសេររបៀបអ៊ីចេះៗគេប្រាប់។ គេប្រាប់មកបានខ្ញុំដឹង។

[១៤:១៤:៥៤]

**ស៖** ខ្ញុំយល់មិនបានពេញលេញទេលោកសាក្សី តាមរយៈសក្ខីកម្មរបស់លោក លោករស់នៅក្នុងភូមិមួយដែលមានមនុស្សចំនួនប្រហែលជា៥០គ្រួសារទេ។ សូមលោកនឹកឡើងវិញ តើលោកមានបានឮអ្នកណាម្នាក់និយាយ ដែលនិយាយថាអ្នកដែលសរសេរ មានសរសេរក្នុងប្រវត្តិរូបរបស់ខ្លួនថាជាទាហានជាអីទេ? មានគេនិយាយអ៊ីចឹងទេ?

**ឆ៖** បាទ បានឮគេនិយាយដែរ ដែលខាងនៅផ្ទះម្ដាយខ្ញុំ នៅក្រោមផ្ទះខ្ញុំហ្នឹងនិយាយប្រាប់ម្ដាយខ្ញុំថា គេធ្វើៗប្រវត្តិរូបហ្នឹង គេមិនដឹងយកទៅខាងណាទេ គ្រាន់តែថាធ្វើប្រវត្តិ ខ្ញុំបានសរសេររួច។ ថាអ៊ីចេះ ធ្វើពីរដងហើយ។

**ស៖** តើលោកមានបានឃើញដោយផ្ទាល់ភ្នែកទេ ដែលប្រជាជនខ្លះបាននិយាយ បានគាត់បានប្រាប់ប្រជាជនខ្លះថាគាត់ជាទាហាន លន់ នល់ ឬអីអ៊ីចឹង? លោកមានបានដឹងអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេត្រង់ហ្នឹង។

**ស៖** ចុះចំពោះអ្នករដ្ឋការរបប លន់ នល់ តើមានប្រាប់អ្នកទាំងនុ៎ងឲ្យទៅកន្លែងណាៗ ដែរទេចំពោះរដ្ឋការ លន់ នល់ នេះ?

[១៤:១៦:៥៤]

**ឆ៖** បាទ កន្លែងរដ្ឋការ លន់ នល់ នេះគេឲ្យទៅ ដូចថាគេចង់ផ្លាស់ទីលំនៅ ឥឡូវវានៅគ្នាច្រើនពេក មិត្តឯងទៅនៅភូមិនោះមួយ នៅភូមិនោះខ្លះទៅ។ អ៊ីចឹងគេឲ្យទៅអ៊ីចឹងទៅ ប៉ុន្តែវាទៅបាត់ខ្លះៗអ៊ីចឹងបានវាស្ងាត់ពីនៅក្នុងភូមិហ្នឹងខ្លះ។

**ស៖** លោកដឹងទេថា មានការពិភាក្សាគ្នាចំពោះមន្ត្រី លន់ នល់ ឬក៏ថាអ្នករដ្ឋការ លន់ នល់

ដែរទេ? តើគេកំណត់ថាម៉េច កំណត់ថាម៉េចថាអ្នកណាជាអ្នករដ្ឋការ លន់ នល់ នោះកំណត់ដោយរបៀបណា? លោកមានឮអ្នកណាគេនិយាយរឿងនេះទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេត្រង់ហ្នឹង។

**ស៖** លោកបាននិយាយចំពោះអ្នករដ្ឋការ លន់ នល់ តិច។ អ៊ីចឹងចំពោះលោកតើលោកចង់មានន័យថាម៉េចចំពោះអ្នករដ្ឋការ លន់ នល់ នេះ?

**ឆ៖** រដ្ឋការ លន់ នល់ នេះថាទាហាន លន់ នល់ តែម្តង ជាទាហាន។ ខ្ញុំយល់អ៊ីចឹង។

**ស៖** តើលោកពេលនេះលោកកំពុងតែនិយាយថា ទាហាន លន់ នល់ គឺថាគេដឹងថាទាហាន លន់ នល់ លុះក្រោយពេលគេប្រមូលប្រវត្តិរូបហ្នឹងមកពិនិត្យ អាន ពិនិត្យអីហើយទើបដឹងថាអ្នកទាំងនុ៎ងជាទាហាន លន់ នល់ ឬក៏យ៉ាងម៉េច?

[១៤:១៩:១៨]

**ឆ៖** បាទ អារឿងដឹងថាគេធ្វើប្រវត្តិរូបរួចហើយ បានដឹងថាអានេះទាហាន លន់ នល់, អានេះប្រជាជន។ ប៉ុន្តែខ្ញុំមិនបានឃើញប្រវត្តិរូបគេសរសេរ ប៉ុន្តែឮគេប្រាប់ខ្ញុំថាគេធ្វើប្រវត្តិរូបអ៊ីចឹងរួចហើយ។

**ស៖** តើលោកដឹងទេថា មានទាហានប៉ុន្មាននាក់ដែលពិតជាសរសេរនៅក្នុងប្រវត្តិរូបរបស់ខ្លួនដោយស្មោះត្រង់ថា ខ្លួនជាទាហាន? តើលោកដឹងទេគិតពីចំនួនវិញ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** តើលោកមានដឹងថាមានអ្នកណាម្នាក់សួរអ្នកទាំងនោះអំពីបុណ្យស័ក្តិរបស់គេឬក៏គេជាទាហានមកពីណា? អ៊ីចឹង សំណួរប្រភេទហ្នឹងលោកមានដឹងថាអ្នកណាបាននិយាយអ៊ីចឹងទេ?

**ឆ៖** បានដឹងគឺប្រធានភូមិហ្នឹងតែម្តង។

**ស៖** តើប្រធានភូមិហ្នឹងមានប្រាប់មកលោកថាគាត់បានដឹងដោយរបៀបណាទេ?

**ឆ៖** បាទ គាត់មិនដឹងជាដឹងពីណាមកទេ បើគាត់ប្រាប់ថាឲ្យធ្វើប្រវត្តិរូបទាហានដោយទាហានហ្នឹង។ មិនមែនមានតែកម្មាភិបាលទេដែលដឹងធ្វើប្រវត្តិរូបឲ្យប្រធានភូមិធ្វើប្រវត្តិរូបអ៊ីចឹង។

**ស៖** លោកសាក្សីខ្ញុំកំពុងតែចង់ដឹងថាតើលោកបានដឹងថា កម្មាភិបាលដទៃទៀតបានដឹងថា អ្នកនេះជាទាហានលន់នល់ហ្នឹងដែរឬក៏អត់? តើកម្មាភិបាល ឬក៏ប្រជាជនហ្នឹងគេផ្ទៀងផ្ទាត់ប្រវត្តិរូបដោយរបៀបណាបានដឹងថាអ្នកហ្នឹងជាទាហាន លន់ នល់ នោះ?

[១៤:២១:៥៤]

**ធ៖** ខ្ញុំមិនដឹងសព្វគ្រប់ទេរឿងបញ្ហាអ្នកនេះធ្វើទាហាន អ្នកនោះធ្វើនេះនោះមិនបានដឹងទេបាទ។

**ស៖** នៅពេលមួយនោះមានមនុស្សមួយក្រុមដែលគេប្រមូលដាក់នៅម្តុំ ហើយបើខ្ញុំយល់មិនច្រឡំទេលោកប្រើពាក្យថាជាការប្រើល្បិច ឬជាការបោកបញ្ឆោតហ្នឹង លោកចាំទេរឿងនេះ?

**ធ៖** ភ្លេចបាត់ហើយអាហ្នឹង។

**ស៖** សូមលោកជួយពន្យល់ម្តងទៀតទៅក្រុមមនុស្ស -- ដែលលោកមិនដឹងថាជាអ្នកណាទេ ក៏ប៉ុន្តែលោកដឹងថាត្រូវគេបញ្ឆោតឲ្យទៅរស់នៅម្តុំហ្នឹងនៅកន្លែងណាមួយដុំនោះ។ តើលោកអាចរៀបរាប់បន្តិចទេ អាល្បិចដែលគេបោកបញ្ឆោតទៅលើមនុស្សមួយក្រុមហ្នឹង គេបោកបញ្ឆោតរបៀបម៉េច?

**ធ៖** បាទ ខ្ញុំឆ្លើយត្រង់នេះថា ខ្ញុំដឹងហ្នឹងគេប្រាប់ថា អ្នកឯងនៅត្រង់ហ្នឹងវាពិបាកណាស់អត់មានអង្ករ អត់មានអីហូបអីចឹង អត់មានទីជម្រកអីចឹងទៅ ទៅនៅភូមិផ្សេងៗពីហ្នឹងទៀតទៅ។ ខ្លះវាតាមគេថាចេះតែទៅអីចឹងទៅ។ គេឲ្យនៅមួយកន្លែងអត់មានអង្ករហូបដែរ ទាល់តែទៅបែងចែកទៅតាមភូមិខ្លះៗបានៗមានស្បៀងមានអង្ករហូប។

**ស៖** តើគេអូសទាញ ឬក៏បោកបញ្ឆោតអ្នកទាំងហ្នឹងដោយរបៀបណា? គេបោកបញ្ឆោតទល់មុខម្នាក់មួយអីចឹង ឬក៏គេបោកបញ្ឆោតនៅក្នុងអង្គប្រជុំណាមួយ?

[១៤:២៤:៤៦]

**ធ៖** បាទ គេបោកបញ្ឆោតនៅមុខហ្នឹងផ្ទាល់ហ្នឹងគេអត់មានប្រជុំទេថា អ្នកឯងនៅហ្នឹងបានអង្ករអីហូប? ឥឡូវទាល់តែចេញទៅរកនៅភូមិមួយទៀត ដោយសារវានៅហ្នឹង កន្លែងហ្នឹងវាច្រើនចង្អៀតអីអីចឹង ទាល់តែយើងទៅរកកន្លែងមួយផ្សេងទៀតអីចឹងទៅ។

**ស៖** ខ្ញុំអត់យល់លោកសាក្សី ការពន្យល់នេះ។ ទី១ លោកថាគេបានប្រើការ -- ប្រើល្បិចកលបោកបញ្ឆោតដើម្បីឲ្យមនុស្សហ្នឹងវាមកនៅម្តុំ។ អីចឹងខ្ញុំចង់សួរលោកថា តើលោកដឹងថាគេប្រមូលមនុស្សហ្នឹងឲ្យមកនៅម្តុំហ្នឹងបានដោយរបៀបណា គេបោកបញ្ឆោតដោយរបៀបណា?

**ធ៖** គេដឹងរបៀបណាទេ ព្រោះខ្ញុំមិនសូវដឹងដែរត្រង់ហ្នឹង។

**ស៖** ដូច្នេះ សក្ខីកម្មរបស់លោកដែលលោកឆ្លើយម្តងមុននោះគឺថា មានពេលនោះមនុស្សមកនៅមួយក្រុម មិនដឹងថាជាអ្នកណា ហើយលោកក៏មិនដឹងថាគេមកដោយរបៀបណា គ្រាន់មកដល់ ឃើញគេនៅមួយក្រុម គឺជាអ្វីដែលលោកចង់និយាយមែនទេ?

[១៤:២៦:៣៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ផ្តល់ឱកាសមួយទៅមេធាវីការពារក្តីក្នុងការសួរផ្លាញ់មកលើសាក្សីរូបនេះ គឺមានសេចក្តី -- លោកសាក្សីបានឆ្លើយទៅនឹងសំណួរហ្នឹង-- សួរប្រហែលជាប្រាំមួយដងហើយ សំណួរដដែលហ្នឹង។ ដូច្នេះមេធាវីការពារក្តីក៏ពាក់ព័ន្ធនៅក្នុងការធ្វើលក្ខណៈមួយមិនត្រឹមត្រូវ។ សាក្សីមិនបាននិយាយថា មិនស្គាល់ថាអ្នកទាំងនោះជាអ្នកណានោះទេ គ្រាន់តែគាត់និយាយថា គាត់អត់ដឹងថាពេលគេផ្លៀងផ្ទាត់ប្រវត្តិរូបដោយរបៀបណាហ្នឹង គាត់ថាអ៊ីចឹងមែន។ ការសួរសំណួរដដែលៗហើយបានលើកឡើងមកធ្វើឲ្យសាក្សីមានការយល់ច្រឡំ។ ដូច្នេះ យើងខ្ញុំសូមជំទាស់ចំពោះការសួរដដែលៗបែបនេះ។

[១៤:២៧:៣៧]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទយោងតាមដំណើរការនីតិវិធីមិនមានការសួរជាន់គ្នាមួយដងណានោះទេ គ្រាន់តែខ្ញុំចង់ដឹងអំពីអត្តិភាពនៃក្រុមមនុស្សដែលគេទៅនៅម្តុំហ្នឹង តើគេទៅនៅដោយរបៀបណា? ហើយសាក្សីគាត់អត់មានយោបល់អី គាត់មិនដឹងថាតើគេមកនៅម្តុំដោយរបៀបណានោះ?

**លោក ឌេល លីសាក់៖**

ខ្ញុំសូមបន្ថែមបន្តិចលោកប្រធាន។ មិនត្រឹមត្រូវតែការដែលលើកសំណើនៅចំពោះមុខសាក្សីបែបនេះ។ ដូច្នេះ ខ្ញុំសូមកុំឲ្យគាត់មានការផ្តល់ជាយោបល់អីអ៊ីចឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកសហព្រះរាជអាជ្ញាដូច្នេះសុំ -- នៅពេលដែលលោកសួរទៅប្រពន្ធរបស់ ខៀវ សំផន ក៏លោកធ្វើដូចគ្នានេះដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៩:២២]

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីតាំងសំណួរទៅមុខទៀត។ ចំណុចអម្បាញ់មិញនេះអង្គជំនុំជម្រះបានសមល្មម

នឹងយកទៅពិចារណាបានហើយ។ ហើយទី២ សូមរំឭកលោកមេធាវីថាការលើកឡើងប្រៀបធៀបទៅនឹងវិធីសាស្ត្រភាគីម្ខាងទៀតសួរទៅប្រពន្ធលោក ខៀវ សំផន គឺលោកលើកច្រើន ច្រើនសាហើយ។ បញ្ហាទាំងអស់នេះអង្គជំនុំជម្រះនឹងយកពិនិត្យពិចារណាសម្រេចសេចក្ដីហើយ វាយតម្លៃទម្ងន់នៃភស្តុតាងនោះ។ សូមរំឭកថាមិនគប្បីលើកដដែលរបៀបដូច្នេះទេ។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកសាក្សី មានមនុស្សមួយក្រុមដែលគេចោទប្រកាន់ថាជាទាហាន លន់ នល់ គឺថាគឺត្រូវគេយកឲ្យរស់នៅម្ដុំក្នុងពេលណាមួយនោះ តើលោកចាំថា វាកើតនៅពេលណាពិតប្រាកដនោះទេ? គេឲ្យទៅនៅម្ដុំនៅពេលណា? ប៉ុន្មានសប្ដាហ៍? ប៉ុន្មានអាទិត្យមកក្រោយ១៧ មេសា នុ៎ង?

[១៤:៣០:៣៨]

**លោក ឡេវ ឡាំ៖**

**ឆ៖** ក្រោយ១៧ មេសា ហ្នឹងវាឃើញថាមកក្នុងភូមិហ្នឹង មកដល់ក្នុងភូមិហ្នឹង រួចគេឲ្យចេញហើយចេញអស់នោះទៅទៀតទៅ មិនដឹងគេយកទៅខាងណា មិនដឹងគេទៅខាងណាទេ។ វាបាត់ចេញពីភូមិហ្នឹងអស់មួយចំនួនបាត់ទៅហើយ។

**ស៖** តើគេទៅណាដែរ អ្នកដែលថាបាត់ចេញពីភូមិ ទៅណា?

**ឆ៖** ខ្លះគេចេញពីភូមិបាត់ទៅ ខ្លះមិនដឹងជាគេទៅណា ព្រោះខ្ញុំមិនដឹងដែរ។ ខ្ញុំតាមគេដែរបាទ។

**ស៖** ក្រុមនេះ គឺក្រុមមនុស្សដែលលោកនិយាយនេះ ជាក្រុមតែមួយ ឬក៏យ៉ាងម៉េច? គឺជាក្រុមមនុស្សដែលលោកនិយាយថា ជាក្រុមមនុស្សក្នុងចំណោមមនុស្ស១០នាក់ដែលលោកនាំទៅកន្លែងមួយនោះ ហ្នឹងឬក៏មិនមែនទេ?

**ឆ៖** បាទ ហ្នឹងមិនមែន នេះអាផ្សេងទេ អារឿង ខ្ញុំនិយាយពីព្រឹកនោះ អានុ៎ងគេឲ្យខ្ញុំនាំ គេថាគេបោស គេថាឲ្យជូនអាប៉ុន្មាន ពីរបីគ្រួសារហ្នឹងទៅនៅភូមិផ្សេង។ ដល់អ៊ីចឹងបានថា ខ្ញុំទៅហ្នឹង។ អារឿងបាត់ប៉ុន្មានក្រុម មួយក្រុមទៀតនោះ ខ្ញុំមិនដឹងទេ គេចេញទៅ ខ្ញុំមិនដឹងដែរ។

[១៤:៣២:៤១]

**ស៖** បាទ លោកសាក្សី ព្រឹកមិញនេះលោកនិយាយពីថាមានមនុស្សមួយក្រុមប្រហែលជា ៧០

នាក់ ហើយក្នុងហ្នឹងគឺថាគេឱ្យលោកយកមនុស្ស ១០នាក់ចេញក្នុងចំណោម ៧០ហ្នឹង យក១០នាក់ចេញទៅ។ តើ១០នាក់ហ្នឹងជានរណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់ចំពោះការលើកសក្ខីកម្មមិនត្រឹមត្រូវនេះ គាត់ថាគាត់យកមនុស្ស ២០នាក់ទៅកន្លែងសម្លាប់មនុស្ស ហើយក្នុងនោះ១០នាក់ត្រូវបានគេចងដៃ រុំមុខយកទៅបាត់ទៅ។ ដូច្នេះខ្ញុំយល់ឃើញថា មេធាវីការពារក្តីកំពុងតែនាំឱ្យសាក្សីមានការយល់ច្រឡំច្របូកច្របល់ហើយ។ សាក្សីនិយាយថាគាត់បានយកមនុស្សទៅ ២០នាក់ ហើយក្នុងចំណោម ២០នាក់ ១០នាក់ត្រូវគេចងដៃ ចងស្លាបសេកទ្និង។ បាទ ខ្ញុំសូមជំទាស់ចំពោះពាក្យនាំទៅកន្លែងសម្លាប់មនុស្ស។

**លោក វ៉ិចទ័រ កូប៉េ៖**

ហ្នឹងអ្វី ដែលខ្ញុំកំពុងតែព្យាយាមសួរទៅដល់ចំណុចហ្នឹងហើយនេះ។

[១៤:៣៣:៥៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីនៅពេលមួយនោះ លោកនាំមនុស្ស១០នាក់ ពីកន្លែងមួយ យើងថាកន្លែង (ក) ទៅកាន់កន្លែង (ខ)។ តើ១០នាក់ហ្នឹងជាអ្នកណា លោកសាក្សី?

**ឆ៖** បាទ កន្លែងមនុស្សហ្នឹងជាប្រជាជន គេហៅថាប្រជាជនស្វ័យត្រាណ។

**ស៖** សូមលោកពន្យល់ឱ្យបានលម្អិតតិចមើល៍ "ស្វ័យត្រាណ" ហ្នឹងមានន័យថាម៉េច?

**ឆ៖** បើតាមដែលខ្ញុំដឹង ខ្ញុំថាស្វ័យត្រាណពីសម័យ លន់ នល់ ស្វ័យត្រាណមើលរបៀបទៅវាឈ្លបភូមិបាទ។ អាហ្នឹង ស្វ័យត្រាណហ្នឹងរបៀបកងឈ្លបភូមិនោះ អាហ្នឹង។

**ស៖** តើលោកដឹង ធ្វើដូចម្តេចបានដឹងថាមនុស្ស១០នាក់ហ្នឹងថាជាកងស្វ័យត្រាណហ្នឹង? លោកនិយាយជាអ្នកទាំងទ្និង មុនពេលលោកនាំខ្លួនទៅហ្នឹង ឬក៏យ៉ាងម៉េចបានលោកដឹងថាអ្នកទាំងហ្នឹងជាស្វ័យត្រាណ?

**ឆ៖** បាទ ប្រធានភូមិថានាំប៉ុន្មានបីបួនគ្រួសារហ្នឹង សុទ្ធតែពួកស្វ័យត្រាណទេ នាំទៅភូមិផ្សេងទៅ។ បានថាខ្ញុំនាំទៅហ្នឹង។

[១៤:៣៥:៤៥]

**ស៖** តើប្រធានភូមិប្រាប់លោកថា គាត់ដឹងថាពួកហ្នឹងជាស្ម័យត្រាណដោយវិធីណា? ថាតើគេដឹងប្រវត្តិពីរបីគ្រួសារដោយរបៀបណា មេភូមិប្រាប់លោកអីចឹងទេ?

**ឆ៖** មេភូមិគេប្រាប់ថាពួកហ្នឹងស្ម័យត្រាណ ហើយនាំទៅឲ្យទៅនៅភូមិផ្សេងទៅ តាមនេះទៅ។

**ស៖** តើគាត់ប្រាប់លោកទេ មុនពេលដែលគេចាប់ចងអ្នកនោះ ឬក៏គេចាប់ចងហើយឬនៅ ឬក៏ទាល់តែពេលក្រោយទេ បានគេចងអ្នកនោះ?

**ឆ៖** បាទ នាំទៅហ្នឹងគេអត់ទាន់ចងទេ មានគោ មានរទេះដែរ។ គេអត់មានទាន់ចងទេ ចងទាល់តែទៅដល់កន្លែងគេតែម្តង បានគេចងនៅហ្នឹងតែម្តង។

**ស៖** នៅពេលដែលគេទៅដល់កន្លែងនោះ តើជាកន្លែងដែលលោកបាននិយាយពីខាងដើម ដែលលោកនិយាយថាលោកបាននៅកន្លែងហ្នឹងប្រហែលតែ១០នាទី។ តើកន្លែងហ្នឹងអ្នែស?

**ឆ៖** បាទ ប្រហែលខ្ញុំនៅកន្លែងហ្នឹងមែន នៅ។ ពិតណាស់ ខ្ញុំនាំពីហ្នឹងទៅ ស្រាប់ដល់កន្លែងហ្នឹងមានទ័ពស្រុកហ្នឹងគេទទួលយកត្រឹមហ្នឹងទៅ។

**ស៖** នោះឯងជាកន្លែងដែលលោកបាននិយាយពីខាងដើមថា លោកមិនដែលបានឃើញរណ្តៅសាកសពអ្វីទេ។ តើត្រឹមត្រូវដែរឬទេ?

[១៤:៣៧:៥៦]

**ឆ៖** បាទ ដល់នាំទៅហ្នឹង ខ្ញុំមិនបានទៅដល់កន្លែងរណ្តៅសពទេ។ គឺគ្រាន់តែថា ទ័ពនោះគេថា "ហ៊ឺ! មិត្តឯងនៅហ្នឹងហើយ នៅមួយកន្លែង កុំដើរឆ្វេចឆ្វាច។ ខ្ញុំនាំមនុស្សយកទៅហើយ"។ មានតែប៉ុណ្ណឹង។

**ស៖** បន្ទាប់ពី១៥នាទី លោកក៏បានត្រឡប់ទៅពីកន្លែងណា ដែលលោកមកនោះ លោកទៅវិញអីចឹងឬទេ?

**ឆ៖** បាទ ខ្ញុំត្រឡប់មកវិញ មកភូមិច្រកសង្កែវិញ។

**ស៖** តើនេះជាមនុស្ស១០នាក់ មានតែ១០ទេ ដែលលោកយកទៅ ទៅកន្លែងតែមួយ កន្លែងដែលលោកបាននិយាយគឺថាមានតែ១០នាក់ប៉ុណ្ណឹងទេឬ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនប្រាកដទេថាតើមេធាវីការពារក្ដីចង់មានគោលបំណងដូចម្ដេចទេ ព្រោះគាត់អះអាងដោយមិនត្រឹមត្រូវតាមសម្ដីរបស់សាក្សី ហើយគាត់សាក្សីគាត់និយាយថា គាត់នាំ២០នាក់ ហើយទៅដល់នោះគេចង១០នាក់។ ប៉ុន្តែមេធាវីនៅតែនិយាយថាគាត់នាំ១០នាក់។ ដូច្នេះថាសូមមានកំណត់ត្រាត្រឹមត្រូវក្នុងតុលាការពីរឿងនេះ។

[១៤:៣៩:៤៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ហើយក្នុងចំណោមមនុស្ស២០នាក់ តើលោកនាំទៅ២០ ឬក៏១០នាក់ទៅកន្លែងហ្នឹង សូមឆ្លើយបញ្ជាក់?

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ ខ្ញុំនាំទៅ២០នាក់ ហើយទាំងមានក្មេងចំនួនប្រាំនាក់ទៀត។ ក្មេងជាកូនចៅរបស់ឪពុកម្ដាយគេអ្នកនាំទៅហ្នឹងតែម្ដង។

**ស៖** នៅពេលដែលលោកទុកអ្នក២០នាក់ហ្នឹងនៅកន្លែងមួយនោះ -- ខ្ញុំសួរម្ដងទៀត។ នៅពេលដែលលោកចាកចេញមក ក្រោយពីនៅកន្លែងនោះ១៥នាទី តើមនុស្ស២០នាក់នោះនៅកន្លែងនុំងដដែលនៅ -- បានន័យថានៅរស់នៅឡើយទេ នៅឈរអង្គុយកន្លែងហ្នឹងនៅឡើយទេ?

**ឆ៖** បាទ ខ្ញុំឃើញនៅៗកន្លែងហ្នឹងនៅឡើយទេ អត់យកចេញនៅឡើយទេ ដែលខ្ញុំចេញមក។

[១៤:៤១:០៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសម្រាកហើយ ឥឡូវប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សីក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:00]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ប្រសិនបើនៅមានសំណួរសូមប្រាប់ដល់អង្គជំនុំជម្រះផងថាតើការបែងចែកពេលវេលារវាងក្រុមមេធាវីការពារក្តី នួន ជា ជាមួយនឹងក្រុមមេធាវីការពារក្តី ខៀវ សំផន យ៉ាងម៉េចដែរ?

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធានយើងយល់ស្របគ្នាថាខ្ញុំនឹងប្រើពេលកន្លះម៉ោងទៀត ហើយប្រហែលជា ២៥នាទី ៣០នាទី នឹងប្រគល់ជូនទៅមេធាវីការពារក្តីលោក ខៀវ សំផន បាទ។

**ស៖** លោកសាក្សីទោះបីជាលោកបានបញ្ជាក់ទៅលើចំណុចនេះពីមុនហើយក្តីប៉ុន្តែចង់ឲ្យច្បាស់នៅពេលនេះ តើត្រឹមត្រូវឬទេ ថាលោកមិនបានឃើញដោយខ្លួនឯងទេនូវការកាប់សម្លាប់ជាក់ស្តែងនោះនូវមនុស្សទាំង២០នាក់នេះ?

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយថាមិនបានឃើញទេ គ្រាន់តែយកទៅហ្នឹងមានគេទទួលនុងបាត់ហើយទ័ពស្រុកនោះ ហើយឲ្យខ្ញុំនៅឈរម្តុំ រួចបានគេឲ្យខ្ញុំមកវិញ។

**ស៖** តើខ្លួនលោកផ្ទាល់តើលោកបានដឹងឮ១ថ្ងៃ ២ថ្ងៃក្រោយមកបន្ទាប់ពីលោកទុកអ្នកទាំងអស់នោះ។ តើលោកដឹងឬក៏អាចនឹងមានសញ្ញាអ្វីមួយថា អ្នកទាំងនោះត្រូវបានសម្លាប់ឬក៏ក្លិន ឬក៏ឮ សំឡេងអាសានីអីជីករណ្តៅ ឬក៏មានសញ្ញាអ្វីដែលធ្វើឲ្យលោកអាចយល់បានស្រដៀងនេះទេ?

**ឆ៖** បាទ អត់ដឹងទេ អត់ដឹង។

[១៥:០៤:00]

**ស៖** នៅពេលដែលលោកថាលោកមិនដឹង មានន័យថាលោកមិនបានឃើញមិនបានឮអ្វី ឬក៏យ៉ាងម៉េច? សូមលោកបញ្ជាក់។

**ឆ៖** បញ្ជាក់ត្រង់ហ្នឹងថា បាននាំទៅមែន តែមិនបានឃើញរណ្តៅគេកាប់ទុក គេត្រៀមទុកដូចជា ដំបងដូចជាស្អី អត់បានឃើញអានុ៎ង អត់បានឃើញ បានខ្ញុំថាខ្ញុំមិនដឹង។

**ស៖** លោកសាក្សីដើម្បីឲ្យច្បាស់អំពីចំនួនៗមនុស្ស គឺថាមុនពេលសម្រាក គឺថាយើងមានការយល់ច្រឡំថាតើមាន ១០នាក់ ឬក៏២០នាក់ដែលលោកបាននាំទៅនោះ។ ខ្ញុំបានពិនិត្យមើលចម្លើយពីមុនរបស់លោកដែលលោកឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេតលោកបាននិយាយពីមនុស្ស ១០នាក់។ ប៉ុន្តែថ្ងៃនេះលោកនិយាយថា២០នាក់។ អ៊ីចឹងខ្ញុំចង់សួរលោកថាដើម្បីឲ្យប្រាកដនោះតើមានមនុស្សប៉ុន្មាននាក់ដែលលោកបាននាំទៅកន្លែងមួយនោះ ១០, ២០ ឬក៏លើសពីហ្នឹង?

**ឆ៖** បាទខ្ញុំបានជម្រាបលោកពីព្រឹកម្តងរួចហើយថា ខ្ញុំបាននាំចំនួនមនុស្ស២០នាក់ មិនមែននាំ ១០នាក់ទេ មានទាំងកូនក្មេងចំនួនប្រាំនាក់ទៀតហើយ។ ក្មេងហ្នឹង ក្មេងអាចដើររួចដែរ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ។ ខ្ញុំគ្រាន់តែអានឲ្យលោកស្តាប់នូវខ្លឹមសារមួយអំពីចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតគឺ ERN 00274647 ទំព័រ៦ កថាខណ្ឌទី១។ លោកនិយាយថា "គេប្រមូលឲ្យអ្នកទាំងអស់នោះ ហើយគេបែងចែកទៅជាក្រុមមនុស្ស១០នាក់ ក្រុមតូច"។ ប៉ុន្តែថ្ងៃនេះលោកនិយាយថាមួយក្រុមនោះ គឺថាមានមនុស្ស២០នាក់ទៅវិញ?

[១៥:០៦:២៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់សំណួរបែបនេះ។ មេធាវីការពារក្តីគឺថាបំភ័ន្តដល់សាក្សីខ្លឹមសារដែលគាត់បានអានហ្នឹងគឺនិយាយអំពីថា តើមានរឿងអ្វីកើតឡើងនៅពេលដែលទៅដល់កន្លែងសម្លាប់? ពេលនោះគឺគាត់ឆ្លើយថា គេបែងចែកជា១០ចេញពីក្រុមហ្នឹង។ ដូច្នេះហើយគាត់ស្រង់យកចំណុចខ្លី គឺធ្វើឲ្យសាក្សីភ័ន្តច្រឡំអំពីសេចក្តីដកស្រង់ដូចជាបញ្ជាក់ឲ្យសាក្សីយល់ថា គាត់បាននាំទៅតែ ១០នាក់ទៅវិញ។ ដូច្នេះសំណួរនេះមិនសមស្រប។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមបន្តទៅសំណួរមួយទៀត។ គឺថាសូមឲ្យសហព្រះរាជអាជ្ញាកុំប្រើពាក្យថាទីសម្លាប់មនុស្ស។ គឺថាយើងមិនទាន់បានឮពីសាក្សីបញ្ជាក់ពីរឿងហ្នឹងថាគេសម្លាប់មនុស្សនៅកន្លែងហ្នឹងទេ។ ប៉ុន្តែ ខ្ញុំសូមបន្តទៅមុខទៀត។

[១៥:០៧:៣៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ដើម្បីឲ្យលោកនិយាយបន្ថែមទៀតអំពីមនុស្សដែលលោកបាននិយាយថា ជាស្វ័យត្រាណ ជាភាសាខ្មែរនោះ។ តើលោកអាចពន្យល់ម្តងទៀតបានទេ តើពាក្យថាស្វ័យត្រាណនោះ គឺសំដៅទៅរកក្រុមមនុស្សមួយក្រុមហ្នឹង គឺជាក្រុមមនុស្សបែបណាដែរ?

**លោក ឡេវ ឡាំ៖**

**ឆ៖** ស្វ័យត្រាណហ្នឹងវា -- មិនមែនជាក្រុមទេ អានេះជាលក្ខណៈជាគ្រួសារ គ្រាន់តែគេធ្វើជាស្វ័យត្រាណហ្នឹង គ្រាន់តែ -- តាមខ្ញុំយល់ "ស្វ័យត្រាណៗ" ដូចថាជាឈ្លបភូមិហ្នឹង។ មានតែប៉ុណ្ណឹង។

**ស៖** ជាឈ្លបភូមិនោះ គឺជាអ្វីដែលតាមការចងចាំរបស់លោកហ្នឹងគឺថា វាខុសពីទាហាន លន់ នល់, ខុសពីមន្ត្រីលន់ នល់។ ក្រុមហ្នឹងគឺក្រុមផ្សេងទេ តើអ៊ីចឹង ឬដូចម្តេច?

**ឆ៖** ស្វ័យត្រាណហ្នឹង អឺ! ជាទាហានលន់ នល់ ហ្នឹង ហើយនិងស្វ័យត្រាណវាដូចតែគ្នា។ មួយគ្រាន់តែជាទាហានសម្រាប់វ៉ៃនៅសមរភូមិ។ មួយជាស្វ័យត្រាណការពារនៅភូមិឃុំរបស់គេ។

[១៥:០៩:៣២]

**ស៖** តាមអ្វីដែលខ្ញុំយល់នោះ ត្រូវដែរឬទេ ពីមុនលោកនិយាយថាក្រុមពួកទាហានលន់ នល់ គឺជាក្រុមផ្សេង។ លោកមិនចាំបាច់ធ្វើអ្វីទេ ពីព្រោះពួកហ្នឹងគេបញ្ជូនទៅតំបន់ផ្សេងរួចទៅហើយ។ តើខ្ញុំស្តាប់លោកនិយាយបែបនោះ ត្រូវដូចដែលលោកឆ្លើយទេ?

**ឆ៖** បាទ ទាហាន លន់ នល់ ហ្នឹងគេបែងចែកថា ទាហាន លន់ នល់ ហើយនិងស្វ័យត្រាណនេះ វាជារួមបើថាវានៅក្នុងដូចថា ក្រុមវាតែមួយទេ អាហ្នឹងវាបក្ខពួកវាតែមួយទេ។ ស្វ័យត្រាណហើយនិងទាហានហ្នឹងវាដូចតែគ្នាទេ។

**ស៖** ប៉ុន្តែពីមុននោះលោកបាននិយាយអំពីក្រុមដាច់ដោយឡែកមួយ គឺក្រុមទាហាន លន់ នល់ ដែលថាផ្សេង។ តើខ្ញុំយល់លោកហ្នឹងត្រូវទេ ពីមុនលោកថាផ្សេង ឥឡូវលោកថាដូចគ្នា។ តើអាចពន្យល់ដូចម្តេច?

**ឆ៖** អានេះតាមខ្ញុំដឹងគឺថាទាហាន គឺទាហានហ្នឹង ស្វ័យត្រាណហ្នឹងវាដូចតែគ្នាហ្នឹង អាមួយគ្រាន់តែទាហានចេញច្បាំង អាមួយទាហានវានៅ វាមិនអាចចេញច្បាំងទេអាហ្នឹង។ អាស្វ័យត្រាណហ្នឹងវាជា ដូចថាជាសេនាជន។ អាហ្នឹងវាមិនមែនចេញច្បាំងដូចជាទាហានពេញមុខទេ។ សូមអស់។

[១៥:១១:៣០]

**សៈ** បាទ តើលោកអាចពន្យល់ម្តងទៀតបានទេថាតើមេភូមិហ្នឹងដឹងដោយរបៀបណាថា អ្នកទាំងអស់គឺថាអ្នកទាំង២០នាក់នេះពិតជាស្ម័យត្រាណមែន ឬមិនមែននោះ? ឬក៏អ្នក២០នាក់ក្នុងក្រុមហ្នឹង គេបានសរសេរក្នុងប្រវត្តិរូប ឬដោយរបៀបណា?

**ឆៈ** បាទ គេសរសេររួចហើយបានគេដឹង រឿងការងារប្រធានភូមិៗនេះគេសម្រាប់ដឹង។ ឯការងារខ្ញុំនេះ គ្មានដឹងអីទេ។

**សៈ** អ៊ីចឹងលោកមិនដឹងថាមនុស្ស ២០នាក់ ស្ម័យត្រាណទាំង២០នាក់នេះ តាមពិតអ្នកហ្នឹងបាន ឬមិនបានសរសេរប្រវត្តិរូបនោះ លោកមិនដឹងទេ។ តើអ៊ីចឹងឬយ៉ាងម៉េច?

**ឆៈ** បាទ អ្នកដែល២០នាក់ហ្នឹង ខ្ញុំមិនបានដឹងថា គេសរសេរប្រវត្តិរូបហើយឬនៅទេ ប៉ុន្តែគ្រាន់គេឲ្យជូន ឲ្យជូនទៅនៅភូមិមួយផ្សេង។ អ៊ីចឹងបានថាខ្ញុំជូនគេទៅហ្នឹងបណ្តោយ។

[១៥:១៣:៤]

**សៈ** តើលោកដឹងថា អ្នកទាំងអស់ហ្នឹងមកពីស្រុកណា ឬក៏ក្រុងណាដែរឬទេ?

**ឆៈ** បាទ មក -- ដឹងមកថា មកពីកំពង់ឆ្នាំង ដឹងថាមកពីកំពង់ឆ្នាំង តែប៉ុណ្ណឹង។

**សៈ** តើលោកដឹងដោយរបៀបណា?

**ឆៈ** បាទ ដឹងដោយប្រធានភូមិគេប្រាប់ហ្នឹងហើយ។

**សៈ** តើប្រធានភូមិប្រាប់លោកថា គាត់ដឹងហ្នឹង ដឹងដោយរបៀបណាទេ?

**ឆៈ** បាទ គ្រាន់តែគាត់ប្រាប់ថា "ឥឡូវអ្នែងនាំអាប៉ុន្មាននាក់ ប៉ុន្មានគ្រួសារនេះ ប្អូនដប់ អា២០នាក់នេះទៅឲ្យនៅភូមិផ្សេងទៅ វានៅវាខ្វះស្បៀង វាខ្វះអី"។ គ្រាន់តែគាត់ប្រាប់ថាអ៊ីចឹងទេ។

**សៈ** តើលោកនៅចាំទេ ថាតើមាននរណាម្នាក់ក្នុងចំណោមអ្នក២០នាក់រស់នៅក្នុងផ្ទះណាមួយក្នុងចំណោមផ្ទះ ១៥០ខ្នងហ្នឹងទេ ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ហ្នឹង?

[១៥:១៤:៤១]

**ឆៈ** បាទ នៅផ្ទះគេឯលិចនេះ ចុងខាងលិច ទាល់ក្នុងផ្ទះហ្នឹងគេឲ្យហៅទៅពីផ្ទះគេផ្សេងទៀត មិនមែនផ្ទះខ្ញុំទេ គឺហៅចេញ នៅចុងខាងលិចភូមិ។ វានៅក្នុងភូមិដែរ តែវានៅអែប មិននៅពាក់កណ្តាល នៅខាង ខាងលិច។

**សៈ** តើលោកនៅចាំថាបានឃើញពួកគេមុនពេលដែលលោកនាំពួកគាត់ទៅ ទៅកន្លែងដែលលោកថានោះទេ? ធ្លាប់បានឃើញពួកហ្នឹង ពួកគាត់ហ្នឹងដើរនៅតាមភូមិនៅកន្លែងណាមួយ មុននឹងគេ

ឲ្យលោកជូនពួកអ្នកហ្នឹងទៅទេ?

**ឆ៖** បាទ អត់ អត់ឃើញ។ អត់ដែលឃើញទេ។

**ស៖** ដើម្បីឲ្យប្រាកដថា ខ្លួនលោកផ្ទាល់គឺមិនដែលស្គាល់អ្នកទាំង២០នាក់ហ្នឹងទេ តើត្រូវឬទេ?

**ឆ៖** ខ្ញុំវាមិនដែលស្គាល់ដែរ ប៉ុន្តែ -- មិនដែលស្គាល់ទេ ប៉ុន្តែគ្រាន់តែថាបើសិនជាឃើញ ក៏នៅក៏អាចនៅចំណាំមុខដែរ ប៉ុន្តែវាអត់ឃើញទល់ឥឡូវ។

**ស៖** តើលោកធ្លាប់ទៅកំពង់ឆ្នាំងទេ ១ឆ្នាំក្រោយមក?

**ឆ៖** បាទ ខ្ញុំធ្លាប់ទៅ។

[១៥:១៦:៤៨]

**ស៖** តើធ្លាប់បានឃើញអ្នកណាម្នាក់ក្នុងចំណោម២០នាក់ហ្នឹង នៅខេត្តកំពង់ឆ្នាំងទេ ពេលដែលលោកទៅ?

**ឆ៖** បាទ អត់ឃើញទេ។

**ស៖** តើលោកធ្លាប់ឮអ្នកណានិយាយទេថា អ្នកណាម្នាក់ដែលក្នុងចំណោម២០នាក់នេះ ឬក៏រស់នៅក្នុងខេត្តកំពង់ឆ្នាំងនៅឡើយទេ?

**ឆ៖** អត់ អត់មានឮគេនិយាយទេ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងត្រឡប់ទៅចម្លើយរបស់លោកឡើងវិញ ហើយខ្ញុំអានខ្លឹមសារមួយនៅក្នុងចម្លើយរបស់លោកកាលពីមុននោះ។ ទំព័រERN 00 -- ទំព័រទី៦ គឺD225/68 នោះ “គឺពេលមួយគេមានការបញ្ជាឲ្យសម្លាប់មនុស្សមួយចំនួននៅដើមឆ្នាំ១៩៧៥ ហើយបញ្ជានោះ ត្រូវអនុវត្តភ្លាម ហើយគេប្រាប់អ្នកទាំងអស់នោះ គឺថាឲ្យធ្វើដំណើរទៅទីសម្លាប់ហ្នឹង គឺថាអាចនឹងតាមរទេះគោ ហើយទិសដៅហ្នឹងគឺថាមានមនុស្សច្រើនណាស់។ នៅពេលដែលគេប្រមូលនៅទីនោះ គេបែងចេញទៅជាមនុស្សក្រុមតូចៗ១០នាក់ ហើយគេប្រាប់ថា គេនឹងយកទៅឲ្យជួបអង្គការ ប៉ុន្តែគេត្រូវចងមុខ ហើយចងស្លាបសេកចងដៃស្លាបសេកនោះ”។ ដូច្នេះ តើរឿងនេះអ្នកផ្សេងប្រាប់លោក ឬក៏លោកបានឃើញដោយផ្ទាល់ពីហេតុការណ៍ដែលលោកនិយាយនេះ? សូមលោកពន្យល់អំពីខ្លឹមសារដោយផ្អែកទៅលើអ្វីដែលខ្ញុំសួរលោក ហើយលោកថាមិនបានឃើញៗ។ ចុះលោកអាចពន្យល់ពីចម្លើយរបស់លោកពីមុននេះ ដូចម្តេច? បាទ សូមលោកពន្យល់។

[១៥:១៩:១៨]

**ឆ៖** បាទ ខ្ញុំមិនបានឃើញគេយកទៅនោះទេ ប៉ុន្តែគ្រាន់តែឮសូរគេថាហ្នឹងណ៎ា។

**ស៖** ថាតើអ្នកណាប្រាប់លោកថា មានមនុស្ស១០០គ្រួសារត្រូវបានគេយកទៅសម្លាប់នៅដើមឆ្នាំ១៩៧៥នោះ?

**ឆ៖** បាទ មានតែប្រធានភូមិហ្នឹងទេ គេប្រាប់ហ្នឹង។

**ស៖** តើគាត់ដឹងដោយរបៀបណា?

**ឆ៖** គាត់ដឹងដោយសារគាត់ជាមេភូមិបានគាត់ដឹង។

**ស៖** តើគាត់ប្រាប់ថាគាត់បានឃើញថាគាត់បានចូលរួម ឬក៏គាត់ពាក់ព័ន្ធនៅក្នុងកាប់សម្លាប់ហ្នឹងផ្ទាល់ ឬដូចម្តេច?

**ឆ៖** គាត់ប្រធានភូមិហ្នឹង ការកាប់សម្លាប់ផ្ទាល់ក៏ខ្ញុំមិនបានដឹងដែរ មិនដែលឃើញគាត់សួរសម្លាប់ទេ តែប្រធានភូមិហ្នឹង។

**ស៖** តើហេតុអ្វីដែលគាត់ប្រាប់លោកថាគាត់បានដឹងនោះ?

[១៥:២១:១២]

**ឆ៖** ហេតុអ្វីដែលគាត់ប្រាប់ខ្ញុំហ្នឹង គាត់ថា “ អើ! អ្អែងមើលអស់ អ្អែងបាត់ពីស្រុកពីភូមិអស់អ្អែងឃើញទេ អត់មានឃើញនៅ”។ គាត់ប្រាប់អ៊ីចឹង។ នឹកឃើញថាស្មានតែស្លាប់ហើយ ត្រឹមហ្នឹងហើយអត់មានឃើញអ៊ីចឹង។ ខ្ញុំគិតអ៊ីចឹង។

**ស៖** ប៉ុន្តែលោកបានឆ្លើយថា គេប្រាប់ មេភូមិប្រាប់លោកថាឲ្យយកទៅនៅភូមិផ្សេង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំត្រូវជំទាស់នឹងសំណួរនេះ លោកប្រធាន។ សំណួរនេះគឺច្រំដែល។ ចំណុចទី២មេធាវីការពារក្តីគឺថារៀបខ្លឹមសារពាក្យសក្ខីកម្មរបស់គាត់នោះគឺថាៗគេប្រាប់គាត់ត្រូវឲ្យទៅនៅភូមិថ្មី ប៉ុន្តែតាមពិតគឺគេប្រើឧបាយកលកុហក បញ្ឆោតទេ។ ដូច្នេះគឺថាមេធាវីសួរដដែលនេះ គឺរយៈពេលដដែលៗច្រើនដង ហើយមេធាវីគាត់បានប្រើពាក្យមិនត្រូវតាមពាក្យរបស់សាក្សី។

[១៥:២២:៤១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសួរសាក្សី ប្រសិនបើសហព្រះរាជអាជ្ញាជាអ្នកបង្ហាញភស្តុតាងវិញ តាមពិតមិនមែនជាការផ្លាស់ប្តូរទៅទីផ្សេងជាការយកទៅសម្លាប់នេះទេ នេះគឺជាសេចក្តីសន្និដ្ឋាន។ ប៉ុន្តែខ្ញុំពិនិត្យឃើញថាមានភាពខុសគ្នារវាងចម្លើយសាក្សីដែលបានផ្តល់ពីខាងដើមថា មួយក្រុមគេបញ្ជូនទៅ យកទៅកន្លែងមួយ។ ហើយខ្ញុំចង់បង្ហាញភស្តុតាងឲ្យតុលាការយល់ថា តើការពិតនៅកន្លែងណា ដែលថាយក២០នាក់ហ្នឹងក្រោយមកឃើញទៀតទេ ឬក៏យ៉ាងម៉េច? បាទ ដូច្នេះសូមលោកប្រធានមេត្តាសម្រេចបាទ។

[១៥:២៣:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៤:០៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃជំទាស់របស់ក្រុមតំណាងសហព្រះរាជអាជ្ញាចំពោះសំណួរនេះមានលក្ខណៈសមស្រប។ អង្គជំនុំជម្រះទទួលស្គាល់ថាពិតជាសំណួរច្រំដែលពិតប្រាកដមែន ហើយមេធាវីសូមលោកទៅមុខទៀត បើមានសំណួរពាក់ព័ន្ធជាមួយនឹង ដែលត្រូវសួរសាក្សីរូបនេះ។ សូមអញ្ជើញតាំងសំណួរថ្មី។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំ -- លោកសាក្សី ខ្ញុំនឹងដកស្រង់ចម្លើយរបស់លោកដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេត គឺនៅទំព័រដដែល ERN ដដែល គឺទំព័រទី៦ លើកំណត់ហេតុនោះ។ លោកបាននិយាយដូចខាងក្រោមនេះ “នៅពេលគេបញ្ជូនមនុស្សយកទៅសម្លាប់នោះ គេទៅដល់កន្លែងសម្លាប់នោះអ្នកសម្លាប់នៅចាំទីនោះ។ គេជីករណ្តៅទុកជាមុន។ អ្នកសម្លាប់គឺត្រូវប្រាប់ឲ្យអ្នកនោះអង្គុយនៅក្បែររណ្តៅ ហើយឲ្យស្តាប់អង្គការ។ អ្នកពិឃាដម្នាក់បានរាប់ មួយ ពីរ បី ហើយគេចាប់ផ្តើមសម្លាប់។ អ្នកសម្លាប់នោះសម្លាប់តែអ្នករងគ្រោះម្នាក់ទេ”។ ដូច្នេះ លោកសាក្សីតើលោកអាចពន្យល់ពីចម្លើយរបស់លោកនេះ គឺថាអ្នកឃាតករម្នាក់សម្លាប់អ្នករងគ្រោះម្នាក់។ ដូច្នេះ តើលោកពន្យល់ពីអ្វីដែលខ្ញុំអានជូនលោកអំមិញនេះបន្ថែមទៀត។

[១៥:២៥:៤០]

**ឆ៖** បាទ មនុស្សម្នាក់អាចសម្លាប់មនុស្សម្នាក់ ទាល់តែម្នាក់ចង មានអ្នកសម្លាប់ បើថាធ្វើតែឯងម៉េចធ្វើកើត ទាល់តែមានគ្នាច្រើន។

**ស៖** ខ្ញុំមិនយល់ពីចម្លើយរបស់លោកទេ លោកសាក្សី។ ខ្ញុំអានខ្លឹមសារដែលលោកបានឆ្លើយនោះជាចម្លើយរបស់លោក ដែលនិយាយថាលោកបានឃើញដោយខ្លួនឯងផ្ទាល់ ថាគេសម្លាប់មនុស្សនោះនុះ។ ប៉ុន្តែថ្ងៃនេះសក្ខីកម្មរបស់លោកនោះ គឺលោកថាមិនដែលបានឃើញដោយផ្ទាល់ភ្នែកទេ។ តើចម្លើយណាមួយដែលត្រឹមត្រូវ ដែលលោកត្រូវប្រកាន់យកនោះ?

**ឆ៖** ចម្លើយ អាហ្នឹងដូចថាវាវាក់បន្តិចហើយ សូមអធ្យាស្រ័យរកកន្លែងឆ្លើយមិនឃើញ។

**ស៖** លោកគិតថាលោកមិនអាចឆ្លើយសំណួរនេះបាន លោកសូមទោស អ៊ីចឹងទេលោកសាក្សី? សំណួរខ្ញុំគឺសាមញ្ញទេ ចង់សួរថាតើចម្លើយណាមួយដែលត្រឹមត្រូវ? ឬក៏លោកយកចម្លើយសក្ខីកម្មថ្ងៃនេះ ឬក៏លោកប្រកាន់យកចម្លើយតាមដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតពីមុន?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៥:២៧:៤៤]

**លោក ខេល លីសាក់៖**

សូមអភ័យទោសដែលខ្ញុំក្រោកឡើងម្តងទៀតនេះ។ លោកប្រធានគឺថាមេធាវីទំនងជាសួរសំណួរទៅជាក់លាក់។ គឺផ្នែកដែលគាត់អាននោះ គឺដំបូងនោះគឺមិនបានចង្អុលបង្ហាញថា -- មិននិយាយថា បានឃើញដោយផ្ទាល់ភ្នែកនោះទេ។ ប៉ុន្តែបើសិនជាមេធាវីចង់សួរផ្នែកជាក់លាក់នៅក្នុងចម្លើយនេះដល់សាក្សីបញ្ជាក់នោះ ដើម្បីឱ្យគេបំភ្លឺនោះខ្ញុំមិនជំទាស់ទេ។ ប៉ុន្តែសំណួរដែលលោកសួរអំមិញនេះ គឺមិនច្បាស់លាស់ទេ នៅពេលដែលលោកអានចម្លើយដែលមានការអះអាងប្រាំមួយយ៉ាងនៅពេលតែមួយនោះ គឺទូលំទូលាយ ជាសំណួរទូលំទូលាយ។ ដូច្នេះសូមឱ្យមេធាវីសួរឱ្យជាក់លាក់ជាងនេះ ទាក់ទងទៅនឹងខ្លឹមសារនេះ។ ជាពិសេសទៅនឹងចម្លើយដែលលោកចង់ឱ្យសាក្សីបញ្ជាក់នោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដូចជាច្រឡំហើយឥឡូវនេះ គឺសូមឱ្យតុលាការពិចារណា។ ខ្ញុំប្រើចម្លើយរបស់សាក្សីដែលនៅ

ក្នុងកំណត់ត្រានេះថា គាត់បានឃើញដោយផ្ទាល់ភ្នែក។ ប៉ុន្តែ ខ្ញុំសួរដេញដោលថ្ងៃនេះគាត់ឆ្លើយថាមិនបានឃើញដោយផ្ទាល់ភ្នែកទេ។ ប៉ុន្តែខ្ញុំចង់ដឹងពីគាត់នៅពេលនេះ ថាតើចម្លើយលាយលក្ខណ៍អក្សរពីមុននោះដែលត្រូវ ឬក៏ចម្លើយពេលនេះ?

[១៥:២៩:១១]

**លោក ឌេល លីសាក់៖**

ខ្ញុំសូមអនុញ្ញាតជួយមេធាវីម្តងទៀត។ គឺថាចំណុចចុងក្រោយដែលគាត់អាននោះគឺថាអ្នកសម្លាប់នោះគឺបានរាប់ មួយ ពីរ បី។ សាក្សីបានពន្យល់អំពីរបៀបដែលគាត់បានដឹង នេះជាមូលហេតុដែលមេធាវីចង់សួរសំណួរជាក់លាក់ទៅលើផ្នែកនេះ។ ខ្ញុំមិនជំទាស់ទេ ប៉ុន្តែបើលោកសួរចម្លើយទាំងបី បួនប្រាំនៅជាមួយគ្នានេះ គឺឲ្យសាក្សីអះអាងបញ្ជាក់តែម្តងនោះមិនត្រឹមត្រូវ។

**លោក វ៉ិចទ័រ កូប៉េ៖**

គាត់ឆ្លើយថា ម្នាក់ក្នុងចំណោមអ្នកឃាតករនោះរាប់: មួយ ពីរ បី។ បាទ ខ្ញុំសូមរៀបឃ្លាឡើងវិញ ខ្ញុំសល់ពេលតែ២នាទីទៀតតែប៉ុណ្ណោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីខ្ញុំនឹងអានជូន។ លោកថាគេដឹករណ្តៅទុកជាមុន។ ពេជ្ឈឃាដហ្នឹងរាប់ មួយ, ពីរ, បី ហើយការកាប់សម្លាប់ហ្នឹងប្រព្រឹត្តទៅ។ ខ្ញុំសួរថាលោកបានឃើញដោយផ្ទាល់ភ្នែកដោយខ្លួនឯង ឬក៏លោកបានឮពីអ្នកដទៃ។ ថាតើលោកអាចនឹងបានចម្លើយហ្នឹងតាមរបៀបណាបាទ លោកសាក្សី?

**ឆ៖** បាទ ខ្ញុំបានដឹងថា -- ខ្ញុំនៅក្បែរនោះដែរ ឮសូរថា មួយ ពីរ បី ក៏ខ្ញុំមិនដឹងថាគេសម្លាប់ទេ ឮសូរអ៊ីចឹង ហើយខ្ញុំដើរចេញមក អាហ្នឹងគេសម្លាប់។ មួយ ពីរ បី ខ្ញុំឮអ៊ីចឹងមែន។

[១៥:៣១:០៣]

**ស៖** តើអ្នកណាជាអ្នករាប់ មួយ ពីរ បី? តើពេជ្ឈឃាដនោះអ្នករាប់ឬក៏អ្នកណា តើលោកដឹងទេពេលនោះ?

**ឆ៖** បាទ មានតែពេជ្ឈឃាដទេដែលរាប់ មួយ ពីរ បី នោះ។ រឿងថាឲ្យអ្នកណាស្រែករាប់នោះអត់ អ្នកណាស្រែកកើតទេ។

**ស៖** តើលោកអាចដឹងដោយរបៀបណា បើលោកមិនបានឃើញអ្វីផងហ្នឹង តើលោកដឹងថាអ្នកណាជាអ្នករាប់ម៉េចកើត?

**ឆ៖** បាទ ខ្ញុំឮសូរតែសំឡេងរាប់ ប៉ុន្តែរឿងថាមើលមនុស្សមានឃើញឯណា វានៅព្រៃ។

**ស៖** អាចនឹងមានអ្នកផ្សេង អាចនឹងណែនាំថាដើរ មួយ ពីរ បី ឬក៏យ៉ាងម៉េច? លោកសន្និដ្ឋានដូចម្តេចបើគ្រាន់តែឮសំឡេងអ៊ីចឹង លោកអាចបញ្ជាក់អ្វីបាន? លោកសាក្សីខ្ញុំនឹងបញ្ចប់ការសួរសំណួររបស់ខ្ញុំ។ បាទ អ៊ីចឹងអាចនឹងថាចម្លើយរបស់លោក សក្ខីកម្មរបស់លោកគឺផ្អែកទៅលើ គេហៅថាការស្រមើស្រមៃរបស់លោក លោកមិនដែលបានឃើញដោយផ្ទាល់ភ្នែក លោកមិនបានស្តាប់ឮដោយត្រចៀកទេ តែលោកស្រមៃ ហើយលោកនិយាយ។ តើដូចអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់ស្រមៃទេ ឮអ៊ីចឹងមែន ខ្ញុំឮសូរ មួយ ពីរ បី ឬមួយគេឲ្យដើរ ឬមួយគេអ្នកសម្លាប់ទេ ខ្ញុំឮពីឆ្ងាយដែរប្រហែល ៣០ ម៉ែត្រ នៅចម្ងាយហ្នឹង។

[១៥:៣៣:០៧]

**ស៖** ខ្ញុំនឹងសួរម្យ៉ាងទៀត ហើយខ្ញុំសួរលោកផ្ទាល់។ មិនមានការកាប់សម្លាប់ទេលោកមិនដែលបានឃើញការកាប់សម្លាប់ណាទេ ក្រោយពី១អាទិត្យ ២អាទិត្យក្រោយពីខែមេសា ឆ្នាំ១៩៧៥។ តើលោកឆ្លើយដូចម្តេច?

**ឆ៖** ខ្ញុំអត់បានច្បាស់។

**ស៖** ចុងក្រោយខ្ញុំសួរលោកផ្ទាល់លោកសាក្សី។ លោកមិនបានឃើញការកាប់សម្លាប់ក្នុងមួយសប្តាហ៍ ពីរសប្តាហ៍ក្រោយពីខែមេសា ឆ្នាំ១៩៧៥ -- ថ្ងៃទី១៧ មេសា ៧៥។ តើត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា។

**លោក ឌេល លីសាក់៖**

លោកប្រធាន មេធាវីការពារក្តីសួរសំណួរឲ្យសាក្សីបញ្ជាក់ថាគាត់បានឃើញដោយផ្ទាល់ភ្នែក។ ខ្ញុំមិនមានបញ្ហាទេ តែបើគាត់សួរ គាត់ធ្វើទឡ្ហីករណ៍នៅទីនេះថាតើសាក្សីនេះធ្វើសក្ខីកម្មគាំទ្រអង្គហេតុថាមានការកាប់សម្លាប់ដែរឬអត់នោះ នេះជាបញ្ហាធំដែលថាគាត់ដាក់សក្ខីកម្មទៅឲ្យសាក្សីឆ្លើយ។ ប៉ុន្តែសំណួរសួរទៅចង់ឲ្យសាក្សីបញ្ជាក់ថាមិនបានឃើញដោយផ្ទាល់ភ្នែក ខ្ញុំមិនមានការជំទាស់ទេ។ ប៉ុន្តែបើមេធាវីដាក់ទឡ្ហីករណ៍ឲ្យគាត់បញ្ជាក់ អាហ្នឹងខ្ញុំជំទាស់។

[១៥:៣៤:០០]

**លោក វ៉ិចទ័រ កូប៉េះ**

គឺថាយើងចង់ឲ្យចេញជាភស្តុតាង ថាតើគាត់បានឃើញការកាប់សម្លាប់ដោយខ្លួនគាត់ផ្ទាល់ទេ ក្រោយពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥នោះ។ ដូច្នេះ សូមតុលាការពិចារណាឲ្យគាត់ឆ្លើយ។

**ប្រធានអង្គជំនុំ៖**

សាក្សី -- សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាសមស្របហើយ។ សាក្សីមិនបាច់ឆ្លើយតបទេសំណួរនេះ។ ហើយគួរចប់ទៅលោកមេធាវី អស់ពេលហើយ។

**លោក វ៉ិចទ័រ កូប៉េះ**

តាមពិតនេះ គឺថាសូមអរគុណ។ ខ្ញុំបញ្ចប់ការតាំងសំណួររបស់ខ្ញុំបាទ។

**ប្រធានអង្គជំនុំ៖**

បាទសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ នៅសល់ពេលវេលា២៤នាទីដែរ។

[១៥:៣៥:៣៦]

**លោក អាកទួរ វ៉េកគែន៖**

បាទសូមអរគុណលោកប្រធានដែលផ្តល់ពេលវេលាដ៏ច្បាស់នេះដល់ខ្ញុំ។ ខ្ញុំមានសំណួរមួយចំនួនបន្តពីសហភាតារបស់ខ្ញុំ។ ខ្ញុំសួរខ្លីទេ គឺខ្ញុំមិនសួរលើសពីពេល២៤នាទីដែលតុលាការចែកឲ្យខ្ញុំទេ។

**សួរដោយលោក អាកទួរ វ៉េកគែន៖**

**ស៖** អម្បាញ់មិញនេះលោកសាក្សីបានឆ្លើយទៅនឹងសំណួរលោក កូប៉េ ដែលបានសួរលោកថា លោកដឹងថា គ្រួសារទាំង៣០០គ្រួសារហ្នឹង មកពីតំបន់ណាដែលមកស្នាក់នៅក្នុងភូមិរបស់លោកហ្នឹង សួរថាលោកដឹងតាមរបៀបណា? ហើយកាលនោះលោកឆ្លើយថា ឪពុករបស់លោកបានពិភាក្សាជាមួយអ្នកទាំងអស់នោះ ហើយនិយាយជាមួយពួកគាត់ទាំងអស់នោះ ហើយពួកគាត់ឆ្លើយថា គាត់មកពីកំពង់ឆ្នាំង។ អ៊ីចឹងសំណួរខ្ញុំ គឺចង់និយាយថា ចុះអ្នកដែលមកពីភ្នំពេញនោះយ៉ាងម៉េចដែរ ព្រោះឪពុកលោកប្រាប់លោកថាប្រជាជនទាំងអស់នោះមកពីកំពង់ឆ្នាំង ចុះអ្នកដែលមកពីភ្នំពេញវិញនោះ យ៉ាងម៉េចដែរ?

[១៥:៣៧:១៣]

**ឆ៖** បាទអ្នកមកពីកំពង់ឆ្នាំង វាអាចនៅជាប់ក្រោមផ្ទះខ្ញុំ។ អ្នកមកភ្នំពេញវាមកនៅ -- មកនៅដែរ មកនៅតាមផ្ទះគេផ្សេង ឬនៅក្រោមម្លប់ឈើបាទ។

**ស៖** បាទ សំណួរអម្បាញ់មិញនេះ សួរថាតើលោកដឹងថាអ្នកផ្សេងទៀតនោះមកពីភ្នំពេញតាមរបៀបណា លោកដឹងតាមរបៀបណាអ្នកដែលមកពីភ្នំពេញ?

**ឆ៖** អ្នកចេញមកពីខាងភ្នំពេញ គឺមកពី -- ផ្លូវវាខុសគ្នា អាមួយមកពីកំពង់ឆ្នាំង មកពីកើត។ អាហ្នឹងមកពីភ្នំពេញ ចេញពីកំពង់ស្ពឺទៅ ចូលទៅខាងកំពង់ឆ្នាំង។ អាហ្នឹងបានថា អ្នកភ្នំពេញមកផ្សេង អ្នកកំពង់ឆ្នាំងគឺមកផ្សេង។ ប៉ុន្តែមកនៅក្នុងស្រុក និងឃុំហ្នឹងវាច្រើនណាស់ មិនមែនតែបីបួនដប់គ្រួសារទេ វាច្រើនអ៊ីចឹងម្ដង។

[១៥:៣៨:៤៥]

**ស៖** បើខ្ញុំមិនយល់សំណួរលោកច្បាស់ទេ ពីដើមទីពេលដែលសួរលោកនោះ ដើមរសៀលនេះ នៅពេលដែលលោកឆ្លើយទៅនឹងសំណួរលោក កូប៉េ លោកបានឆ្លើយថា នៅពេលដែលលោកឃើញក្រុមគ្រួសារទាំង៣០០គ្រួសារនោះមកនៅក្នុងភូមិយើងនោះ ឃើញគេតាំងលំនៅរួចទៅហើយនៅក្នុងភូមិហ្នឹង។ ឥឡូវហ្នឹង ខ្ញុំសួរថាតើលោកដឹងថាគ្រួសារមួយចំនួនដែលមកពីភ្នំពេញនោះ ដឹងនោះដឹងដោយរបៀបណា ហើយលោកឆ្លើយអម្បាញ់មិញនេះថា ដឹងថាមកភ្នំពេញ ព្រោះគេមកតាមផ្លូវផ្សេងៗគ្នា។ អ៊ីចឹងខ្ញុំចង់ -- សំណួរខ្ញុំគ្រាន់តែចង់ដឹងថា តើលោកដឹងថាគេមកពីភ្នំពេញហ្នឹង គ្រួសារមួយចំនួនមកពីក្រុងភ្នំពេញនោះតាមរបៀបណា? ចង់សួរតែប៉ុណ្ណឹងទេ?

**ឆ៖** អាមកពីភ្នំពេញហ្នឹង ឮតែដល់ណេះគេថា មានអ្នកនៅភ្នំពេញខ្លះដែលនៅក្នុងភូមិហ្នឹងហើយ។ តាមឮប្រធាន គាត់ថាមានអ្នកភ្នំពេញ ក៏មកហ្នឹងដែរ មានអ្នកកំពង់ចាមក៏មកហ្នឹងដែរ។ បានខ្ញុំដឹងតាមរយៈហ្នឹង។

[១៥:៤០:១៥]

**ស៖** លោក នេះលោកកំពុងតែនិយាយពីភូមិរបស់លោកដែលលោកមានផ្ទះនៅក្នុងភូមិហ្នឹង ឬក៏លោកនិយាយអំពីភូមិមួយផ្សេងទៀតទេ?

**ឆ៖** បាទ ខ្ញុំនិយាយពីរឿងនៅក្នុងភូមិខ្ញុំហ្នឹងទេ ដែលខ្ញុំដឹងនៅក្នុងភូមិហ្នឹងទេ អាភូមិគេផ្សេងទៀតក៏ខ្ញុំមិនដឹងទេ។

**ស៖** អ៊ីចឹងអ្វីដែលលោកប្រាប់នេះគឺថា ក្រុមគ្រួសារទាំង៣០០គ្រួសារនោះ លោកដឹងថាគេមកពីទីក្រុងភ្នំ -- លោកដឹងថាពួកគេមកពីណាពីណីនោះ តាមរយៈប្រធានភូមិរបស់លោក។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ អ៊ីចឹង។

[១៥:៤១:១៤]

**ស៖** តើប្រធានភូមិរបស់លោកនោះផ្តល់ព័ត៌មានហ្នឹងឱ្យលោកនោះ មុនពេលដែលក្រុមគ្រួសារទាំង៣០០គ្រួសារហ្នឹងបានសរសេរប្រវត្តិរូបរបស់ខ្លួន ឬក៏ក្រោយពេលដែលពួកគាត់ទាំងអស់ហ្នឹងសរសេរប្រវត្តិរូបរបស់ខ្លួនរួចហើយ?

**ឆ៖** បាទ គាត់សរសេររួចហើយបានដឹងថា ខាងនេះមកពីភ្នំពេញ នោះមកពីកំពង់ឆ្នាំង។

**ស៖** តើពេលដែលគាត់មកតាំងទីលំនៅទីហ្នឹង អ្នកទាំង៣០០គ្រួសារហ្នឹង ពេលដែលអ្នកទាំង៣០០គ្រួសារហ្នឹងមកនៅហ្នឹង ភូមិហ្នឹង ហើយនិងអ្នកដែលគ្រួសារចំនួន៧០គ្រួសារទៀតដែលគេជម្លៀសចេញ។ អ៊ីចឹងតើចន្លោះពេលទាំងពីរហ្នឹង ពេលដែលអ្នកទាំង៣០០គ្រួសារដែលមកដល់ ហើយនិងអ្នកដែលមនុស្ស ៧០គ្រួសារដែល -- ៧០គ្រួសារ ឬក៏ ២០គ្រួសារ ១០គ្រួសារហ្នឹងគេឱ្យលោកនាំទៅភូមិមួយទៀត។ តើចន្លោះពេលហ្នឹងប្រហែលប៉ុន្មានដែរ រយៈពេលប៉ុន្មានដែរ?

**ឆ៖** អាគេនាំ -- ដែលខ្ញុំបានតែនាំដែរ អាចំនួនមនុស្ស អា២០នាក់នុ៎ងទេ រួចពីនោះខ្ញុំអត់បានទៅនាំគេទេបាទ។

**ស៖** បាទ ខ្ញុំយល់ ប៉ុន្តែសំណួរខ្ញុំចង់ដឹងពីរយៈពេលចន្លោះ ពេលដែលថាក្រុមគ្រួសារទាំង៣០០គ្រួសារហ្នឹងមកដល់ ហើយនិងពេលដែលលោកនាំមនុស្ស២០នាក់ហ្នឹងទៅទីណាមួយនោះ។ អ៊ីចឹងខ្ញុំចង់ដឹងតែចន្លោះតែពេលហ្នឹងទេ ពីពេលដែល៣០០គ្រួសារ មនុស្ស៣០០គ្រួសារមកដល់ ហើយនិងពេលដែលលោកនាំគេចេញប៉ុន្មាន ២០នាក់ ឬក៏ ២០គ្រួសារហ្នឹងចេញទៅ។ ចន្លោះហ្នឹងរយៈពេលប្រហែលប៉ុន្មាន?

[១៥:៤៣:៤២]

**ឆ៖** បាទ ចន្លោះហ្នឹងប្រហែលជា៣ថ្ងៃ បានគេឱ្យនាំ ឱ្យខ្ញុំនាំគេហ្នឹងទៅ។ អង្កាល់មុននោះគេនាំទៅមុនអស់ខ្លះទៅ ប៉ុន្តែនៅក្រោយហ្នឹង ប្រហែលចំនួន២០នាក់ហ្នឹងបានឱ្យខ្ញុំនាំ។

**ស៖** បាទ លោកបានឆ្លើយថា លោកបានសង្កេតឃើញថាមានមនុស្ស ៣០០គ្រួសារចូលមកដល់ភូមិលោក ហើយឥឡូវនេះលោកឆ្លើយថា នៅក្នុងមួយគ្រួសារហ្នឹងមានប្រហែលជា៥នាក់។ ដូច្នេះមានមនុស្សប្រហែលជា ១៥០០នាក់ ដែលមកស្នាក់នៅក្នុងភូមិរបស់លោក ពិតជាមានកុមារ ឬក៏មនុស្សចាស់ មនុស្សធំ ហើយលោកក៏បានលើកឡើងដែរថាមាន។ ក៏ប៉ុន្តែអ្នកទាំងអស់នេះត្រូវសរសេរប្រវត្តិរូបរបស់ខ្លួន លោកក៏បានប្រាប់ដែរពីបញ្ហានេះ។ គឺថាមានពីរភាគបី អ្នកទាំងអស់ហ្នឹងត្រូវគេបានសុំឱ្យ

សរសេរប្រវត្តិរូបប្រហាក់ប្រហែលជា១.០០០ប្រវត្តិរូបហើយ ហើយលោកបានឆ្លើយថា ប្រហែលជា ៣ថ្ងៃក្រោយមកនោះ ប្រធានហ្នឹងអាចត្រួតពិនិត្យលើប្រវត្តិរូប១.០០០ប្រវត្តិរូបហ្នឹង ហើយគាត់អាចធ្វើការពិនិត្យពិច័យដើម្បីឱ្យដឹងថា ត្រូវយកអ្នកណាអ្នកណីចេញ។ អ៊ីចឹងលោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច ១.០០០នាក់ជាង ព្រោះ១.០០០ប្រវត្តិរូបជាង ក្នុងពេល៣ថ្ងៃ?

**ឆៈ** បាទ គេថា គេចេញក្នុង១ថ្ងៃហ្នឹង វាចេញមិនអស់ ហើយគេចេញពីភូមិហ្នឹង ឱ្យទៅនៅភូមិផ្សេងៗហ្នឹង ម្តង១០គ្រួសារ ម្តង២០គ្រួសារអ៊ីចឹងទៅ វាចេញបន្តៗ។

[១៥:៤៦:៣០]

**សៈ** អម្បាញ់មិញនេះ ប្រហែលជាមានបញ្ហាបកប្រែហើយមើលទៅ។ អម្បាញ់មិញនេះ គឺថាលោកបានឆ្លើយ ផ្តល់ចម្លើយពីរផ្ទុយគ្នា ទាក់ទងទៅនឹងប្រវត្តិរូបទាំងអស់នេះ។ ខ្ញុំបានធ្វើកត់កំណត់ត្រានៅពេលដែលសហភាតាខ្ញុំ កូប៉េ គាត់បានសួរលោក។ គាត់សួរដូច្នេះ៖ “មិនមែនដែលមានអ្នកណាប្រាប់អំពីការផ្ទៀងផ្ទាត់ប្រវត្តិរូបទេឬ? របៀបគេផ្ទៀងផ្ទាត់ណា?” ហើយខ្ញុំស្តាប់តាមរយៈការបកប្រែជាភាសាបារាំងនេះ ឮឆ្លើយថា “គេឱ្យខ្ញុំផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងប្រវត្តិរូបផ្ទាល់តែម្តង។ នេះជារបៀបផ្ទៀងផ្ទាត់ប្រវត្តិរូបតែមួយគត់។ បើសិនជាងអ្នកណាប្រាប់ថា គេជាកសិករ គេក៏ចូលទៅក្នុងក្រុមកសិករទៅ”។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់។ ហើយបន្ទាប់មកទៀត លោកនិយាយថា៖ “គេមិនដែលប្រាប់ឱ្យខ្ញុំផ្ទៀងផ្ទាត់ប្រវត្តិរូបអីទេ ពីព្រោះថាខ្ញុំមានភារកិច្ចផ្សេងទៀត”។ អ៊ីចឹងខ្ញុំសូមឱ្យលោកជួយបំភ្លឺជូនតុលាការ ថាតើលោកបានពិនិត្យទៅលើខ្លឹមសារប្រវត្តិរូបជាង១០០០នេះដែរឬទេ របស់អ្នកដែលមកនៅក្នុងភូមិលោកនេះ។ អ៊ីចឹងខ្ញុំចង់ឱ្យលោកបញ្ជាក់តែប៉ុណ្ណឹង ថាតើលោកមានបានផ្ទៀងផ្ទាត់លើប្រវត្តិរូបជាង១.០០០ហ្នឹងទេ?

**ឆៈ** បាទ បើខ្ញុំមិនបានផ្ទៀងផ្ទាត់បញ្ជីទេ ព្រោះអីភារកិច្ចខ្ញុំវាខុសគ្នា។ ភារកិច្ចកម្មាភិបាលផ្សេង ភារកិច្ចឈ្លបនោះផ្សេង អត់មានពាក់ព័ន្ធអីជាមួយគ្នា វាអត់មានអី។ ខ្ញុំមិនដែលបានត្រួតពិនិត្យអ៊ីចឹងផ្ទាល់ទេ។ អត់ទេ។

[១៥:៤៨:៣២]

**សៈ** អម្បាញ់មិញនេះ លោកនិយាយថាជាភារកិច្ចរបស់កម្មាភិបាលទេ ប៉ុន្តែអំមិញនេះ ពេលដែលលោកឆ្លើយទៅលោកមេធាវី កូប៉េ លោកឆ្លើយថា៖ “មានតែប្រធានភូមិដែលផ្ទៀងផ្ទាត់ខ្លឹមសារប្រវត្តិរូប”។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកកំពុងតែផ្លាស់ប្តូរចម្លើយ គឺចង់បានន័យមានតែប្រធាន

ភូមិទេដែលមានសិទ្ធិផ្ទៀងផ្ទាត់លើប្រវត្តិរូបហ្នឹង ក៏មានអ្នកផ្សេងដែលពិនិត្យលើប្រវត្តិរូបទាំងអស់ហ្នឹង។ អ៊ីចឹងសូមលោកបញ្ជាក់ចម្លើយលោកបន្តិចមើល?

**ឆ៖** បាទ ខ្ញុំបញ្ជាក់ត្រង់នេះបន្តិច។ ពិនិត្យលើប្រវត្តិរូបហ្នឹង វាមានប្រធានភូមិ វាមានកម្មា-ភិបាលឃុំ ថ្នាក់ស្រុក ថ្នាក់ឃុំ ថ្នាក់ស្រុកហ្នឹង ភូមិហ្នឹង វាពិភាក្សាគ្នាហ្នឹងបានគេពិនិត្យប្រវត្តិរូប។ មិនមែនថាប្រធានភូមិតែមួយទេ គឺមានកម្មាភិបាលថ្នាក់ឃុំ ថ្នាក់ស្រុកហ្នឹងដែរ។

**ស៖** តើលោកដឹងថាប្រវត្តិរូបទីមួយៗនោះ មានប៉ុន្មានទំព័រដែរ លោកអាចដឹងប្រហាក់ប្រហែលទេ? មានប៉ុន្មានទំព័រប្រវត្តិរូបមួយ?

[១៥:៥០:០២]

**ឆ៖** ខ្ញុំសូមឆ្លើយត្រង់ហ្នឹង អត់ទេ ខ្ញុំអត់ដឹងសោះហើយ។

**ស៖** តើក្នុងរយៈពេល៣ថ្ងៃនេះ ប្រធានភូមិ ហើយនិងកម្មាភិបាលផ្សេងៗទៀត ដែលធ្វើការជាមួយគាត់ហ្នឹង អាចវាយតម្លៃ ឬក៏ស៊ើបផ្ទៀងផ្ទាត់ខ្លឹមសារប្រវត្តិរូបនេះ គឺថាប្រវត្តិរូបរបស់មនុស្សទាំង៧០គ្រួសារនេះ ដែលគេត្រូវយកចេញហ្នឹងតាមរបៀបណាទៅក្នុងរយៈពេល៣ថ្ងៃនេះ គឺថាសរសេរហើយអានផ្ទៀងផ្ទាត់តែ៣ថ្ងៃហ្នឹង មានមនុស្ស៧០គ្រួសារហ្នឹងផ្ទៀងផ្ទាត់យ៉ាងម៉េច? លោកដឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធាន សន្លឹកម្មរបស់សាក្សីគឺថាលោក វែកគែន បានសួរឲ្យគាត់ឆ្លើយដោយស្មាន។ ថាតើមេភូមិ និងកម្មាភិបាលហ្នឹងធ្វើដោយរបៀបណានោះ? សំណួររបស់គាត់គឺសួរឲ្យសាក្សីឆ្លើយស្មានបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥១:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា គឺមានមូលដ្ឋានត្រឹមត្រូវ។ ដូច្នេះសេចក្តីជំទាស់មានប្រសិទ្ធភាព។

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ដែលសួរលោកនៅសំណួរចុងក្រោយអម្បាញ់មិញនេះទេ។

**លោក អាកទួរ វែកគែន៖**

បាទ ពីរបីនាទីមុននោះ ខ្ញុំបានសួរលោកថាតើចន្លោះពេលដែលក្រុមគ្រួសារទាំង៣០០គ្រួសារមកដល់ភូមិលោក ហើយនិងពេលដែលគេឲ្យលោកនាំមនុស្ស២០នាក់ទៅកន្លែងផ្សេងនោះ លោកប្រាប់ថាមានរយៈពេល៣ថ្ងៃចន្លោះពេលហ្នឹង។ អំមិញនេះ មុននឹងអម្បាញ់មិញនេះ មុនម៉ោងពីរកន្លះបន្តិចនៅពេលដែលឆ្លើយទៅនឹងសំណួររបស់មេធាវី កូប៉េ លោកឆ្លើយដូចតទៅនេះ គេសួរលោកថា "តើក្រុមគ្រួសារទាំង៣០០គ្រួសារហ្នឹងដែលនៅក្រោមផ្ទះលោកនោះ ក្នុងរយៈពេលប៉ុន្មាន? លោកឆ្លើយថា ១សប្តាហ៍។ ហើយក្នុងពេលនោះ អ្នកខ្លះបាត់ខ្លួនទៅ ហើយអ្នកខ្លះនៅក្នុងភូមិដដែល"។ អ៊ីចឹងឥឡូវនេះចម្លើយរបស់លោកនេះ ចង់និយាយថា អ្នកដែលគេបញ្ជូនទៅភូមិផ្សេងទៀតក្នុងរយៈពេល៣ថ្ងៃក្រោយមកហ្នឹង លោកចង់និយាយថា៣ថ្ងៃក្រោយមក ឬក៏១សប្តាហ៍ក្រោយមក?

[១៥:៥៣:៣៥]

**លោក ឡេវ ឡាំ៖**

**ឆ៖** បាទ ខ្ញុំបានជម្រាបហើយថា ៣ថ្ងៃក្រោយមក។

**ស៖** ជាទីបញ្ចប់ ខ្ញុំសូមឲ្យលោកបំភ្លឺចំណុចមួយ លើពាក្យដែលខ្ញុំនឹងអានប្រហែលមិនច្បាស់ទេ ប៉ុន្តែអ្នកបកប្រែនឹងកែតម្រូវ។ ពាក្យ "ស្វ័យត្រាណ" នេះ លោកបាននិយាយថា ស្វ័យត្រាណនេះគឺជាឈ្លបនៅក្នុងភូមិ។ អ្វីដែលខ្ញុំមិនយល់នោះ លោកក្នុងពេលជាមួយគ្នានោះ លោកនិយាយថាក្រុមគ្រួសារទាំង៣០០គ្រួសារដែលមកស្នាក់នៅក្នុងភូមិលោកនោះ គាត់នោះមកពីទីក្រុងពីរ គឺទីក្រុងកំពង់ឆ្នាំង ហើយនិងពីទីក្រុងភ្នំពេញ។ អ៊ីចឹងខ្ញុំមើលទៅឃើញថាមានភាពចម្រោងចម្រាសនៅក្នុងចម្លើយរបស់លោក។ អ៊ីចឹងលោកអាចពន្យល់បានទេ ហេតុអីក៏មានភាពចម្រោងចម្រាស់បែបនេះ?

**ឆ៖** ស្វ័យត្រាណនេះវា -- ដូចថា -- និយាយរួចហើយថ ស្វ័យត្រាណនេះជា វានៅការពារភូមិអាហ្នឹង គេហៅស្វ័យត្រាណ។ ទាហានគេចេញច្បាំងអាន៎ុងគេហៅថាទាហាន។ អ៊ីចឹង ថែងចែក ជាពីរអ៊ីចឹង។ ស្វ័យត្រាណវានៅការពារក្នុងភូមិមិនអាចចេញទៅច្បាំងទេ នេះហៅថាស្វ័យត្រាណ។ យើងរាល់ថ្ងៃនេះបើសិនជាឈ្លប ហៅឈ្លបភូមិដែររាល់ថ្ងៃហ្នឹង។

[១៥:៥៥:៤១]

**ស៖** ហើយអង្កាល់សម័យនោះ តាមក្រុងនោះមានស្វ័យត្រាណ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំមិនដឹងដែរ ដឹងថានៅក្នុងក្រុងមានស្វ័យត្រាណ មិនដឹងនៅតាមភូមិមានស្វ័យត្រាណ ព្រោះនៅភូមិខុសគ្នា បែងចែកជាតំបន់ខុសគ្នាបាទ។

**ស៖** បាទ ដើម្បីបញ្ចប់ អម្បាញ់មិញនេះលោក កូប៉េ បានសួរលោកបន្ទាប់ពីពេលដែលលោកនាំម្នាក់ប្រមាណ២០នាក់ហ្នឹងទៅកន្លែងផ្សេង ហើយក្រោយមកគាត់បានចាកចេញ ហើយលោកបានឃើញតម្រុយនៃការឧក្រិដ្ឋកម្ម លោកធុំក្លិនអាក្រក់ ហើយបន្ទាប់មកលោកឆ្លើយថាលោកមិនដឹងទេ "ខ្ញុំគ្រាន់តែនាំពួកគេទៅទីនោះទេ តែខ្ញុំមិនបានឃើញផ្នូរខ្មោចអីនោះទេ រណ្ដៅ"។ អ៊ីចឹងសំណួរលោក កូប៉េ អម្បាញ់មិញសួរថាតើលោកបានឃើញរណ្ដៅសាកសពទាំងអស់នុ៎ងមុនពេល ឬក៏ក្រោយលោក មានបានធុំក្លិនអាក្រក់ ឬក៏ឃើញតម្រុយណាមួយ តម្រុយឧក្រិដ្ឋអីណាមួយទេ?

[១៥:៥៧:២២]

**ឆ៖** បាទ ខ្ញុំមិនបានឃើញទេ ព្រោះអីគ្រាន់តែជូន អាលែងជូនដល់នោះមានទ័ពគេទទួលនុ៎ងហើយ ខ្ញុំមានបានទៅមើលរឿងពិនិត្យ រឿងរណ្ដៅ រឿងអីហ្នឹង មានធុំក្លិនមានអីហ្នឹង អត់ទេអត់មាន។

**ស៖** ចុះក្រោយមកទៀត សប្ដាហ៍ក្រោយទៀត ពីរបីសប្ដាហ៍ ឬពីរបីខែក្រោយមកទៀត បន្តបន្ទាប់មកហ្នឹងម៉េចទៀត?

**ឆ៖** បាទបន្តបន្ទាប់ទៀតហ្នឹង គឺខ្ញុំមិនបានទៅនៅក្បែរហ្នឹងទៀតទេ អត់មានពេលទៅនុ៎ង អត់ដឹង។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំសួរចប់ហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

លោក ឡេវ ឡាំ ការស្ដាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានលះបង់ពេលវេលាដ៏មានតម្លៃ មកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល១ថ្ងៃកន្លងមកនេះ ដោយភាពអត់ធ្មត់ ខិតខំប្រឹងប្រែងអស់ពីសមត្ថភាព និងលទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។

សូមជូនពរលោកជួបតែសំណាងល្អ មានសុខភាពល្អ ឲ្យបានសេចក្ដីសុខសេចក្ដីចម្រើន។

[១៥:៥៩:០៣]

សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនា-ការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៣ ខែកក្កដា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-689។ សូមភាគីនៃរឿងក្ដី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការនៃអង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

បាទ សូមកែសម្រួលបន្ដិចវិញ ដោយសារលំដាប់ហ្នឹងគឺសាក្សីដែលមានរហស្សនាម TCW-164 ទេ។ ដោយព្រឹកមិញក្រឡាបញ្ជីមានការរាយការណ៍មិនត្រឹមត្រូវ ហើយសូមកែតម្រូវឡើងវិញ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ឡេវ ឡាំ វិលត្រឡប់ទៅកាន់ទីកន្លែងដែលជាគោលដៅ និងបំណងដែលគាត់ចង់ទៅ ឬក៏ទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ។ ហើយដូចគ្នានេះដែរ សូមជូនសាក្សីបម្រុងត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ ហើយឲ្យនាំគាត់ត្រឡប់មកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះនិងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបមកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*